# ប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារ

## ចក្ខុវិស័យឆ្នាំ២០៤០



រៀបចំដោយ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**


អាសយដ្ឋានៈ ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរសព្ទ (៨៥៥) ២៣ ៨៨៦ ៩៩៩

គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com



ប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារ ចក្ខុវិស័យឆ្នាំ២០៤០


**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់


# ប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារ

## ចក្ខុវិស័យឆ្នាំ២០៤០


រៀបចំដោយ


**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**



បោះពុម្ពផ្សាយលើកទី១

ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧, ខែកក្កដា ឆ្នាំ២០២៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

លេខ: ០៥៥ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារ ខេត្តព្រះវិហារ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២២/១២៣៦ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍

- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២ និងមាត្រា៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- យោងសេចក្តីសម្រេចលេខ០៤១ សសរ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ
- យោងតាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារនិងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះវិហារ

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារ ខេត្តព្រះវិហារ ដែលមានចក្ខុវិស័យដល់ឆ្នាំ២០៤០ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្តីសម្រេចនេះ។

**ប្រការ២.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះវិហារនិងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងព្រះវិហារ ត្រូវរៀបចំផែនការសម្រាប់អនុវត្តប្លង់គោលប្រើប្រាស់ដីខាងលើនេះឱ្យមានប្រសិទ្ធភាព និងត្រូវរាយការណ៍អំពីវឌ្ឍនភាពជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។

**ប្រការ៣.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងព្រះវិហារ ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការកែសម្រួលប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារមុនពេលកំណត់ អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈឬផលប្រយោជន៍ជាតិ។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារត្រូវអនុវត្តតាមនីតិវិធីដែលមានចែងនៅក្នុងសេចក្តីសម្រេចលេខ០៤១ សសរ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារនិងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះវិហារ និងអភិបាលនៃគណៈអភិបាលក្រុងព្រះវិហារនិងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងព្រះវិហារ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៣កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**ជា សុផារ៉ា**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃសេចក្ដីសម្រេចលេខ...០៥៥ សសរ...ចុះថ្ងៃសុក្រ ១៣កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ត្រូវនឹងថ្ងៃទី...៣០... ខែ...មិថុនា... ឆ្នាំ២០២៣
ស្ដីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារ

# ប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារ

## ចក្ខុវិស័យឆ្នាំ២០៤០

## មាតិកា

**ទំព័រ**


**១-សេចក្តីផ្តើម** ..... ១

**២-ក្របខ័ណ្ឌសង្គម-សេដ្ឋកិច្ច និងចក្ខុវិស័យ** ..... ៣

**២.១-ក្របខ័ណ្ឌសង្គម-សេដ្ឋកិច្ច** ..... ៣

**២.២-ចក្ខុវិស័យ** ..... ៤

**៣-គោលបំណងនិងគោលដៅ** ..... ៤

**៣.១-គោលបំណង** ..... ៤

**៣.២-គោលដៅ** ..... ៤

**៤-យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្សប្រកបដោយភាពឆ្លាត ចីរភាព និងបរិយាបន្ន** ..... ៥

**៤.១-យុទ្ធសាស្ត្រអភិវឌ្ឍនគរូបនីយកម្ម** ..... ៥

៤.១.១-តំបន់នគរូបនីយកម្មបច្ចុប្បន្ន ..... ៥

៤.១.២-ទិសដៅនគរូបនីយកម្ម ..... ៦

៤.១.៣-ការអភិវឌ្ឍទីក្រុងប្រកបដោយភាពឆ្លាត ..... ៦

៤.១.៤-ការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព ..... ៧

៤.១.៥-ការអភិវឌ្ឍទីក្រុងប្រកបដោយបរិយាបន្ន ..... ៨

**៤.២-យុទ្ធសាស្ត្រគ្រប់គ្រងនិងប្រើប្រាស់ដី** ..... ៨

៤.២.១-ប្រភេទដីអាចសាងសង់បាន ..... ៨

៤.២.២-ប្រភេទដីកម្រិតការសាងសង់ ..... ១៨

**៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ** ..... ២១

៤.៣.១-អ័ក្សអភិវឌ្ឍទេសចរណ៍-ពាណិជ្ជកម្ម តាមផ្លូវជាតិ និងច្រកទ្វារព្រំដែន ..... ២១

៤.៣.២-ផ្លូវថ្នល់ ..... ២១

៤.៣.៣-ផ្លូវទឹក ..... ២៣

៤.៣.៤-ការគ្រប់គ្រងធនធានទឹកនិងការផ្គត់ផ្គង់ទឹកស្អាត ..... ២៣

៤.៣.៥-ការផ្គត់ផ្គង់ថាមពលអគ្គិសនី ទូរគមនាគមន៍ បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ..... ២៤

៤.៣.៦-ហេដ្ឋារចនាសម្ព័ន្ធសង្គម ..... ២៤

**៤.៤-យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច** ..... ២៥

៤.៤.១-ការអភិវឌ្ឍទេសចរណ៍ ..... ២៥

៤.៤.២-ការអភិវឌ្ឍពាណិជ្ជកម្ម ..... ២៧

៤.៤.៣-ការអភិវឌ្ឍឧស្សាហកម្ម ..... ២៨

៤.៤.៤-ការអភិវឌ្ឍកសិកម្មនិងការផ្សព្វផ្សាយផលិតផលក្នុងស្រុក ..... ២៩

**៤.៥- យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ច** ........ ៣០

**៤.៦- យុទ្ធសាស្ត្រការពារបរិស្ថាននិងគ្រប់គ្រងសំណល់** ........ ៣១

៤.៦.១- ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន ........ ៣១

៤.៦.២- វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ ........ ៣១

៤.៦.៣- ការគ្រប់គ្រងសំណល់រឹង ........ ៣១

៤.៦.៤- ការគ្រប់គ្រងសំណល់រាវនិងទឹកកខ្វក់ ........ ៣២

**៤.៧- យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ** ........ ៣៣

**៤.៨- យុទ្ធសាស្ត្រពង្រឹងអភិបាលកិច្ចល្អ គ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុនៅមូលដ្ឋាន** ........ ៣៤

**៥- ផែនការសកម្មភាព** ........ ៣៤

**៥.១- ការរៀបចំបទប្បញ្ញត្តិនគរូបនីយកម្ម** ........ ៣៥

**៥.២- ការផ្សព្វផ្សាយ** ........ ៣៥

**៥.៣- ការអនុវត្តគម្រោងតាមវិស័យ** ........ ៣៥

៥.៣.១- ការអភិវឌ្ឍក្រុង ........ ៣៥

៥.៣.២- ការអភិវឌ្ឍការដឹកជញ្ជូន ........ ៣៦

៥.៣.៣- ការអភិវឌ្ឍទេសចរណ៍ ........ ៣៦

៥.៣.៤- ការអភិវឌ្ឍពាណិជ្ជកម្ម ........ ៣៧

៥.៣.៥- ការអភិវឌ្ឍឧស្សាហកម្ម ........ ៣៧

៥.៣.៦- ការអភិវឌ្ឍកសិកម្មនិងការផ្សព្វផ្សាយផលិតផលក្នុងស្រុក ........ ៣៨

៥.៣.៧- ការគ្រប់គ្រងធនធានទឹកនិងការផ្គត់ផ្គង់ទឹកស្អាត ........ ៣៨

៥.៣.៨- ការផ្គត់ផ្គង់ថាមពលអគ្គិសនី ទូរគមនាគមន៍ បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ........ ៣៨

៥.៣.៩- ការគ្រប់គ្រងសំណល់រឹង ........ ៣៨

៥.៣.១០- ការគ្រប់គ្រងសំណល់រាវនិងទឹកកខ្វក់ ........ ៣៩

៥.៣.១១- ការបង្ការទប់ស្កាត់គ្រោះមហន្តរាយ ........ ៣៩

**៥.៤- ការអនុវត្តគម្រោងរយៈពេលខ្លី មធ្យម និងវែង** ........ ៣៩

៥.៤.១- ការអនុវត្តគម្រោងរយៈពេលខ្លីឬគម្រោងអាទិភាព ........ ៤០

៥.៤.២- ការអនុវត្តគម្រោងរយៈពេលមធ្យម ........ ៤១

៥.៤.៣- ការអនុវត្តគម្រោងរយៈពេលវែង ........ ៤១

**៦- ធនធានហិរញ្ញវត្ថុ** ........ ៤១

**៧- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ** ........ ៤១

**៧.១- យន្តការ** ........ ៤១

៧.២- គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត........................................ ៤២

៧.៣- ភារកិច្ច នីតិវិធី និងគោលការណ៍........................................ ៤២

**៨-សេចក្តីសន្និដ្ឋាន**........................................ ៤៣

**អនុសាសន៍**........................................ ៤៤

**សន្ទានុក្រម**........................................ ៤៥

**ឯកសារឧបសម្ព័ន្ធ**........................................ ៤៨


ꕥꕥ✲ꕥꕥ

## ១-សេចក្តីផ្តើម

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្សនៅក្រោមដំបូលរដ្ឋធម្មនុញ្ញនិងច្បាប់ រាជរដ្ឋាភិបាលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែកនិងគ្រប់វិស័យក្នុងគោលដៅបង្កើននិងកែលម្អការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា សំដៅធានាថាដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជាត្រូវបានគ្រប់គ្រង រៀបចំ ប្រើប្រាស់ ការពារ និងបែងចែកដីធ្លីប្រកបដោយសមធម៌ តម្លាភាព ប្រសិទ្ធភាព សមាហរណកម្ម និងចីរភាព ដើម្បីរួមចំណែកធ្វើឱ្យសម្រេចនូវគោលដៅជាតិក្នុងការកាត់បន្ថយភាពក្រីក្រ ការធានាសន្តិសុខស្បៀង ការការពារបរិស្ថាននិងធនធានធម្មជាតិ ការអភិវឌ្ឍស្របតាមបរិបថនៃសេដ្ឋកិច្ចទីផ្សារសេរី។ ក្នុងនីតិកាលទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលបានដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដើម្បីធ្វើជាមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងក្លាយជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ក្នុងនោះមុំទី៣ នៃចតុកោណទី៤ គឺការពង្រឹងការគ្រប់គ្រងនគរូបនីយកម្មដោយកំណត់នូវគោលដៅជាយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍទីក្រុងនិងទីប្រជុំជនឱ្យមានសោភណភាពនិងមានបរិស្ថានល្អសម្រាប់ការរស់នៅ ដើម្បីលើកកម្ពស់សុខុមាលភាពរបស់ប្រជាជននិងប្រសិទ្ធភាពសេដ្ឋកិច្ចសង្គម។

ស្ថិរភាពនិងវឌ្ឍនភាពនៃសង្គម សេដ្ឋកិច្ចនេះគឺជាកាលានុវត្តភាពជំរុញឱ្យមាននិន្នាការកើនឡើងយ៉ាងឆាប់រហ័សនៃកំណើនប្រជាជន ការប្រើប្រាស់ដីធ្លីនិងលំនៅឋាន ការរីករាលដាលនៃនគរូបនីយកម្ម និងការបង្កើតជាទីក្រុងតូចធំគ្រប់កម្រិតតាមលក្ខណៈពិសេសនៃតំបន់ភូមិសាស្ត្រនីមួយៗដែលទាមទារឱ្យមានការគិតគូរនិងរៀបចំកសាងឡើងជាបន្ទាន់នូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជាប្រព័ន្ធគមនាគមន៍និងដឹកជញ្ជូន ថាមពលនិងអគ្គិសនី សុខភាព ទឹកស្អាត សំណល់រឹងនិងរាវ ការគ្រប់គ្រងគ្រោះមហន្តរាយ និងការការពារប្រព័ន្ធអេកូឡូស៊ីនិងធនធានធម្មជាតិ។ល។

ខេត្តព្រះវិហារមានទីតាំងស្ថិតនៅភាគខាងជើងនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយប្រវែង៣០០គីឡូម៉ែត្រពីរាជធានីភ្នំពេញតាមផ្លូវជាតិលេខ៦និងផ្លូវជាតិលេខ៦២ និងមានព្រំប្រទល់ខាងជើងជាប់ប្រទេសថៃនិងប្រទេសឡាវ ខាងត្បូងជាប់ខេត្តកំពង់ធំ ខាងកើតជាប់ខេត្តស្ទឹងត្រែង និងខាងលិចជាប់ខេត្តសៀមរាបនិងខេត្តឧត្តរមានជ័យ ព្រមទាំងទន្លេមេគង្គប្រវែងប្រមាណ២៤គីឡូម៉ែត្រដែលហូរកាត់ស្រុកឆែប និងស្ទឹងសែនប្រវែងប្រមាណ២១៣គីឡូម៉ែត្រដែលហូរកាត់ដោយមានប្រភពមកពីជួរភ្នំដងរែក។ ខេត្តព្រះវិហារមានច្រកទ្វារភាគីអានសេះ កម្ពុជា-ថៃ និងចំណុចប្រសព្វមុំបី កម្ពុជា-ឡាវ-ថៃ។ ខេត្តព្រះវិហារជាខេត្តដែលសម្បូរសម្បត្តិបេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រ សាសនា និងធនធានធម្មជាតិពិសិដ្ឋ ដូចជាប្រាសាទព្រះវិហារដែលជាសម្បត្តិបេតិកភណ្ឌពិភពលោក ប្រាសាទ

កោះកេរ ប្រាសាទព្រះខ័នកំពង់ស្វាយ និងប្រាសាទវប្បធម៌ប្រវត្តិសាស្ត្រដែលបានរកឃើញចំនួន២៨៥ បេតិកភណ្ឌធម្មជាតិភ្នំត្បែង តំបន់អភិរក្សគូលែនព្រហ្មទេព ដែនជម្រកសត្វព្រៃបឹងពែរ ឧទ្យានជាតិឫស្សីត្រើបតេជោសែន (កន្លែងស្លរដែកបុរាណ) ទឹកជ្រោះព្រះនិម្មិតទន្លេមេគង្គលើ ទឹកធ្លាក់កំពូលភ្នំត្បែង បឹងទំនប់៩៥ តំបន់អភិរក្សព្រៃព្រះរការដែប តំបន់អភិរក្សព្រៃឡង់ តំបន់ការពារទេសភាពធម្មជាតិភ្នំដងរែក ទន្លេល្ពៅដែលជាព្រំប្រទល់ប្រទេសកម្ពុជា- ឡាវ ស្ទឹងសែនដែលមានប្រភពពីភ្នំដងរែកហូរចូលបឹងទន្លេសាប រ៉ែដែក រ៉ែមាស ព្រៃឈើ សត្វព្រៃ ស្ទឹង បឹងបួ អូរ មច្ឆជាតិ រ៉ែ ដីមានជីជាតិសម្រាប់ដំណាំកសិឧស្សាហកម្ម និងជាគោលដៅទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ សាសនា និងធម្មជាតិប្រកបដោយសក្តានុពលទាក់ទាញ។ តំបន់ធនធានធម្មជាតិត្រូវការពារ ដូចជាតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង តំបន់ការពារទេសភាពព្រះវិហារ តំបន់ដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព តំបន់ដែនជម្រកសត្វព្រៃដែប តំបន់ដែនជម្រកសត្វព្រៃរការ និងតំបន់ដែនជម្រកសត្វព្រៃព្រៃឡង់ ដែលជាសក្តានុពលធម្មជាតិដ៏មានតម្លៃរបស់ជាតិ។ សក្តានុពលទាំងអស់នេះបានធ្វើឱ្យខេត្តព្រះវិហារមានការអភិវឌ្ឍរីកចម្រើនយ៉ាងឆាប់រហ័សស្ទើរគ្រប់វិស័យ ដូចជាហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សំណង់ ថាមពល សេដ្ឋកិច្ច ពាណិជ្ជកម្ម សេវាកម្ម ទេសចរណ៍ សង្គមកិច្ចការពារបរិស្ថាន និងការលើកកម្ពស់វប្បធម៌ប្រវត្តិសាស្ត្រ។

ក្រុងព្រះវិហារ មានចម្ងាយ៣០០គីឡូម៉ែត្រពីរាជធានីភ្នំពេញតាមផ្លូវជាតិលេខ៦និងផ្លូវជាតិលេខ៦២ មានចំនួន២សង្កាត់គឺសង្កាត់កំពង់ប្រណាកនិងសង្កាត់ប៉ាលហាល មានចំនួន២១ភូមិ និងមានផ្ទៃដីប្រមាណ២២ ០៦៣,២៩ ហិកតា។ ក្រុងព្រះវិហារជាតំបន់ស្នូលនគរូបនីយកម្មនៃខេត្តព្រះវិហារ មានសក្តានុពលដែលគាំទ្រដល់ការរស់នៅ ការធ្វើដំណើរ ការប្រកបការងារ និងការលម្ហែកម្សាន្ត។ ក្រុងព្រះវិហារជាមជ្ឈមណ្ឌលរដ្ឋបាល សេដ្ឋកិច្ច ទេសចរណ៍ សង្គមកិច្ច និងវប្បធម៌ នៃខេត្តព្រះវិហារ ដែលមានប្រព័ន្ធទំនាក់ទំនងដ៏ល្អប្រសើរជាមួយខេត្តជុំវិញនិងបណ្តាស្រុកដទៃទៀតទូទាំងខេត្តព្រះវិហារ។

ក្នុងគោលបំណងធានាការគ្រប់គ្រងនិងការអភិវឌ្ឍក្រុងព្រះវិហារប្រកបដោយចីរភាពនិងបរិយាបន្ន គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះវិហារដែលមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះវិហារជាសេនាធិការ បានដឹកនាំគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងព្រះវិហារដែលមានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុងព្រះវិហារជាសេនាធិការក្រោមការគាំទ្របច្ចេកទេសដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានរៀបចំប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារ ចក្ខុវិស័យឆ្នាំ២០៤០ ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រងនិងតម្រង់ទិសការអភិវឌ្ឍដែនដីក្រុងព្រះវិហារ ស្របតាមចក្ខុវិស័យគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងគោលនយោបាយតាមវិស័យសំខាន់ៗជាច្រើនទៀត។

ប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារ ត្រូវបានកសាងឡើងដោយមានការសិក្សាច្បាស់លាស់លើកត្តាភូមិសាស្ត្រ ប្រជាសាស្ត្រ សង្គមកិច្ច សេដ្ឋកិច្ច បរិស្ថាន ទេសចរណ៍ និងវប្បធម៌ ព្រមទាំងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំដែនដីនិងនគរូបនីយកម្ម មានជាអាទិ៍គោលនយោបាយដីធ្លី "**សៀវភៅសដីធ្លី**" គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយជាតិស្តីពីលំនៅឋាន ច្បាប់ភូមិបាល ច្បាប់ស្តីពីសំណង់ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពី

អស្សាមិករណ៍ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យស្តីពីការគ្រប់គ្រងអាងទន្លេ អនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ព្រះរាជក្រឹត្យស្តីពីការបង្កើតដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព អនុក្រឹត្យស្តីពីការបង្កើតតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង អនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ និងសេចក្តីសម្រេចស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ចក្ខុវិស័យនៃប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារមានលក្ខណៈទូលំទូលាយ គ្របដណ្តប់ទាំងទិដ្ឋភាពគតិយុត្ត និងបច្ចេកទេសសម្រាប់ធ្វើការសម្របសម្រួលរវាងវិស័យនានាដែលជាកម្លាំងចលករសេដ្ឋកិច្ច សំដៅធ្វើការតម្រង់ទិសការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន ឆ្លើយតបទៅនឹងកំណើនប្រជាសាស្ត្រ តម្រូវការក្នុងការប្រើប្រាស់ដី ការអភិវឌ្ឍលំនៅឋាន និងការអភិវឌ្ឍគ្រប់វិស័យក្នុងពេលបច្ចុប្បន្ននិងទៅអនាគត ដោយធានាបាននូវការការពារធនធានដី ធនធានទឹក ទឹកក្រោមដី ប្រព័ន្ធអេកូឡូស៊ី បរិស្ថាន និងធនធានធម្មជាតិដែលអាចធ្វើការអភិវឌ្ឍឱ្យមានសណ្តាប់ធ្នាប់ របៀបរៀបរយ សោភណភាព ចីរភាព និងចូលរួមបង្ការទប់ស្កាត់ការប្រែប្រួលអាកាសធាតុ ដូចជាការបំភាយឧស្ម័នផ្ទះកញ្ចក់ ការកើនឡើងនៃកម្តៅ ទឹកជំនន់ និងខ្យល់ព្យុះជាដើម។

## ២-ក្របខ័ណ្ឌសង្គម-សេដ្ឋកិច្ច និងចក្ខុវិស័យ

### ២.១-ក្របខ័ណ្ឌសង្គម-សេដ្ឋកិច្ច

ប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារត្រូវបានរៀបចំឡើងដោយបានសិក្សា ប្រមូល និងវិភាគទិន្នន័យប្រជាសាស្ត្រ ទិន្នន័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ទិន្នន័យសង្គម ទិន្នន័យសេដ្ឋកិច្ច ទិន្នន័យបរិស្ថាន និងការស្រង់មតិសមស្របតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយដីធ្លី "**សៀវភៅសដីធ្លី**" ច្បាប់ស្តីពីសំណង់ អនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងសេចក្តីសម្រេចស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

ដើម្បីកំណត់ចក្ខុវិស័យប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារដល់ឆ្នាំ២០៤០ ក្របខ័ណ្ឌសង្គម-សេដ្ឋកិច្ចត្រូវបានសិក្សាវិភាគតាមបែបវិទ្យាសាស្ត្រដោយផ្អែកតាមលទ្ធផលនៃជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨ និងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩។ តាមរយៈការសិក្សាខាងលើនេះ ក្រុងព្រះវិហារមានផ្ទៃដី២២ ០៦៣,២៩ហិកតា ប្រជាជននៅឆ្នាំ២០០៨ មានចំនួន២១ ៧៧៩នាក់ និងនៅឆ្នាំ២០១៩ មានចំនួន២៤ ៣៦០នាក់ ហើយតាមការព្យាករនៅឆ្នាំ២០៤០ ប្រជាជននឹងកើនឡើងដល់ចំនួន៣៧ ៦៧៩នាក់ ផ្អែកតាមការគណនាអត្រាកំណើនប្រចាំឆ្នាំ។ ជាមួយគ្នានេះ ការបែងចែកកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចសម្រាប់ក្រុងព្រះវិហារនៅឆ្នាំ២០១៩ ប្រជាជនដែលធ្វើការក្នុងវិស័យកសិកម្មមានចំនួន៤ ២៣៥នាក់ស្មើនឹង៣៥,០០% វិស័យឧស្សាហកម្មធុនស្រាលដែលជាសិប្បកម្មមានចំនួន១ ៣៣១នាក់ស្មើនឹង១១,០០% និងវិស័យសេវាកម្មមានចំនួន៦ ៥៣៥នាក់ស្មើនឹង៥៤,០០% ហើយរំពឹងថា នៅឆ្នាំ២០៤០ ប្រជាជនដែលធ្វើការក្នុងវិស័យកសិកម្មនឹងថយចុះមកត្រឹមចំនួន៣ ៣៩១នាក់ស្មើនឹង២០,០០% វិស័យឧស្សាហកម្មធុនស្រាលដែលជាសិប្បកម្មនឹងកើនឡើងដល់ចំនួន៤ ២៣៩នាក់ស្មើនឹង២៥,០០% និងវិស័យសេវាកម្មនឹងកើនឡើងដល់ចំនួន៩ ៣២៥នាក់ស្មើនឹង៥៥,០០%។

### ២.២-ចក្ខុវិស័យ

ចក្ខុវិស័យដល់ឆ្នាំ២០៤០ នៃប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារគឺសំដៅរៀបចំ អភិរក្ស និងអភិវឌ្ឍក្រុងព្រះវិហារជា “**មជ្ឈមណ្ឌលពហុសេវាកម្មប្រពៃនៃតំបន់បេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រពិភពលោក និងតំបន់បេតិកភណ្ឌធម្មជាតិពិសិដ្ឋ និងជាមជ្ឈមណ្ឌលទេសចរណ៍ ធុរកិច្ច និងកសិឧស្សាហកម្ម ប្រកបដោយសុខដុមរមនា**” តាមរយៈការរៀបចំនិងការជំរុញ: ១) គ្រប់គ្រង ការពារ និងអភិរក្ស បេតិកភណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រ ធនធានធម្មជាតិ និងបរិស្ថាន ប្រកបដោយប្រសិទ្ធភាព ចីរភាព និងបរិយាបន្ន ២) ស្តារនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការអភិវឌ្ឍ ការប្រើប្រាស់ដី និងនគរូបនីយកម្ម ប្រកបដោយជីវភាពនិងសុខដុមរមនា ៣) អភិវឌ្ឍធុរកិច្ច សេវាកម្ម និងផលិតផលទេសចរណ៍សម្បូរបែប ប្រកបដោយគុណភាពនិងភាពទាក់ទាញ ដែលភ្ញៀវទេសចរមានអារម្មណ៍ជិតស្និតទៅនឹងប្រវត្តិសាស្ត្រ វប្បធម៌ខ្មែរ និងធម្មជាតិ ៤) អភិវឌ្ឍកសិកម្មនិងឧស្សាហកម្ម ប្រកបដោយគុណភាព និង ៥) លើកកម្ពស់អភិបាលកិច្ចល្អ សេដ្ឋកិច្ចនិងសង្គមឌីជីថល និងអភិវឌ្ឍមូលធនមនុស្ស កិច្ចការពារសន្តិសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈល្អប្រសើរ។

## ៣-គោលបំណងនិងគោលដៅ

ដើម្បីសម្រេចចក្ខុវិស័យខាងលើ ប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារមានគោលបំណងនិងគោលដៅដូចខាងក្រោម៖

### ៣.១-គោលបំណង

ប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារមានគោលបំណងធានាសមាហរណកម្មនៃការអភិវឌ្ឍនិងការអភិរក្សនគរូបនីយកម្ម ការប្រើប្រាស់ដីនិងសក្តានុពលដែលមានស្រាប់ឱ្យបានត្រឹមត្រូវនិងចំទិសដៅប្រកបដោយភាពឆ្លាតគុណភាព តុល្យភាព ចីរភាព និងបរិយាបន្នតាមរយៈការគ្រប់គ្រងនិងអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាពខ្ពស់។

### ៣.២-គោលដៅ

ប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារមានគោលដៅដូចខាងក្រោម៖

- គ្រប់គ្រងការប្រើប្រាស់ដីនិងការប្រើប្រាស់សក្តានុពលធម្មជាតិនិងនគរូបនីយកម្មស្របទៅនឹងតំបន់លំនៅឋាន សេដ្ឋកិច្ច ពាណិជ្ជកម្ម វប្បធម៌ រដ្ឋបាល និងសេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ចីរភាព តុល្យភាព និងស្របតាមលក្ខណៈពិសេសនៃតំបន់នីមួយៗ
- ជំរុញកំណើនសេដ្ឋកិច្ចនិងអភិវឌ្ឍធុរកិច្ចទាក់ទាញគាំទ្រដល់ការវិនិយោគសាធារណៈនិងឯកជនដើម្បីសមធម៌សង្គមនិងផ្តល់ការងារ
- ធ្វើសមាហរណកម្មផែនការរូបវន្ត សង្គម សេដ្ឋកិច្ច វប្បធម៌ បរិស្ថាន និងផែនការតាមវិស័យ ដើម្បីធានាភាពសុខដុមរមនាសង្គមនិងការអភិវឌ្ឍប្រកបដោយចីរភាព
- លើកកម្ពស់បេតិកភណ្ឌ ធនធានធម្មជាតិ កិច្ចការពារបរិស្ថាន ការអភិវឌ្ឍបៃតង និងបង្ការទប់ស្កាត់គ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព
- លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការកែលម្អ ការអភិវឌ្ឍ និងការការពារហេដ្ឋារចនាសម្ព័ន្ធ
- ដោះស្រាយនិងឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ប្រជាជន។

## ៤-យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្សប្រកបដោយភាពឆ្លាត ចីរភាព និងបរិយាបន្ន

ដើម្បីសម្រេចបានចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ ប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារបានកំណត់យុទ្ធសាស្ត្រគ្រប់គ្រង អភិបាលកិច្ច និងការធ្វើសមាហរណកម្មការអភិវឌ្ឍនិងការអភិរក្សប្រកបដោយប្រសិទ្ធភាព ចីរភាព តុល្យភាព និងសមធម៌ដូចខាងក្រោម៖

### ៤.១-យុទ្ធសាស្ត្រអភិវឌ្ឍនគរូបនីយកម្ម

#### ៤.១.១-តំបន់នគរូបនីយកម្មបច្ចុប្បន្ន

ដើម្បីជំរុញការគ្រប់គ្រងនិងការកែលម្អតំបន់នគរូបនីយកម្មបច្ចុប្បន្នរបស់ក្រុងសម្រាប់ការរស់នៅប្រកបដោយសុខុមាលភាព ត្រូវអនុវត្តដូចខាងក្រោម៖

- បន្តជំរុញដាក់ឈ្មោះឬលេខផ្លូវនិងលេខផ្ទះ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងរដ្ឋបាលនិងប្រៃសណីយ៍
- កែលម្អនិងស្តារសួនច្បារតាមបណ្តោយទាំងសងខាងស្ទឹងសែន បឹងទំនប់៩៥ អូរ ផ្លូវ និងភ្លើងបំភ្លឺឱ្យមានសោភណភាព គុណភាពបរិស្ថានល្អ និងសកម្មភាពរស់រវើកទាំងពេលយប់និងពេលថ្ងៃ និងការពារទេសភាពធម្មជាតិស្ទឹង ភ្នំ និងតំបន់កសិកម្ម
- ការពារ កែលម្អ ស្តារ និងកសាងខឿនទប់ការបាក់ច្រាំងទាំងសងខាងនៃស្ទឹងសែន
- ចុះកំណត់និយាមកានិងបោះបង្គោលព្រំការពារដីចំណីស្ទឹងសែន បឹងទំនប់៩៥ និងតំបន់ធនធានទឹកនានា
- កែលម្អនិងស្តារកំណាត់ផ្លូវជាតិលេខ៦២និងកំណាត់ផ្លូវជាតិលេខ៩ ក្នុងទីក្រុង ផ្លូវក្រវាត់ក្រុង និងនៅតាមចិញ្ចើមផ្លូវ កំណត់ប្រភេទដើមឈើនិងដាំដើមឈើលម្អតាមដងផ្លូវ រៀបចំសួនតាមបណ្តោយផ្លូវ ភ្លើងបំភ្លឺផ្លូវឆ្លាត ផ្លាកនិងគំនូសសញ្ញាចរាចរណ៍ ផ្លាកផ្សព្វផ្សាយពាណិជ្ជកម្ម ឱ្យមានសោភណភាព សណ្តាប់ធ្នាប់ គុណភាព និងបរិស្ថាន សមស្របជាខ្លោងនិងអ័ក្សមេ នៃទីក្រុង
- កែលម្អនិងរៀបចំមហាវិថី វិថី អនុវិថី ផ្លូវដឹកជញ្ជូនសំខាន់ៗ ផ្លូវថ្មើរជើង ផ្លូវសម្រាប់ជនមានពិការភាព បណ្តាញផ្លូវ គន្លងផ្លូវទោចក្រយាន ចិញ្ចើមផ្លូវ លម្អសាធារណៈនិងដាំដើមឈើ រៀបចំសួនសាធារណៈនិងសួនកុមារ ទីលានកីឡា កន្លែងកម្សាន្ត អភិវឌ្ឍផ្ទៃបៃតង ក្នុងទីក្រុងស្របតាមតំបន់ប្រើប្រាស់ដីឱ្យមានសោភណភាព រស់រវើក សណ្តាប់ធ្នាប់ល្អ និងបរិស្ថានរស់នៅប្រកបដោយផាសុកភាពសម្រាប់មនុស្សទាំងអស់គ្នា
- កំណត់តំបន់ដែលត្រូវរៀបចំកែលម្អទីក្រុង កែលម្អនិងស្តារបណ្តាញហេដ្ឋារចនាសម្ព័ន្ធ រួមមានបណ្តាញផ្លូវ បណ្តាញទឹកស្អាត បណ្តាញអគ្គិសនី បណ្តាញប្រឡាយ និងការប្រមូលសំណល់រឹងនិងរាវឱ្យមានលក្ខណៈសមស្របនិងមានគុណភាព ដើម្បីលើកកម្ពស់គុណភាពរស់នៅនិងសោភណភាពក្រុង
- កំណត់តំបន់អភិវឌ្ឍទីក្រុងឡើងវិញ ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធ បង្កើនលទ្ធភាពនៃការប្រើប្រាស់ដី លើកកម្ពស់គុណភាពបរិស្ថាននៃការរស់នៅ និងទាក់ទាញការវិនិយោគ

- គ្រប់គ្រងសំណង់ រៀបចំ និងកំណត់ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន សោភណភាពនិងពណ៌សមស្រប និងរបងដីឡូត៍ឱ្យមានសោភណភាពល្អស្របតាមទីតាំងភូមិសាស្ត្រ មជ្ឈមណ្ឌលវប្បធម៌ សន្តិសុខ សេដ្ឋកិច្ច និងសង្គម
- រៀបចំផែនការប្រើប្រាស់ដីដោយកំណត់បទប្បញ្ញត្តិនៃការប្រើប្រាស់ដី ការអភិវឌ្ឍ ការសាងសង់ និងរៀបចំប្លង់លម្អិតនគរូបនីយកម្មតាមតំបន់នីមួយៗ។

### ៤.១.២- ទិសដៅនគរូបនីយកម្ម

អភិវឌ្ឍនគរូបនីយកម្មជាតំបន់ស្នូលអភិវឌ្ឍនៃខេត្តព្រះវិហារសម្រាប់រដ្ឋបាល វប្បធម៌ សេដ្ឋកិច្ច ពាណិជ្ជកម្ម និងទេសចរណ៍ប្រកបដោយគុណភាពបរិស្ថានរស់នៅល្អប្រសើរ ភាពសុខដុមរមនា ភាពឆ្លាត ចីរភាព និងបរិយាបន្ន ដោយៈ

- កំណត់ទិន្នាការនៃការអភិវឌ្ឍទីក្រុងនិងនគរូបនីយកម្មមានលទ្ធភាពពង្រីកឆ្ពោះទៅតំបន់ភាគខាងជើងក្រុងបច្ចុប្បន្ន តាមបណ្តោយផ្លូវជាតិលេខ៩ ក្នុងសង្កាត់កំពង់ប្រណាក និងតំបន់ភាគខាងត្បូង និងខាងកើតក្រុងបច្ចុប្បន្ន ក្នុងសង្កាត់ប៉ាលហាល ហើយត្រូវស្ថិតនៅខាងក្រៅតំបន់ដែនជម្រកសត្វព្រៃគូលែនព្រហ្មទេពនិងតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង
- គ្រប់គ្រងការអភិវឌ្ឍនិងការធ្វើសមាហរណកម្មការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រកបដោយប្រសិទ្ធភាព និងចីរភាពស្របតាមបទដ្ឋានបច្ចេកទេសនគរូបនីយកម្មនិងការអភិវឌ្ឍរូបវន្ត ជាពិសេសបណ្តាញផ្លូវ បណ្តាញអគ្គិសនី បណ្តាញទឹកស្អាត បណ្តាញលូប្រឡាយ អាងស្តុកទឹក និងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ និងចៀសវាងការសាងសង់មុនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- ពង្រឹងសមត្ថភាពគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះវិហារដែលមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះវិហារជាសេនាធិការ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងព្រះវិហារដែលមានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុងព្រះវិហារជាសេនាធិការ នៅក្នុងការគ្រប់គ្រងនិងអនុវត្តការងាររៀបចំដែនដីនិងនគរូបនីយកម្ម
- បន្តរៀបចំផែនការប្រើប្រាស់ដីនិងប្លង់លម្អិតនគរូបនីយកម្ម ដើម្បីធានាការគ្រប់គ្រង ការអភិវឌ្ឍ និងការអភិរក្សប្រកបដោយប្រសិទ្ធភាពនិងចីរភាព។

### ៤.១.៣- ការអភិវឌ្ឍទីក្រុងប្រកបដោយភាពឆ្លាត

ដើម្បីលើកកម្ពស់ដល់គុណភាពរស់នៅប្រកបដោយភាពងាយស្រួលក្នុងការទំនាក់ទំនងនិងសន្សំសំចៃ ឆ្លើយតបទៅនឹងតម្រូវការបច្ចុប្បន្ននិងអនាគត ប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារបានដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍទីក្រុងឆ្លាតតាមរយៈការគិតគូរនិងបំពាក់នូវបរិក្ខារនិងសេវាកម្មដូចខាងក្រោមៈ

- ជំរុញអភិវឌ្ឍក្រុងព្រះវិហារជាក្រុងឆ្លាតដោយផ្តោតលើវិស័យទូរគមនាគមន៍ ដឹកជញ្ជូនសាធារណៈ សន្តិសុខនិងសុវត្ថិភាព អភិវឌ្ឍទីក្រុង នគរូបនីយកម្មនិងសំណង់ ការប្រើប្រាស់ថាមពល ការគ្រប់គ្រងធនធានទឹក ការគ្រប់គ្រងសំណល់រឹងនិងរាវ ការគ្រប់គ្រងរដ្ឋបាលនិងផ្តល់សេវាសាធារណៈ ការបង្ការគ្រោះមហន្តរាយ ការគ្រប់គ្រងបរិស្ថាន និងវិស័យផ្សេងៗទៀតស្របតាមសក្តានុពលរបស់ក្រុង

- ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា ទូរគមនាគមន៍ និងបច្ចេកវិទ្យាទំនើប ដើម្បីជួយសម្រួលដល់ការអភិវឌ្ឍ ការផ្តល់សេវា ប្រតិបត្តិការទីក្រុង និងដំណោះស្រាយបញ្ហាទីក្រុង ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនិងការប្រកួតប្រជែង ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម បរិស្ថាន វប្បធម៌ដោយឆ្លើយតបនឹងតម្រូវការរបស់ប្រជាជនបច្ចុប្បន្ននិងធានាបានចីរភាពសម្រាប់អនាគត
- បច្ចេកវិទ្យាសម្រាប់ការផ្តល់សេវាកម្មនិងការអភិវឌ្ឍបរិក្ខារសំខាន់ៗក្នុងទីក្រុងឆ្លាតរួមមាន៖
  - សេវាអ៊ីនធឺណិតសាធារណៈ
  - មជ្ឈមណ្ឌលទិន្នន័យព័ត៌មានវិទ្យា
  - ប្រព័ន្ធដឹកជញ្ជូនសាធារណៈ
  - ចំណតយានយន្តឆ្លាត
  - ការសន្សំសំចៃថាមពលនិងការប្រើប្រាស់ថាមពលកកើតឡើងវិញ
  - សេវានិងប្រព័ន្ធឆ្លាតសម្រាប់ផ្គត់ផ្គង់ទឹកស្អាត
  - សេវានិងប្រព័ន្ធឆ្លាតសម្រាប់សន្តិសុខនិងសុវត្ថិភាព
  - ប្រព័ន្ធឆ្លាតក្នុងការជម្លៀសចេញពីគ្រោះមហន្តរាយ
  - ប្រព័ន្ធឆ្លាតសម្រាប់គ្រប់គ្រងនិងប្រព្រឹត្តិកម្មទឹកកខ្វក់និងសំណល់រាវ
  - ប្រព័ន្ធឆ្លាតសម្រាប់គ្រប់គ្រងសំណល់រឹង
  - ប្រព័ន្ធការពារធនធានធម្មជាតិនិងបរិស្ថាន សមាហរណកម្ម និងលម្អនគរូបនីយកម្មប្រកបដោយភាពសុខដុមរមនាជាមួយផ្ទៃទឹកនិងផ្ទៃបៃតង។
- ជំរុញប្រើប្រាស់បច្ចេកវិទ្យាឆ្លាតក្នុងការរចនា ការរៀបចំ ការអភិវឌ្ឍបៃតង និងការការពារបរិស្ថាននិងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព ចីរភាព និងការប្រកួតប្រជែង
- ប្រើប្រាស់បច្ចេកវិទ្យាឆ្លាតក្នុងការអភិវឌ្ឍក្រុងតាមរយៈការគ្រប់គ្រងនិងការលើកទឹកចិត្តដល់ការអភិវឌ្ឍសំណង់បៃតង ហេដ្ឋារចនាសម្ព័ន្ធបៃតង និងសេវាដឹកជញ្ជូនឆ្លាតដែលដំណើរការដោយបច្ចេកវិទ្យាទូរគមនាគមន៍ទំនើប
- ប្រើប្រាស់បច្ចេកវិទ្យាឆ្លាតក្នុងដំណើរការផលិត កែច្នៃ និងដឹកជញ្ជូនផលិតផលកសិកម្ម ឧស្សាហកម្មកែច្នៃ ពាណិជ្ជកម្ម និងទេសចរណ៍ ដើម្បីបង្កើនគុណភាពនិងបរិមាណសម្រាប់ការផ្គត់ផ្គង់តម្រូវការដល់ប្រជាជនក្នុងនិងក្រៅក្រុងឱ្យបានសមស្របនិងមានចីរភាព
- ជំរុញលើកស្ទួយដល់ការប្រកួតប្រជែងរបស់ទីក្រុងតាមរយៈការជំរុញលើកទឹកចិត្តដល់វិស័យឧស្សាហកម្មកែច្នៃនិងទេសចរណ៍ឱ្យប្រើប្រាស់បច្ចេកវិទ្យាឆ្លាត
- ជំរុញនិងលើកទឹកចិត្តដល់ការប្រើប្រាស់បច្ចេកវិទ្យាឆ្លាតនៅក្នុងវិស័យអប់រំ សុខាភិបាល សន្តិសុខនិងសណ្តាប់ធ្នាប់ ជាពិសេសការគ្រប់គ្រងនិងផ្តល់សេវាកម្មផ្សេងៗទាំងរដ្ឋនិងឯកជន។

### ៤.១.៤-ការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព

- ត្រូវធានានូវរាល់ការអភិវឌ្ឍនិងអភិរក្សទីក្រុងឱ្យទទួលបានចីរភាពខាងសង្គម សេដ្ឋកិច្ច បរិស្ថានវប្បធម៌ សន្តិសុខស្បៀង និងការពារសន្តិភាព

- ជំរុញនិងលើកទឹកចិត្តចំពោះការប្រើប្រាស់ប្រព័ន្ធដំណើរការថាមពលឆ្លាតដោយប្រើប្រាស់ថាមពលកកើតឡើងវិញ ដូចជាថាមពលពន្លឺព្រះអាទិត្យនិងថាមពលបានពីការកែច្នៃសំណល់រឹងនិងរាវ ក្នុងគោលបំណងកាត់បន្ថយជាអតិបរមាដល់ការប្រើប្រាស់ថាមពលដែលបានមកពីការប្រើប្រាស់ធនធានធម្មជាតិ
- ជំរុញនិងលើកទឹកចិត្តដល់ការរចនា ការរៀបចំ និងការអនុវត្តគម្រោងសាងសង់និងគម្រោងអភិវឌ្ឍនិងអភិរក្សទីក្រុងតាមគោលការណ៍អភិវឌ្ឍប្រកបដោយចីរភាព
- ជំរុញគ្រប់គ្រង ផ្គត់ផ្គង់ទឹកស្អាត និងកសាងប្រព័ន្ធកែច្នៃការប្រើប្រាស់ទឹកឡើងវិញ។

### ៤.១.៥-ការអភិវឌ្ឍទីក្រុងប្រកបដោយបរិយាបន្ន

- ត្រូវធានារាល់ការអភិវឌ្ឍនិងការអភិរក្សទីក្រុងសម្រាប់មនុស្សទាំងអស់គ្នាអាចទទួលបាននូវផលប្រយោជន៍ប្រកបដោយសមធម៌ រួមទាំងជនមានពិការភាពនិងជនងាយរងគ្រោះ
- កែលម្អបរិស្ថានទីក្រុងសម្រាប់ការរស់នៅប្រកបដោយសុវត្ថិភាពពីគ្រោះមហន្តរាយផ្សេងៗតាមរយៈការប្រើប្រាស់ប្រព័ន្ធបង្ការគ្រោះមហន្តរាយឆ្លាតនិងការកសាងផ្លូវនិងលម្ហសម្រាប់ការជម្លៀសចេញពីគ្រោះមហន្តរាយ
- ជំរុញគ្រប់គ្រងទីក្រុងប្រកបដោយប្រសិទ្ធភាពនិងមានការចូលរួមតាមរយៈការកសាងមជ្ឈមណ្ឌលប្រតិបត្តិដំណើរការសមាហរណកម្មមុខងាររបស់ទីក្រុង។

## ៤.២-យុទ្ធសាស្ត្រគ្រប់គ្រងនិងប្រើប្រាស់ដី

អនុលោមតាមអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ និងយោងតាមការកំណត់ព្រំប្រទល់រដ្ឋបាល ក្រុងព្រះវិហារត្រូវបានកំណត់ការប្រើប្រាស់ដីជាពីរប្រភេទគឺប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់។

### ៤.២.១-ប្រភេទដីអាចសាងសង់បាន

ក្រុងព្រះវិហារមានផ្ទៃដីសរុបប្រមាណ២២ ០៦៣,២៩ហិកតា ក្នុងនោះប្រភេទដីអាចសាងសង់បានមានផ្ទៃដីប្រមាណ៤ ៤៧០,៥៧ហិកតា ស្មើនឹង២០,២៦%នៃផ្ទៃដីសរុប។ ប្រភេទដីអាចសាងសង់បាន ត្រូវបានរៀបចំនិងបែងចែកជាតំបន់ដូចមានក្នុងផែនទីប្លង់គោលឧបសម្ព័ន្ធដូចខាងក្រោម៖

១) តំបន់លំនៅឋានមានផ្ទៃដីប្រមាណ១ ៩៤៩,៩៩ហិកតាស្មើនឹង៤៣,៥៧%នៃផ្ទៃដីអាចសាងសង់បាន ស្ថិតនៅសង្កាត់ទាំង២ នៃក្រុងព្រះវិហារ។ តំបន់លំនៅឋានត្រូវបានកំណត់បែងចែកបន្តជា៖

- តំបន់លំនៅឋានដាច់ពីគ្នាដែលមានកម្ពស់ទាបមានលំនៅឋានដាច់ពីគ្នា(ភូមិគ្រឹះទោល)និងលំនៅឋានពាក់កណ្តាលជាប់គ្នា(ភូមិគ្រឹះភ្លោះ) ស្ថិតនៅភូមិដំណាក់ ភូមិសំរោង ភូមិថ្មី និងភូមិគោកម្រែង ក្នុងសង្កាត់កំពង់ប្រណាក និងភូមិអភិវឌ្ឍន៍ ភូមិឯកភាព ភូមិស្មារ ភូមិប៉ាលហាល ភូមិសាមគ្គី ភូមិទីនប់ ភូមិហ្មសែត ភូមិអូរខ្លែងពង និងភូមិចំការស្រមូវ ក្នុងសង្កាត់ប៉ាលហាល។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់នេះត្រូវកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា១,៥
- ផ្លាតម្លាតអគារអប្បបរមាខាងមុខ៥ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង២,៥ម៉ែត្រ
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តិកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ផ្ទៃក្រឡាកម្រាលសំណង់៥០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១។

○ តំបន់លំនៅឋានជាប់គ្នាដែលមានកម្ពស់ទាបមានលំនៅឋានជាប់គ្នា(ផ្ទះល្វែង) ស្ថិតនៅភូមិសំរោង ភូមិថ្មី និងភូមិគោកបេង ក្នុងសង្កាត់កំពង់ប្រណាក និងភូមិប៉ាលហាល ភូមិភារកិច្ច ភូមិទំនប់ និងភូមិហ្សេត ក្នុងសង្កាត់ប៉ាលហាល។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់នេះត្រូវកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦៥%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា១,៥
- ផ្លាតម្លាតអគារអប្បបរមាខាងមុខ៥ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង២,៥ម៉ែត្រ។ ចំហៀងសងខាងត្រូវរក្សាគម្លាតឱ្យបានយ៉ាងតិច២ម៉ែត្រឬសាងសង់ដោយមានកិច្ចសន្យាជាប់ព្រំចំពោះផ្នែកដែលមិនជាប់ផ្លូវ
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តិកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ផ្ទៃក្រឡាកម្រាលសំណង់១០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១។

○ តំបន់លំនៅឋានដែលមានកម្ពស់មធ្យមមានលំនៅឋានដាច់ពីគ្នា(ភូមិគ្រឹះទោល) លំនៅឋានពាក់កណ្ដាលជាប់គ្នា(ភូមិគ្រឹះភ្លោះ) លំនៅឋានជាប់គ្នា(ផ្ទះល្វែង) អគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិ ស្ថិតនៅភូមិដំណាក់ ភូមិស្រះឈូក ភូមិសំរោង ភូមិថ្មី និងភូមិគោកបេង ក្នុងសង្កាត់កំពង់ប្រណាក និងភូមិស្លាពរ ភូមិប៉ាលហាល និងភូមិភារកិច្ច ក្នុងសង្កាត់ប៉ាលហាល។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់នេះត្រូវកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៣,០
- ធ្លាគម្លាតអគារៈ
  - អគារកម្ពស់ពី៤ដល់៨ជាន់ត្រូវកំណត់ធ្លាគម្លាតអគារអប្បបរមាផ្នែកខាងមុខ៥ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង២,៥ម៉ែត្រឬលើសពីនេះចេញពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី៩ដល់១១ជាន់ត្រូវកំណត់ធ្លាគម្លាតអគារអប្បបរមាផ្នែកខាងមុខ៦ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង៣ម៉ែត្រឬលើសពីនេះចេញពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់។
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តិកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ផ្ទៃក្រឡាកម្រាលសំណង់១០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១។

○ តំបន់លំនៅឋានដែលមានកម្ពស់ខ្ពស់មានអគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិ ស្ថិតនៅភូមិដំណាក់ ភូមិសំរោង និងភូមិកំពង់ចំលង ក្នុងសង្កាត់កំពង់ប្រណាក។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់នេះត្រូវកំណត់ៈ

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៤,០
- ធ្លាគម្លាតអគារៈ
  - អគារកម្ពស់ពី៤ដល់៨ជាន់ត្រូវកំណត់ធ្លាគម្លាតអគារអប្បបរមាផ្នែកខាងមុខ៥ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង២,៥ម៉ែត្រឬលើសពីនេះចេញពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី៩ដល់១១ជាន់ត្រូវកំណត់ធ្លាគម្លាតអគារអប្បបរមាផ្នែកខាងមុខ៦ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង៣ម៉ែត្រឬលើសពីនេះចេញពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់។
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តិកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ផ្ទៃក្រឡាកម្រាលសំណង់១០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១។

- តំបន់លំនៅឋានចម្រុះមានលំនៅឋានដាច់ពីគ្នា(ភូមិគ្រឹះទោល) លំនៅឋានពាក់កណ្ដាលជាប់គ្នា (ភូមិគ្រឹះភ្លោះ) លំនៅឋានជាប់គ្នា(ផ្ទះល្វែង) អគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិ ស្ថិតនៅភូមិកំពង់ចំលង ភូមិស្រះឈូក ភូមិឡឥដ្ឋ ភូមិសំរោង ភូមិថ្មី និងភូមិគោកបេង ក្នុងសង្កាត់កំពង់ប្រណាក និងភូមិភារកិច្ច ក្នុងសង្កាត់ប៉ាលហាល។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់នេះត្រូវកំណត់៖
  - ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%
  - សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៤,០
  - ផ្លាតម្លាតអគារ៖
    - អគារកម្ពស់ពី៤ដល់៨ជាន់ត្រូវកំណត់ផ្លាតម្លាតអគារអប្បបរមាផ្នែកខាងមុខ៥ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង២,៥ម៉ែត្រឬលើសពីនេះចេញពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
    - អគារកម្ពស់ពី៩ដល់១១ជាន់ត្រូវកំណត់ផ្លាតម្លាតអគារអប្បបរមាផ្នែកខាងមុខ៦ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង៣ម៉ែត្រឬលើសពីនេះចេញពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់។
  - សោភណភាពនិងពណ៌សមស្រប
  - ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
  - អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
  - អាងប្រព្រឹត្តិកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
  - ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
  - ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
  - ផ្ទៃក្រឡាកម្រាលសំណង់១០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១។

២) តំបន់ពាណិជ្ជកម្មមានផ្ទៃដីប្រមាណ៣៧,១១ហិកតាស្មើនឹង០,៨៣%នៃផ្ទៃដីអាចសាងសង់បាន ដែលត្រូវជំរុញអភិវឌ្ឍលម្ហសាធារណៈនិងផ្ទៃបៃតងឱ្យបានសមស្រប។ តំបន់ពាណិជ្ជកម្មត្រូវបានកំណត់បែងចែកបន្តជា៖

- តំបន់ពាណិជ្ជកម្មមានអគារសម្រាប់បម្រើដល់ពាណិជ្ជកម្ម ធុរកិច្ច និងសេវាកម្មនានា ដូចជាអគារការិយាល័យ ធនាគារ រោងកុន ភោជនីយដ្ឋាន ហាងលក់ដូរ ទីផ្សារ និងដេប៉ូចែកចាយទំនិញ ស្ថិតនៅផ្សារកំពង់ប្រណាកនិងតំបន់ជុំវិញផ្សារនេះ ក្នុងភូមិកណ្ដាលនិងភូមិឡឥដ្ឋ និងគម្រោងផ្សារថ្មីក្នុងភូមិកំពង់ចំលងនិងភូមិអណ្ដូងពោធ ក្នុងសង្កាត់កំពង់ប្រណាក។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់នេះត្រូវកំណត់៖
  - ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៧០%
  - សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៦,០
  - ផ្លាតម្លាតអគារ៖
    - អគារកម្ពស់ពី១ដល់៣ជាន់ត្រូវកំណត់ផ្លាតម្លាតអគារអប្បបរមាផ្នែកខាងមុខ៤ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង២ម៉ែត្រឬលើសពីនេះចេញពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់

- អគារកម្ពស់ពី៤ដល់៨ជាន់ត្រូវកំណត់ឆ្លាតម្លាតអគារអប្បបរមាផ្នែកខាងមុខ៥ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង២,៥ម៉ែត្រឬលើសពីនេះចេញពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
    - អគារកម្ពស់ពី៩ដល់១១ជាន់ត្រូវកំណត់ឆ្លាតម្លាតអគារអប្បបរមាផ្នែកខាងមុខ៦ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង៣ម៉ែត្រឬលើសពីនេះចេញពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់។
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តិកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១២០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ចំណតរថយន្តតូចៈ
    - ភោជនីយដ្ឋាននិងភេសជ្ជដ្ឋាន ផ្ទៃក្រឡាកម្រាលសំណង់១៥ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១ និងក្លឹបកម្សាន្ត ផ្ទៃក្រឡាកម្រាលសំណង់កន្លែងរាំ១ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
    - ផ្សារទំនើប ផ្ទៃក្រឡាកម្រាលសំណង់២៥ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
    - ផ្សារឬកន្លែងលក់ដូរ ផ្ទៃក្រឡាកម្រាលសំណង់៥០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
    - អគារពាណិជ្ជកម្មផ្សេងៗផ្ទៃក្រឡាកម្រាលសំណង់៥០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១។

○ តំបន់ពាណិជ្ជកម្មចម្រុះមានអគារពាណិជ្ជកម្មសម្រាប់បម្រើដល់លំនៅឋាននិងការរស់នៅ ដូចជាហាងលក់ដូរនិងទីផ្សារតូចៗ ស្ថិតនៅភូមិកណ្ដាល ភូមិឡឥដ្ឋ និងភូមិអណ្ដូងពោត ក្នុងសង្កាត់កំពង់ប្រណាក។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់នេះត្រូវកំណត់ៈ

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៧០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៤,០
- ឆ្លាតម្លាតអគារៈ
    - អគារកម្ពស់ពី១ដល់៣ជាន់ត្រូវកំណត់ឆ្លាតម្លាតអគារអប្បបរមាផ្នែកខាងមុខ៤ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង២ម៉ែត្រឬលើសពីនេះចេញពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
    - អគារកម្ពស់ពី៤ដល់៨ជាន់ត្រូវកំណត់ឆ្លាតម្លាតអគារអប្បបរមាផ្នែកខាងមុខ៥ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង២,៥ម៉ែត្រឬលើសពីនេះចេញពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់។
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន

- អាងប្រព្រឹត្តិកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១២០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិថែងផ្សេងពីនេះ
- ចំណតរថយន្តតូច៖
  - ភោជនីយដ្ឋាននិងភេសជ្ជដ្ឋាន ផ្ទៃក្រឡាកម្រាលសំណង់១៥ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១ និងក្លឹបកម្សាន្ត ផ្ទៃក្រឡាកម្រាលសំណង់កន្លែងរាំ១ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
  - ផ្សារឬកន្លែងលក់ដូរ ផ្ទៃក្រឡាកម្រាលសំណង់៥០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
  - អគារពាណិជ្ជកម្មផ្សេងៗផ្ទៃក្រឡាកម្រាលសំណង់៥០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១។

៣) តំបន់ឧស្សាហកម្មមានផ្ទៃដីប្រមាណ៧៤៨,១៦ហិកតាស្មើនឹង១៦,៧២%នៃផ្ទៃដីអាចសាងសង់បាន ស្ថិតនៅផ្នែកខ្លះក្បែរស្ទឹងសែននៃភូមិភារកិច្ច ក្នុងសង្កាត់ប៉ាលហាល និងភូមិគោកបេង ក្នុងសង្កាត់កំពង់ប្រណាក។ តំបន់ឧស្សាហកម្មសម្រាប់បម្រើដល់សិប្បកម្ម ការកែច្នៃផលិតផលកសិកម្ម រោងចក្រ និងផលិតកម្មផ្សេងៗ ដែលមានជាតិពុលតិចឬមធ្យម។ តំបន់នេះត្រូវយកចិត្តទុកដាក់ដោយធានាបាននូវបរិស្ថានល្អនិងរក្សាផ្ទៃបៃតងឱ្យបានសមស្រប។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់នេះត្រូវកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៣,០
- ថ្លាគម្លាតអគារអប្បបរមាខាងមុខ៥ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង២,៥ម៉ែត្រ
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តិកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិថែងផ្សេងពីនេះ
- ចំណតរថយន្តតូចនិងធំ៖
  - អគាររោងចក្រ ផ្ទៃក្រឡាកម្រាលសំណង់២៥០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១ និងផ្ទៃក្រឡាកម្រាលសំណង់១ ២៥០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តធំចំនួន១
  - អគារឃ្លាំងផ្ទុកទំនិញផ្ទាល់ខ្លួនផ្ទៃក្រឡាកម្រាលសំណង់៤០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១ និងផ្ទៃក្រឡាកម្រាលសំណង់២ ០០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តធំចំនួន១។

៤)តំបន់ចម្រុះមានផ្ទៃដីប្រមាណ៧១,២៨ហិកតាស្មើនឹង១,៥៩%នៃផ្ទៃដីអាចសាងសង់បាន ស្ថិតនៅចន្លោះផ្លូវម្លូព្រៃនិងផ្លូវកោះកេរ និងតំបន់ជុំវិញផ្សារកំពង់ប្រណាក នៃភូមិកណ្តាល ភូមិឡឥដ្ឋ ភូមិទួលទំនប់ ភូមិអណ្តូងពោត និងភូមិគោកបេង ក្នុងសង្កាត់កំពង់ប្រណាក និងភូមិស្លាពរ ក្នុងសង្កាត់ប៉ាលហាល។ តំបន់ចម្រុះសម្រាប់បម្រើដល់ពហុមុខងារដែលមានលំនៅឋាន ពាណិជ្ជកម្ម និងសេវាកម្ម ដោយធានាបានបរិស្ថានរស់នៅល្អ។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់នេះត្រូវកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦៥%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,០
- ថ្លាតម្លាតអគារ៖
  - អគារកម្ពស់ពី១ដល់៣ជាន់ត្រូវកំណត់ថ្លាតម្លាតអគារអប្បបរមាផ្នែកខាងមុខ៤ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង២ម៉ែត្រឬលើសពីនេះចេញពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី៤ដល់៨ជាន់ត្រូវកំណត់ថ្លាតម្លាតអគារអប្បបរមាផ្នែកខាងមុខ៥ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង២,៥ម៉ែត្រឬលើសពីនេះចេញពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី៩ដល់១១ជាន់ត្រូវកំណត់ថ្លាតម្លាតអគារអប្បបរមាផ្នែកខាងមុខ៦ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង៣ម៉ែត្រឬលើសពីនេះចេញពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់។
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តិកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១២០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះ
- ចំណតរថយន្តត្រូវកំណត់ទៅតាមការកំណត់ចំនួនចំណតរថយន្តរបស់ប្រភេទអគារនីមួយៗដែលបានកំណត់នៅក្នុងតំបន់ប្រើប្រាស់ដីនីមួយៗ។

៥)តំបន់ដឹកជញ្ជូនមានផ្ទៃដីប្រមាណ១ ០៥៧,១០ហិកតាស្មើនឹង២៣,៦២%នៃផ្ទៃដីអាចសាងសង់បាន ស្ថិតនៅសង្កាត់ទាំង២ នៃក្រុងព្រះវិហារ។ តំបន់ដឹកជញ្ជូនមានបណ្តាញផ្លូវ ផែស្ងួត ចំណតរថយន្តឈ្នួល ចំណតរថយន្តសាធារណៈ។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់នេះត្រូវកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា២,០
- ថ្លាតម្លាតអគារអប្បបរមាខាងមុខ៥ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង២,៥ម៉ែត្រ
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តិកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%

- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ផ្ទៃក្រឡាកម្រាលសំណង់១០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១និងផ្ទៃក្រឡាកម្រាលសំណង់៥០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តធំចំនួន១។

៦) តំបន់ទេសចរណ៍មានផ្ទៃដីប្រមាណ១០១,១៥ហិកតាស្មើនឹង២,២៦%នៃផ្ទៃដីអាចសាងសង់បាន ស្ថិតនៅចន្លោះតំបន់លំនៅឋាន តំបន់រដ្ឋបាលនិងសេវាសាធារណៈ និងតំបន់ចម្រុះ ផ្នែកខ្លះនៃភូមិគោកបេង ភូមិថ្មី ភូមិដំណាក់ ភូមិសំរោង និងភូមិកំពង់ចំលង ក្នុងសង្កាត់កំពង់ប្រណាក ព្រមទាំងតាមបណ្ដោយផ្លូវស្របដងស្ទឹងសែន ដោយមិនរួមបញ្ចូលផ្ទៃដីរមណីយដ្ឋានទេសចរណ៍និងកន្លែងកម្សាន្តទេសចរណ៍។ តំបន់ទេសចរណ៍ធម្មជាតិតាមដងស្ទឹងសែននិងតំបន់ទេសចរណ៍សេវាកម្មទីក្រុងត្រូវរក្សាផ្ទៃបៃតងឱ្យបានសមស្រប។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់នេះត្រូវកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,០
- ផ្លាតម្លាតអគារ៖
  - អគារកម្ពស់ពី១ដល់៣ជាន់ត្រូវកំណត់ផ្លាតម្លាតអគារអប្បបរមាផ្នែកខាងមុខ៤ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង២ម៉ែត្រឬលើសពីនេះចេញពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី៤ដល់៨ជាន់ត្រូវកំណត់ផ្លាតម្លាតអគារអប្បបរមាផ្នែកខាងមុខ៥ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង២,៥ម៉ែត្រឬលើសពីនេះចេញពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី៩ដល់១១ជាន់ត្រូវកំណត់ផ្លាតម្លាតអគារអប្បបរមាផ្នែកខាងមុខ៦ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង៣ម៉ែត្រឬលើសពីនេះចេញពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់។
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តិកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១២០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ចំណតរថយន្តតូចនិងធំ៖
  - អគារសណ្ឋាគារ ចំនួនបន្ទប់៥បន្ទប់ត្រូវមានចំណតរថយន្តតូចចំនួន១ និងចំនួនបន្ទប់៣០បន្ទប់ត្រូវមានចំណតរថយន្តធំចំនួន១
  - អគារផ្ទះសំណាក់ ចំនួនបន្ទប់១០បន្ទប់ត្រូវមានចំណតរថយន្តតូចចំនួន១ និងចំនួនបន្ទប់៣០បន្ទប់ត្រូវមានចំណតរថយន្តធំចំនួន១
  - អគារទេសចរណ៍ផ្សេងៗ ផ្ទៃក្រឡាកម្រាលសំណង់៥០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១។

៧) តំបន់រដ្ឋបាលនិងសេវាសាធារណៈមានផ្ទៃដីប្រមាណ១៣៥,៤១ហិកតាស្មើនឹង៣,០៣%នៃផ្ទៃដីអាចសាងសង់បាន ស្ថិតនៅប្រមូលផ្តុំក្នុងសង្កាត់កំពង់ប្រណាក និងនៅអតីតព្រលានយន្តហោះខេត្តព្រះវិហារក្នុងសង្កាត់ប៉ាលហាល ព្រមទាំងតំបន់គ្រោងថ្មីនៅភូមិកំពង់ចំលង ក្នុងសង្កាត់កំពង់ប្រណាក។ តំបន់នេះមានជាអាទិ៍សាលាខេត្ត សាលាក្រុង សាលាសង្កាត់ សាលាដំបូង មន្ទីរ អង្គភាព ស្នងការដ្ឋាន ទីបញ្ជាការដ្ឋាន អធិការដ្ឋាន សាលារៀន មន្ទីរពេទ្យ បណ្ណាល័យ សារមន្ទីរ មណ្ឌលសុខភាព ប៉ុស្តិ៍នគរបាល ប៉ុស្តិ៍ប្រៃសណីយ៍។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់នេះត្រូវកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,០
- ឆ្លាតម្លាតអគារ៖
  - អគារកម្ពស់ពី១ដល់៣ជាន់ត្រូវកំណត់ឆ្លាតម្លាតអគារអប្បបរមាផ្នែកខាងមុខ៤ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង២ម៉ែត្រឬលើសពីនេះចេញពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី៤ដល់៨ជាន់ត្រូវកំណត់ឆ្លាតម្លាតអគារអប្បបរមាផ្នែកខាងមុខ៥ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង២,៥ម៉ែត្រឬលើសពីនេះចេញពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់
  - អគារកម្ពស់ពី៩ដល់១១ជាន់ត្រូវកំណត់ឆ្លាតម្លាតអគារអប្បបរមាផ្នែកខាងមុខ៦ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង៣ម៉ែត្រឬលើសពីនេះចេញពីព្រំដីឡូត៍កាន់កាប់ស្របច្បាប់។
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តិកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ចំណតរថយន្តតូច៖
  - អគារគ្រឹះស្ថានឧត្តមសិក្សា ផ្ទៃក្រឡាកម្រាលសំណង់១០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
  - អគារគ្រឹះស្ថានមធ្យមសិក្សា ផ្ទៃក្រឡាកម្រាលសំណង់២០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
  - អគារគ្រឹះស្ថានបឋមសិក្សា ផ្ទៃក្រឡាកម្រាលសំណង់៣០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
  - អគារមជ្ឈមណ្ឌលកីឡា ផ្ទៃក្រឡាកម្រាលសំណង់១០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
  - អគារមន្ទីរពេទ្យ ផ្ទៃក្រឡាកម្រាលសំណង់១០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១

- ▪ អគារក្លឹបហាត់ប្រាណនិងសុខភាព ផ្ទៃក្រឡាកម្រាលសំណង់១២០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
- ▪ អគាររដ្ឋបាលនិងការិយាល័យផ្សេងៗ ផ្ទៃក្រឡាកម្រាលសំណង់១០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១។

- ត្រូវរៀបចំសម្រាប់មនុស្សទូទៅ រួមទាំងជនមានពិការភាពនិងជនងាយរងគ្រោះ។

៨) តំបន់លម្ហសាធារណៈនិងផ្ទៃបៃតងមានផ្ទៃដីប្រមាណ៣១៥,២៨ហិកតាស្មើនឹង៧,០៥%នៃផ្ទៃដីអាចសាងសង់បាន ស្ថិតនៅភូមិទំនប់ ភូមិភារកិច្ច និងភូមិប៉ាលហាល ក្នុងសង្កាត់ប៉ាលហាល និងភូមិកំពង់ចំលង ក្នុងសង្កាត់កំពង់ប្រណាក មានសួនច្បារតាមបណ្តោយដងស្ទឹងសែន សួនច្បារមុខសាលាខេត្ត សួនច្បារតាមបណ្តោយផ្លូវជាតិលេខ៦២និងផ្លូវជាតិលេខ៩ លម្ហសាធារណៈជុំវិញបឹងទំនប់៩៥។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់នេះត្រូវកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា១០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា០,១
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- សួនច្បារសាធារណៈនិងដាំដើមឈើកំណត់បង្ហាញអំពីអត្តសញ្ញាណទីតាំងភូមិសាស្ត្រ
- ត្រូវរៀបចំចំណតរថយន្តសម្រាប់សាធារណៈ
- ត្រូវរៀបចំសម្រាប់មនុស្សទូទៅ រួមទាំងជនមានពិការភាពនិងជនងាយរងគ្រោះ។

៩) តំបន់វប្បធម៌និងសាសនាមានផ្ទៃដីប្រមាណ១៣,៥៣ហិកតាស្មើនឹង០,៣០%នៃផ្ទៃដីអាចសាងសង់បាន ស្ថិតនៅសង្កាត់ទាំង២ នៃក្រុងព្រះវិហារ។ តំបន់នេះ មានជាអាទិ៍ប្រាសាទបុរាណ វត្តអារាមព្រះពុទ្ធសាសនា វិហារចិន វិហារអ៊ីស្លាម សាលាឆទាន ទីសក្ការបូជា ទួលអ្នកតា និងទីបញ្ចុះសព។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់នេះត្រូវកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា១,៥
- ផ្លាតម្លាតអគារអប្បបរមាខាងមុខ៦ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង៣ម៉ែត្រ
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- អាងបង្គន់អនាម័យស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- អាងប្រព្រឹត្តិកម្មទឹកកខ្វក់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិថែងផ្សេងពីនេះ
- ផ្ទៃក្រឡាកម្រាលសំណង់១០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១
- ត្រូវរៀបចំសម្រាប់មនុស្សទូទៅ រួមទាំងជនមានពិការភាពនិងជនងាយរងគ្រោះ។

១០)តំបន់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈមានផ្ទៃដីប្រមាណ៤៦,១៦ហិកតាស្មើនឹង១,០៣%នៃផ្ទៃដីអាចសាងសង់បាន មានគម្រោងស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ក្រុង ស្ថិតនៅភូមិសំរោងនិងភូមិកំពង់ចំលង ក្នុងសង្កាត់កំពង់ប្រណាក ស្ថានីយចម្រោះទឹកស្អាត ស្ថិតនៅភូមិដំណាក់ ក្នុងសង្កាត់កំពង់ប្រណាក គម្រោងស្ថានីយចម្រោះទឹកស្អាត ស្ថិតនៅភូមិទំនប់ ក្នុងសង្កាត់ប៉ាលហាល ទីលានទុកដាក់សំរាមបច្ចុប្បន្ននិងគម្រោងទីលានទុកដាក់សំរាម ស្ថិតនៅភូមិភារកិច្ចនិងភូមិហ្សសែត ក្នុងសង្កាត់ប៉ាលហាល។ បទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់នេះត្រូវកំណត់៖

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%
- សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា២,០
- ផ្លូតម្លាតអគារអប្បបរមាខាងមុខ៨ម៉ែត្រនិងខាងក្រោយនិងចំហៀងសងខាង៤ម៉ែត្រ
- សោភណភាពនិងពណ៌សមស្រប
- ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០%
- ផ្ទៃដីឡូត៍១០០ម៉ែត្រក្រឡាត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ
- ផ្ទៃក្រឡាកម្រាលសំណង់១០០ម៉ែត្រក្រឡាត្រូវមានចំណតរថយន្តតូចចំនួន១។

សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ សួនច្បារជ្រាបទឹក ដាំដើមឈើ ផ្លូវតម្រង់ ផ្លូតម្លាត កម្ពស់សំណង់ ចំណតរថយន្ត អាងបង្គន់អនាម័យ អាងប្រព្រឹត្តិកម្មទឹកកខ្វក់ ពណ៌អគារ សោភណភាព និងរចនាបថស្ថាបត្យកម្មខ្មែរនិង/ឬលក្ខណៈធម្មជាតិនៃតំបន់នីមួយៗដូចបានកំណត់ខាងលើត្រូវអនុវត្តឱ្យបានត្រឹមត្រូវស្របតាមបទប្បញ្ញត្តិជាធរមាន។

គម្រោងអភិវឌ្ឍនិងសាងសង់ក្នុងប្រភេទដីនេះតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ជាមុន ស្របតាមច្បាប់ស្តីពីសំណង់ អនុក្រឹត្យលេខ២២៤អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងប្រកាសលេខ២១៧ ប្រក.ដ.ន.ស. ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធានគណនាសន្ទស្សន៍ប្រើប្រាស់ដី។

### ៤.២.២-ប្រភេទដីកម្រិតការសាងសង់

ប្រភេទដីកម្រិតការសាងសង់មានផ្ទៃដីប្រមាណ១៧ ៥៩២,៧២ហិកតាស្មើនឹង៧៩,៧៤%នៃផ្ទៃដីសរុប។ ប្រភេទដីកម្រិតការសាងសង់ ត្រូវបានរៀបចំនិងបែងចែកជាតំបន់ដូចមានក្នុងផែនទីប្លង់គោលឧបសម្ព័ន្ធដូចខាងក្រោម៖

១)តំបន់កសិកម្មមានផ្ទៃដីប្រមាណ១២ ៦១៨,១៧ហិកតាស្មើនឹង៧១,៦៧%នៃផ្ទៃដីកម្រិតការសាងសង់។ តំបន់កសិកម្មត្រូវបានកំណត់បែងចែកបន្តជា៖

○ តំបន់កសិកម្មជាចម្ការមានផ្ទៃដីប្រមាណ១១ ៦៤៥,២០ហិកតាស្មើនឹង៦៦,១៤%នៃផ្ទៃដីកម្រិតការសាងសង់ ស្ថិតនៅភូមិកំពង់ចំលងនិងភូមិដំណាក់ ក្នុងសង្កាត់កំពង់ប្រណាក និងភូមិអភិវឌ្ឍន៍ ភូមិស្ថាពរ ភូមិឯកភាព ភូមិប៉ាលហាល ភូមិសាមគ្គី ភូមិទំនប់ ភូមិភារកិច្ច ភូមិហ្វសែត ភូមិអូរខ្លែងព័រ និងភូមិចំការស្រម៉ូវ ក្នុងសង្កាត់ប៉ាលហាល។ តំបន់នេះមានដីចម្ការដំណាំរយៈពេលខ្លី មធ្យម និងវែង ជាពិសេសដំណាំកសិឧស្សាហកម្ម ដែលជាស្នូលសេដ្ឋកិច្ចរបស់ក្រុងនាថ្ងៃខាងមុខ រួមទាំងដីកសិកម្មនៅក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែនព្រហ្មទេពនិងតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង ក្នុងសង្កាត់ទាំង២។ តំបន់នេះត្រូវ៖

- រក្សាការពារផ្ទៃដីកសិកម្មដែលមានសក្តានុពលសម្រាប់ដំណាំ ដូចជាកៅស៊ូ ស្វាយចន្ទី ស្វាយ ចេក ល្ហុ ម្រេច សណ្តែកសៀង សណ្តែកបាយ សណ្តែកដី ដំឡូងមី អំពៅ និងវារីវប្បកម្ម ដោយអនុវត្តឱ្យបានត្រឹមត្រូវតាមប្លង់គោលប្រើប្រាស់ដី
- ពិនិត្យឱ្យបានច្បាស់លាស់និងត្រឹមត្រូវចំពោះសំណង់ផ្សេងៗ ការប្រើប្រាស់ជីគីមី ការប្រើប្រាស់ថ្នាំគីមីសម្លាប់សត្វល្អិតគ្រប់ប្រភេទ ដែលប្រើប្រាស់នៅតំបន់នេះ ដោយសារតំបន់នេះជាផ្ទៃរងទឹកភ្លៀងនិងហូរចូលទៅបឹងទំនប់៩៥ ដែលនឹងរៀបចំជាប្រភពទឹកស្អាតប្រើប្រាស់បន្ថែមលើប្រភពពីស្ទឹងសែន
- ធ្វើផែនការគ្រប់គ្រងដីកសិកម្មដោយកំណត់និងបែងចែកតំបន់សក្តានុពលកសិកម្មឱ្យបានច្បាស់លាស់ រួមមានតំបន់កសិកម្មភាគខាងជើង ខាងលិច និងខាងត្បូង នៃក្រុង
- អនុវត្តផែនការពង្រីកក្រុងឱ្យបានសមស្របក្នុងគោលបំណងកាត់បន្ថយផលប៉ះពាល់ជាអតិបរមាចំពោះតំបន់កសិកម្មដែលបានរក្សាការពារ។

○ តំបន់កសិកម្មដំណាំស្រូវមានផ្ទៃដីប្រមាណ៩៧២,៩៧ហិកតាស្មើនឹង៥,៥៣%នៃផ្ទៃដីកម្រិតការសាងសង់ ស្ថិតនៅភូមិអភិវឌ្ឍន៍ ភូមិស្ថាពរ ភូមិឯកភាព ភូមិប៉ាលហាល ភូមិសាមគ្គី ភូមិទំនប់ និងភូមិហ្វសែត ក្នុងសង្កាត់ប៉ាលហាល។ តំបន់នេះត្រូវដាំស្រូវនិងអនុវត្តឱ្យបានច្រើនដងក្នុងមួយឆ្នាំ រួមជាមួយបច្ចេកទេសកសិកម្មទំនើប ដើម្បីទទួលបានទិន្នផលខ្ពស់សម្រាប់ទ្រទ្រង់សេដ្ឋកិច្ចក្រុងនិងប្រជាជន។ តំបន់នេះត្រូវ៖

- រក្សាការពារផ្ទៃដីកសិកម្មដែលមានសក្តានុពលសម្រាប់ដំណាំស្រូវ ដោយអនុវត្តឱ្យបានត្រឹមត្រូវតាមប្លង់គោលប្រើប្រាស់ដី
- ធ្វើផែនការគ្រប់គ្រងដីកសិកម្មដោយកំណត់និងបែងចែកតំបន់សក្តានុពលកសិកម្មឱ្យបានច្បាស់លាស់ រួមមានភាគខាងលិចក្រុង
- អនុវត្តផែនការពង្រីកក្រុងឱ្យបានសមស្របក្នុងគោលបំណងកាត់បន្ថយផលប៉ះពាល់ជាអតិបរមាចំពោះតំបន់កសិកម្មដែលបានរក្សាការពារ។

២) តំបន់ព្រៃឈើមានផ្ទៃដីប្រមាណ៤ ៤៣៨,២៥ហិកតាស្មើនឹង២៥,២១%នៃផ្ទៃដីកម្រិតការសាងសង់(បើធៀបជាមួយឆ្នាំ២០២០ តំបន់ព្រៃឈើមានផ្ទៃដីរហូតដល់៨ ៨៩៦,១៩ហិកតា) ស្ថិតនៅភូមិទំនប់និងភូមិអូរខ្លែងព័រ ក្នុងសង្កាត់ប៉ាលហាល ដែលគ្របដណ្តប់ស្ទើរទាំងស្រុងដោយតំបន់បេតិកភណ្ឌធម្មជាតិ

ភ្នំត្បែង និងមួយផ្នែកទៀតស្ថិតនៅភូមិឯកភាពនិងភូមិអភិវឌ្ឍន៍ ក្នុងសង្កាត់ប៉ាលហាល ដែលគ្របដណ្តប់ដោយដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព។ តំបន់នេះត្រូវអភិរក្សជាតំបន់ទ្រនាប់បៃតង តំបន់ទេសភាពផ្ទៃរងទឹកភ្លៀង និងតំបន់សម្រាប់រៀបចំជាអេកូទេសចរណ៍ធម្មជាតិ។

- តំបន់ដែនជម្រកសត្វព្រៃគូលែនព្រហ្មទេពដែលស្ថិតក្នុងព្រំប្រទល់រដ្ឋបាលក្រុងព្រះវិហារមានផ្ទៃដីប្រមាណ១ ៦០៤,៣៦ហិកតាស្មើនឹង៧,៣៣%នៃផ្ទៃដីក្រុង ស្ថិតនៅភូមិឯកភាព ភូមិអភិវឌ្ឍន៍ ភូមិស្គាពរ ក្នុងសង្កាត់ប៉ាលហាល និងនៅភូមិស្រះឈូក ភូមិដំណាក់ និងភូមិកំពង់ចំលង ក្នុងសង្កាត់កំពង់ប្រណាក។ តំបន់នេះមានរូបភាពប្រើប្រាស់ជាលំនៅឋាន ពាណិជ្ជកម្ម ទេសចរណ៍ រដ្ឋបាលនិងសេវាសាធារណៈ លម្ហសាធារណៈនិងផ្ទៃបៃតង កសិកម្ម ព្រៃឈើ និងធនធានទឹក ដោយពុំទាន់ត្រូវបានបែងចែកការគ្រប់គ្រងឱ្យអនុលោមតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិនៅឡើយទេ ជាក់ស្តែងតំបន់សហគមន៍បម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ចសង្គម នៃសហគមន៍ដែលមានសកម្មភាពស្រាប់ រួមមានលំនៅឋាន ស្រែ និងចម្ការ នៅក្នុងតំបន់នេះ។
- តំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែងដែលស្ថិតក្នុងព្រំប្រទល់រដ្ឋបាលក្រុងព្រះវិហារមានផ្ទៃដីប្រមាណ៣ ៤៧៧,៧៤ហិកតាស្មើនឹង១៥,៧៦ %នៃផ្ទៃដីក្រុង ស្ថិតនៅភូមិទំនប់និងភូមិអូរខ្លែងពរ ក្នុងសង្កាត់ប៉ាលហាល។ តំបន់នេះមានរូបភាពប្រើប្រាស់ជាកសិកម្ម ព្រៃឈើ និងធនធានទឹក ដោយមានរមណីយដ្ឋានទឹកធ្លាក់កំពូលភ្នំត្បែងនិងតំបន់សម្រាប់រៀបចំជាអេកូទេសចរណ៍ធម្មជាតិ។

៣) តំបន់ធនធានទឹកមានផ្ទៃដីប្រមាណ៥៤៩,៦៩ហិកតាស្មើនឹង៣,១២%នៃផ្ទៃដីកម្រិតការសាងសង់ ដែលគ្របដណ្តប់ផ្នែកខ្លះនៃសង្កាត់ទាំង២ រួមមានស្ទឹងសែន បឹងទំនប់៩៥ ត្រពាំង អូរ ប្រឡាយ និងបណ្តាញផ្លូវទឹក។ តំបន់នេះជាសក្តានុពលដ៏សំខាន់ដែលត្រូវស្តារ ការពារ និងថែរក្សា ដើម្បីប្រើប្រាស់សម្រាប់គាំទ្រដល់ការផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធរំដោះទឹកជំនន់ ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់តាមបែបធម្មជាតិ ផ្លូវទឹកស្រោចស្រពកសិកម្ម និងធនធានជលផល។

បទប្បញ្ញត្តិនៃការសាងសង់ក្នុងតំបន់កសិកម្មត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង០,៥ ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាស្មើនឹង១០% ផ្គតម្លាតអគារខាងមុខយ៉ាងតិច១០ម៉ែត្រ និងចំហៀងសងខាងនិងខាងក្រោយយ៉ាងតិចស្មើនឹងពាក់កណ្តាលគម្លាតអគារខាងមុខ កម្ពស់អគារអតិបរមាស្មើនឹង៨ម៉ែត្រ សួនច្បារដែលអាចជ្រាបទឹកនិងផ្ទៃបៃតងយ៉ាងតិច៦៥%នៃផ្ទៃដីដែលនៅសល់ពីការសាងសង់ និងដាំដើមឈើយ៉ាងតិច១ដើមសម្រាប់ផ្ទៃក្រឡាដីឡូត៍៤៩ម៉ែត្រក្រឡា។

គម្រោងអភិវឌ្ឍនិងសាងសង់ក្នុងប្រភេទដីកម្រិតការសាងសង់ តម្រូវឱ្យមានលិខិតអនុញ្ញាតអភិវឌ្ឍដីជាមុនស្របតាមអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។ មានតែតំបន់កសិកម្មប៉ុណ្ណោះដែលអាចអនុញ្ញាតឱ្យសាងសង់លំនៅឋានផ្ទាល់ខ្លួនបានដែលមិនមានលក្ខណៈអាជីវកម្មនិងអាចសាងសង់រោងសិប្បកម្មសម្រាប់គោលដៅកសិកម្មបានដោយមិនបាច់ធ្វើការកែប្រែទៅជាប្រភេទដីអាចសាងសង់បាន លើកលែងតែតំបន់ណាដែលមានលិខិតបទដ្ឋានគតិយុត្តកំណត់ដោយឡែក។

## ៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

ក្រុងព្រះវិហារ ជាក្រុងមាត់ទឹក អមជាមួយព្រៃឈើ ភ្នំ និងតំបន់ការពារទេសភាពដ៏ល្អ និងត្រូវបានហូរកាត់ដោយស្ទឹងសែន បែងចែកភូមិសាស្ត្រក្រុងជាពីរ ក្នុងនោះផ្នែកខាងជើងគឺភូមិកំពង់ចំលង ក្នុងសង្កាត់កំពង់ប្រណាក និងផ្នែកខាងត្បូងមានផ្នែកខ្លះនៃសង្កាត់កំពង់ប្រណាកនិងសង្កាត់ប៉ាលហាល ដោយមានព្រំប្រទល់ជាប់ស្រុកត្បែងមានជ័យ។ ស្ថានភាពភូមិសាស្ត្រនេះនាំឱ្យក្រុងមានផ្លូវជាតិសំខាន់ឆ្លងកាត់ចំនួន៣ គឺផ្លូវជាតិលេខ៦២ ផ្លូវជាតិលេខ៩ និងផ្លូវជាតិលេខ៦៤។ ផ្លូវជាតិលេខ៦៤ភ្ជាប់ពីខេត្តសៀមរាបមកស្រុកគូលែន ខេត្តព្រះវិហារនិងបន្តភ្ជាប់ជាមួយផ្លូវជាតិលេខ៦២ មកដល់ក្រុងព្រះវិហារ។ ផ្លូវជាតិលេខ៩ ឆ្លងកាត់ស្ទឹងសែនដោយស្ពានស្ទឹងសែនភ្ជាប់មកស្រុកត្បែងមានជ័យនិងស្រុកឆែប ខេត្តព្រះវិហារ និងបន្តភ្ជាប់ទៅខេត្តស្ទឹងត្រែង។ ផ្លូវជាតិលេខ៦២ ភ្ជាប់ជាមួយផ្លូវជាតិលេខ៩ ត្រង់ផ្នែកខាងជើងទីប្រជុំជនក្រុងដោយឆ្លងកាត់ក្រុងភ្ជាប់ទៅស្រុករវៀង ខេត្តព្រះវិហារ និងបន្តភ្ជាប់ទៅខេត្តកំពង់ធំនិងរាជធានីភ្នំពេញ។

ក្រុងព្រះវិហារត្រូវគិតគូរនិងយកចិត្តទុកដាក់ខ្ពស់លើការកែលម្អនិងអភិវឌ្ឍបណ្តាញផ្លូវថ្នល់ ផ្លូវទឹក ការគ្រប់គ្រងធនធានទឹកនិងការផ្គត់ផ្គង់ទឹកស្អាត ការផ្គត់ផ្គង់ថាមពលអគ្គិសនី ទូរគមនាគមន៍ បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធសង្គម ដើម្បីត្រៀមខ្លួនឆ្លើយតបនឹងតម្រូវការហេដ្ឋារចនាសម្ព័ន្ធនានា។

### ៤.៣.១-អ័ក្សអភិវឌ្ឍទេសចរណ៍-ពាណិជ្ជកម្ម តាមផ្លូវជាតិ និងច្រកទ្វារព្រំដែន

ផ្លូវជាតិលេខ៩ ផ្លូវជាតិលេខ៦២ និងផ្លូវជាតិលេខ៦៤ មានតួនាទីជាអ័ក្សអភិវឌ្ឍទេសចរណ៍-ពាណិជ្ជកម្ម ចាំបាច់ត្រូវពង្រីកទទឹងផ្លូវដែលមានស្រាប់ កែលម្អ និងធ្វើការសាងសង់ផ្លូវវាងក្រុងបន្ថែម ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការដឹកជញ្ជូននិងចរាចរណ៍។ ផ្លូវជាតិលេខ៩ ជាអ័ក្សអភិវឌ្ឍតំបន់ភាគខាងជើងនៃព្រះរាជាណាចក្រកម្ពុជា ភ្ជាប់ពីខេត្តព្រះវិហារទៅខេត្តស្ទឹងត្រែងនិងបន្តភ្ជាប់ទៅប្រទេសវៀតណាម និងផ្លូវជាតិលេខ៦២និងផ្លូវជាតិលេខ៦៤ ជាអ័ក្សអភិវឌ្ឍតំបន់ភាគខាងជើងនៃព្រះរាជាណាចក្រកម្ពុជា ភ្ជាប់ពីខេត្តព្រះវិហារ ជាពិសេសពីតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ រមណីយដ្ឋានប្រាសាទកោះកេរ ទៅខេត្តសៀមរាប ខេត្តកំពង់ធំ និងបន្តភ្ជាប់ទៅរាជធានីភ្នំពេញ ព្រមទាំងភ្ជាប់ពីក្រុងព្រះវិហារទៅប្រទេសថៃនិងប្រទេសឡាវ សម្រាប់ទេសចរណ៍ ពាណិជ្ជកម្ម និងការដឹកជញ្ជូនទំនិញ។

អភិវឌ្ឍច្រកទ្វារព្រំដែនទ្វេភាគីអានសេះ រវាងប្រទេសកម្ពុជានិងប្រទេសថៃនិងច្រកទ្វារព្រំដែនត្រីភាគី រវាងប្រទេសកម្ពុជា ប្រទេសថៃ និងប្រទេសឡាវ សម្រាប់កិច្ចសហការតាមព្រំដែន ការដោះដូរទំនិញ ការដឹកជញ្ជូន និងការធ្វើដំណើរ។ កែលម្អបណ្តាញផ្លូវនិងធ្វើឱ្យប្រសើរឡើងនូវមធ្យោបាយត្រួតពិនិត្យរបស់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីលើកកម្ពស់ការអភិវឌ្ឍទេសចរណ៍ ពាណិជ្ជកម្ម និងការដឹកជញ្ជូនទំនិញ តាមច្រកទ្វារព្រំដែនទ្វេភាគីនិងត្រីភាគី តាមខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង និងខេត្តរតនគីរី ឱ្យកាន់តែមានប្រសិទ្ធភាព។

### ៤.៣.២-ផ្លូវថ្នល់

- រៀបចំនិងកែលម្អកំណាត់ផ្លូវជាតិលេខ៩ និងកំណាត់ផ្លូវជាតិលេខ៦២ ឆ្លងកាត់ក្រុង ជាអ័ក្សអភិវឌ្ឍនគរូបនីយកម្ម ដើម្បីបញ្ចៀសការកកស្ទះចរាចរណ៍ កាត់បន្ថយពេលវេលាធ្វើដំណើរនិងដឹកជញ្ជូន និងកំណត់មុខងារជាមហាវិថីទេសចរណ៍

- ជំរុញកសាងផ្លូវវាងក្រុង ដើម្បីបញ្ចៀសរថយន្តដឹកទំនិញធុនធ្ងន់ចូលក្នុងក្រុង កាត់បន្ថយបញ្ហាកកស្ទះចរាចរណ៍និងគ្រោះថ្នាក់ចរាចរណ៍ លើកកម្ពស់បរិស្ថានក្រុង សណ្តាប់ធ្នាប់ក្រុង និងសោភណភាពក្រុង
- ជំរុញកសាងផ្លូវក្រវាត់ក្រុងភ្ជាប់ពីផ្លូវជាតិលេខ៦២ ភាគខាងលិចក្រុង តាមបណ្តោយទំនប់៩៥ មកភ្ជាប់ផ្លូវជាតិលេខ៦២វិញត្រង់ចំណុចខាងលើអតីតព្រលានយន្តហោះខេត្តព្រះវិហារ និងបន្តភ្ជាប់ទៅគម្រោងទំនប់ការពារទឹកលិចទំនប់រក្សា តាមបណ្តោយខាងលិចដងស្ទឹងសែនរហូតដល់ផ្លូវជាតិលេខ៩
- ជំរុញកសាងផ្លូវក្រវាត់ក្រុងភ្ជាប់ពីផ្លូវជាតិលេខ៩ ត្រង់ភូមិសាស្រ្តភូមិដំណាក់ ឆ្លងកាត់ស្ទឹងសែន តាមបណ្តោយព្រំប្រទល់ភូមិកំពង់ចំលង មកភ្ជាប់ផ្លូវជាតិលេខ៩វិញ និងបន្តឆ្លងកាត់ស្ទឹងសែនត្រង់ភូមិសាស្រ្តភូមិសំរោង ក្នុងសង្កាត់កំពង់ប្រណាក
- ជំរុញកសាងផ្លូវក្រវាត់ក្រុងភ្ជាប់ពីផ្លូវជាតិលេខ៦២ ភាគខាងលិចក្រុង មកភ្ជាប់ផ្លូវជាតិលេខ៦២វិញត្រង់ចំណុចរង្វង់មូល និងបន្តភ្ជាប់ទៅភាគខាងកើតក្រុង ដោយឆ្លងកាត់ស្ទឹងសែន ភ្ជាប់នឹងផ្លូវមានស្រាប់ និងឆ្លងកាត់តំបន់ឧស្សាហកម្ម
- ជំរុញកសាងនិងពង្រីកបន្ថែមផ្លូវក្រវាត់ក្រុងភ្ជាប់ពីផ្លូវជាតិលេខ៩ ត្រង់ចំណុចប្រសព្វនឹងផ្លូវជាតិលេខ៦២ មកភ្ជាប់ផ្លូវក្រវាត់ក្រុងនៃភាគខាងត្បូងក្រុង
- សាងសង់ស្ពានបន្ថែមឆ្លងកាត់ស្ទឹងសែន ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការដឹកជញ្ជូននិងធ្វើដំណើរ
- ជំរុញកសាងបណ្តាញផ្លូវក្នុងតំបន់ឧស្សាហកម្មដែលបានគ្រោងទុក
- បង្កើតបណ្តាញផ្លូវតភ្ជាប់ទំនាក់ទំនងរវាងទីប្រជុំជនក្រុងទៅតំបន់ជាយក្រុងភាគខាងកើត ខាងត្បូង និងខាងជើងនៅភូមិកំពង់ចំលងក្នុងសង្កាត់កំពង់ប្រណាក ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការធ្វើដំណើរ និងកែលម្អផ្លូវស្របតាមបណ្តោយដងស្ទឹងសែននិងបណ្តាញផ្លូវក្នុងក្រុងឱ្យមានគុណភាពនិងសោភណភាព ស្របតាមគោលការណ៍អភិវឌ្ឍបៃតង
- រៀបចំឱ្យមានភ្លើងសញ្ញាចរាចរណ៍ ភ្លើងបំភ្លឺនៅតាមដងផ្លូវ ផ្លាកនិងគំនូសសញ្ញាចរាចរណ៍ និងលេខផ្លូវឱ្យបានគ្រប់ផ្លូវ
- រៀបចំចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង ផ្លូវជិះកង់ ផ្លូវសម្រាប់ជនមានពិការភាព និងចំណតរថយន្តសាធារណៈសម្រាប់មនុស្សទាំងអស់គ្នារួមទាំងជនមានពិការភាពនិងជនងាយរងគ្រោះអាចធ្វើដំណើរប្រកបដោយភាពងាយស្រួលនិងសុវត្ថិភាព
- បង្កើតផ្លូវថ្មីនិងតភ្ជាប់កំណាត់ផ្លូវដែលទាល់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការចរាចរណ៍បច្ចុប្បន្ននិងអនាគត
- លើកទឹកចិត្តអ្នកចូលរួមគាំទ្រក្នុងការពង្រីកផ្លូវ កែលម្អជាផ្លូវបេតុងនិងជាផ្លូវកៅស៊ូ នៅតាមមូលដ្ឋានដើម្បីសម្រួលចរាចរណ៍ធ្វើដំណើរទៅវិញទៅមក
- កំណត់ទីតាំងសម្រាប់រៀបចំចំណតរថយន្តក្រុងនិងចំណតទូកទៅនៅក្នុងទីប្រជុំជនក្រុងនិងតាមសង្កាត់
- ពង្រីកនិងកែលម្អបណ្តាញផ្លូវទាំងអស់ឱ្យមានទំហំសមស្រប មានបណ្តាញបៃតង មានសោភណភាពប្រទាក់ក្រឡាគ្នាជាប្រព័ន្ធនគរូបនីយកម្ម មានជាអាទិ៍មហាវិថី វិថី វក្កវិថី តិរវិថី អនុវិថី និងផ្លូវបម្រើឱ្យការធ្វើដំណើរនិងដឹកជញ្ជូន ផ្លូវជិះកង់ ផ្លូវថ្មើរជើង និងផ្លូវសម្រាប់ជនមានពិការភាព ដើម្បីបង្កើតជាលម្ហសាធារណៈសម្រាប់គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ និងដំណោះស្រាយចរាចរណ៍ដ៏ល្អប្រសើរសម្រាប់ក្រុងព្រះវិហារដែលជាបេះដូងនៃខេត្តព្រះវិហារ។

### ៤.៣.៣- ផ្លូវទឹក

- រៀបចំមធ្យោបាយធ្វើដំណើរតាមផ្លូវទឹកឱ្យបានច្រើនប្រភេទ ដើម្បីសម្រួលដល់ការធ្វើដំណើរទូទៅ ទេសចរណ៍ និងការប្រកបរបរ
- រៀបចំ កែលម្អ និងសាងសង់កំពង់ផែទេសចរណ៍និងកំពង់ផែនេសាទ នៅទីតាំងសមស្របតាមដងស្ទឹងសែន ឱ្យស្របតាមបទដ្ឋានបច្ចេកទេស
- ស្តារឃ្លងផ្នែកខ្លះនៃស្ទឹងសែន ដើម្បីងាយស្រួលដល់ការដឹកជញ្ជូននិងការធ្វើដំណើរ
- កែលម្អ ស្តារ និងកសាងបណ្តាញផ្លូវទឹកនៅតាមដងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ និងបឹងបួ សម្រាប់បម្រើដល់ទេសចរណ៍ កសិកម្ម ការផ្គត់ផ្គង់ទឹក និងការរំដោះទឹកជំនន់
- រៀបចំប្រព័ន្ធដឹកជញ្ជូននិងមធ្យោបាយដឹកជញ្ជូនផ្លូវទឹកស្របតាមតម្រូវការ។

### ៤.៣.៤- ការគ្រប់គ្រងធនធានទឹកនិងការផ្គត់ផ្គង់ទឹកស្អាត

ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅក្រុងព្រះវិហារត្រូវបានផ្គត់ផ្គង់ដោយក្រុមហ៊ុនឯកជន ដែលទទួលបានការអនុញ្ញាតឱ្យផ្គត់ផ្គង់ទឹកស្អាតនៅសង្កាត់កំពង់ប្រណាក និងបានពង្រីកបណ្តាញផ្គត់ផ្គង់ទឹកស្អាតបន្ថែមទៅដល់សង្កាត់ប៉ាលហាល។ ប្រព័ន្ធដែលមានស្រាប់នេះ ត្រូវកែលម្អនិងពង្រីកបន្ថែម ដើម្បីរក្សាតុល្យភាពជាមួយកំណើនប្រជាជន។ ដូចនេះយុទ្ធសាស្ត្រគ្រប់គ្រងធនធានទឹកនិងផ្គត់ផ្គង់ទឹកស្អាតរួមមានៈ

- បន្តលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាតដោយយកចិត្តទុកដាក់លើគុណភាពនិងបរិមាណ
- គ្រប់គ្រងធនធានទឹកដែលមានប្រភពពីទឹកភ្លៀងសម្រាប់សម្អាតទីក្រុងនិងស្រោចដំណាំ
- សិក្សាពីជលសាស្ត្រនិងត្រួតពិនិត្យតាមដាន ដើម្បីធានានូវបរិមាណទឹកស្អាតនៃធនធានទឹកដែលអាចមាន
- សិក្សាប្រភពទឹកផ្សេងៗ ជាពិសេសប្រភពទឹកពីបឹងទំនប់៩៥ ដើម្បីផ្គត់ផ្គង់ទឹកស្អាតសម្រាប់តំបន់កណ្តាលក្រុងនិងជាយក្រុង បន្ថែមលើប្រភពទឹកពីស្ទឹងសែន ដើម្បីធានានូវសក្តានុពលនៃទឹកក្រោមដី
- ការពារផ្ទៃរងទឹកភ្លៀងផ្នែកខាងលើបឹងទំនប់៩៥ ពីការអភិវឌ្ឍផ្សេងៗ ជាពិសេសការធ្វើកសិកម្មដែលនាំឱ្យបំពុលដល់បរិស្ថាន
- ស្តារឡើងវិញនិងដោះដូរបំពង់ទឹកចាស់ៗ ដើម្បីកាត់បន្ថយការលេចធ្លាយនិងបង្កើនគុណភាពទឹកតាមតម្រូវការជាក់ស្តែង
- ការពារ ពង្រីកបន្ថែម សាងសង់អាងស្តុកទឹក បណ្តាញចែកចាយទឹក និងអភិវឌ្ឍស្ថានីយថ្មីចម្រោះទឹកស្អាត ដើម្បីធានាការផ្គត់ផ្គង់ស្របតាមការរីកចម្រើននិងការប្រើប្រាស់
- រៀបចំ ស្តារ និងពង្រីកការផ្គត់ផ្គង់ទឹកស្អាតដោយក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាតក្រុងព្រះវិហារដល់ប្រជាជនក្នុងក្រុងឱ្យបាន១០០%
- ពង្រីកបណ្តាញចែកចាយទឹក ដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាជនឱ្យបានច្រើនជាងមុននិងដើម្បីបង្កើនប្រាក់ចំណូល
- បន្តពង្រឹងសមត្ថភាពនិងគ្រប់គ្រងដំណើរការថែទាំ ជួសជុល និងការពារបណ្តាញចែកចាយទឹកស្របតាមបទដ្ឋានបច្ចេកទេស
- ជំរុញរៀបចំប្រព័ន្ធឆ្លាត ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវានិងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត
- ការពារប្រភពទឹកធម្មជាតិ មានជាអាទិ៍ទន្លេ ស្ទឹង អូរ ប្រឡាយ បឹងបួ ត្រពាំង និងទឹកក្រោមដី។

## ៤.៣.៥-ការផ្គត់ផ្គង់ថាមពលអគ្គិសនី ទូរគមនាគមន៍ បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍

យុទ្ធសាស្ត្រផ្គត់ផ្គង់ថាមពលអគ្គិសនី ទូរគមនាគមន៍ បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍រួមមាន៖

- ពង្រីកនិងកែលម្អបណ្ដាញអគ្គិសនីដែលមានស្រាប់ ដើម្បីរក្សាតុល្យភាពទៅនឹងកំណើនប្រជាជន និងតម្រូវការផ្គត់ផ្គង់អគ្គិសនីក្នុងក្រុងដែលកំពុងមានកំណើនខ្ពស់
- រៀបចំ ជួសជុល កែលម្អ និងសាងសង់បង្គោលភ្លើងបំភ្លឺផ្លូវថ្មី និងបណ្ដាញខ្សែភ្លើងសម្រាប់ការគ្រប់គ្រង និងចែកចាយអគ្គិសនីឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ចៀសវាងការបង្កគ្រោះថ្នាក់ និងបាត់បង់សោភណភាពក្រុង
- ជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់អគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យនិងថាមពលកកើតឡើងវិញ
- ជំរុញលទ្ធភាពរៀបចំបណ្ដាញអគ្គិសនីឬបណ្ដាញបញ្ជូនអគ្គិសនី បណ្ដាញទូរគមនាគមន៍ ខ្សែកាបគ្រប់ប្រភេទ កប់ក្នុងដី ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនិងរក្សាដល់សោភណភាពក្រុង
- ជំរុញការវិនិយោគនិងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច ទេសចរណ៍ ពាណិជ្ជកម្ម ឧស្សាហកម្ម និងលំនៅឋាន
- ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា ទូរគមនាគមន៍ និងបច្ចេកវិទ្យាទំនើប ដើម្បីជួយសម្រួលដល់ការអភិវឌ្ឍ ការផ្ដល់សេវា ប្រតិបត្តិការ និងដំណោះស្រាយបញ្ហា ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនិងការប្រកួតប្រជែង ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម បរិស្ថាន វប្បធម៌ ដោយឆ្លើយតបនឹងតម្រូវការរបស់ប្រជាជនបច្ចុប្បន្ននិងធានាបានចីរភាពសម្រាប់អនាគត
- ជំរុញអភិវឌ្ឍមជ្ឈមណ្ឌលក្រុងជាតំបន់ឆ្លាតដោយផ្ដោតលើវិស័យទូរគមនាគមន៍ ដឹកជញ្ជូនសាធារណៈ សន្តិសុខនិងសុវត្ថិភាព អភិវឌ្ឍតំបន់នគរូបនីយកម្ម និងសំណង់ ការផ្គត់ផ្គង់ថាមពលអគ្គិសនីនិងទឹកស្អាត ការគ្រប់គ្រងសំណល់រឹងនិងរាវ គ្រប់គ្រងរដ្ឋបាលនិងការផ្ដល់សេវាសាធារណៈ និងវិស័យផ្សេងទៀតស្របតាមសក្ដានុពលរបស់តំបន់
- ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធបណ្ដាញមេ បណ្ដាញចែកចាយ និងស្ថានីយទូរគមនាគមន៍ក្នុងតំបន់និងជុំវិញ ដូចជាសេវាអ៊ីនធឺណិតសាធារណៈនិងមជ្ឈមណ្ឌលទិន្នន័យព័ត៌មានវិទ្យា។

## ៤.៣.៦-ហេដ្ឋារចនាសម្ព័ន្ធសង្គម

យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសង្គមរួមមាន៖

- ជំរុញស្ដារនិងរៀបចំលម្អសាធារណៈ ផ្ទៃបៃតង សួនសាធារណៈ មជ្ឈមណ្ឌលវប្បធម៌ និងសាសនាសម្រាប់មនុស្សគ្រប់គ្នា រួមមានកុមារ យុវជន ស្ត្រីមានគភ៌ មនុស្សវ័យចាស់ និងជនមានពិការភាពឱ្យទទួលបាននូវសេវាប្រកបដោយសមធម៌
- រៀបចំឱ្យមានផ្លូវថ្មើរជើង ផ្លូវសម្រាប់ជនមានពិការភាព និងបង្គន់អនាម័យសម្រាប់ជនមានពិការភាពនៅតាមទីសាធារណៈ អគារសាធារណៈ និងកន្លែងផ្ដល់សេវាកម្មផ្សេងៗ
- រៀបចំឱ្យមានសាលារៀន មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈគ្រប់កម្រិតនៅតាមភូមិសាស្ត្រក្នុងក្រុងស្របតាមបទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្មនិងបទដ្ឋានបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

- រៀបចំ កែលម្អ និងពង្រីកសេវាកម្មសុខាភិបាលនៅគ្រប់កម្រិត មានជាអាទិ៍ប៉ុស្តិ៍សុខភាព កន្លែងសង្គ្រោះបន្ទាន់ មណ្ឌលសុខភាព មន្ទីរពេទ្យ ឱសថស្ថាន នៅតាមភូមិសាស្ត្រក្នុងក្រុងស្របតាមបទដ្ឋានបច្ចេកទេសរបស់ក្រសួងសុខាភិបាល
- ថែរក្សាទីតាំងវប្បធម៌ សាសនា និងសម្បត្តិបេតិកភណ្ឌ ដូចជាវត្តអារាមព្រះពុទ្ធសាសនា ប្រាសាទបុរាណជាដើម
- រៀបចំឱ្យមានសួនជ្រាបទឹកនៅតាមហេដ្ឋារចនាសម្ព័ន្ធសង្គម។

## ៤.៤-យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច

ការអភិវឌ្ឍសេដ្ឋកិច្ចក្រុងព្រះវិហារត្រូវបានពឹងផ្អែកលើសេវាកម្មទេសចរណ៍ ពាណិជ្ជកម្ម ឧស្សាហកម្ម និងកសិកម្ម។

### ៤.៤.១-ការអភិវឌ្ឍទេសចរណ៍

ខេត្តព្រះវិហារមានសក្តានុពលទេសចរណ៍ជាច្រើន ដូចជាតំបន់ទេសចរណ៍ធម្មជាតិតាមដងទន្លេ ស្ទឹង ភ្នំ ព្រៃឈើ សត្វព្រៃ ទឹកជ្រោះ ទឹកធ្លាក់ ប្រាសាទបុរាណ វត្តអារាម ទីស្ការបូជា តំបន់ទេសភាពធម្មជាតិ តំបន់សហគមន៍ទេសចរណ៍ និងតំបន់រមណីយដ្ឋានទេសចរណ៍នានានៅតាមស្រុក ក្នុងខេត្ត ដែលជាគោលដៅទេសចរណ៍ពេញនិយមសម្រាប់ការស្នាក់នៅនិងការលម្ហែកម្សាន្ត។

តំបន់ទេសចរណ៍ព្រៃភ្នំដែលស្ថិតនៅភាគខាងជើងនៃប្រទេសកម្ពុជា រួមមានខេត្តសៀមរាប ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ និងខេត្តស្ទឹងត្រែង គឺជាប៉ូលទេសចរណ៍ដ៏សំខាន់។ ខេត្តព្រះវិហារបានបំពេញតួនាទីទទួលភ្ញៀវទេសចរមកស្នាក់នៅនិងលម្ហែកម្សាន្ត និងកំពុងអភិវឌ្ឍខ្លួនក្នុងវិស័យនេះ ដោយសហការជាមួយដៃគូអភិវឌ្ឍ ផ្នែកឯកជន សំដៅរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ នៅឆ្នាំ២០២៥ មន្ទីរទេសចរណ៍ខេត្តព្រះវិហារនឹងត្រូវដឹកនាំរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍ ដោយគ្រប់ទីកន្លែងដែលមានសក្តានុពលទេសចរណ៍វប្បធម៌និងធម្មជាតិ នឹងត្រូវបានយកចិត្តទុកដាក់រៀបចំប្រែក្លាយទៅជាគោលដៅទេសចរណ៍ ផ្សព្វផ្សាយទាក់ទាញភ្ញៀវទេសចរ និងរៀបចំយន្តការគ្រប់គ្រងនិងអភិវឌ្ឍនៅនឹងកន្លែង ក្នុងនោះមានការប្រមូលផ្តុំចងក្រងជាសហគមន៍ទេសចរណ៍ ដោយផ្តល់លទ្ធភាព សមត្ថភាព ចំណេះដឹង និងផលប្រយោជន៍ជូនប្រជាជនមូលដ្ឋានជាអាទិភាព។

ការអភិវឌ្ឍទេសចរណ៍មានសារៈសំខាន់ណាស់ក្នុងការរួមចំណែកដល់ការអភិវឌ្ឍក្រុងព្រះវិហារក៏ដូចជាខេត្តព្រះវិហារ។ ក្រុងព្រះវិហារមានសក្តានុពលទេសចរណ៍ជាច្រើន ដូចជាតំបន់ទេសចរណ៍វប្បធម៌និងសោភណភាពក្រុងនិងតំបន់ទេសចរណ៍ធម្មជាតិ។ ដូចនេះយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍រួមមានៈ

១)តំបន់ទេសចរណ៍វប្បធម៌និងសោភណភាពក្រុង

- រៀបចំបែងចែកតំបន់សណ្ឋាគារ ភោជនីយដ្ឋាន រមណីយដ្ឋាន ផ្សាររាត្រី និងលំនៅឋានបម្រើទេសចរណ៍ប្រកបដោយសុខុមាលភាព
- កំណត់ទីតាំងសួនទេសចរណ៍ ពង្រីកបន្ថែមតំបន់លម្ហសាធារណៈ ទីតាំងសេវាកម្ម មណ្ឌលកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យ

- លើកកម្ពស់ប្រសិទ្ធភាពនៃការអភិវឌ្ឍសំណង់ស្ថាបត្យកម្មលក្ខណៈខ្មែរនិងវប្បធម៌ ដោយផ្សារភ្ជាប់នឹងទេសភាពធម្មជាតិតាមដងស្ទឹងសែន ភ្នំ ព្រៃឈើ និងផ្ទៃបៃតង ជុំវិញក្រុង
- ថែរក្សានិងការពារសំណង់សម្រាប់បម្រើវិស័យវប្បធម៌ ដូចជារោងភាពយន្ត អគារវប្បធម៌ជាដើម
- រៀបចំតំបន់ទេសចរណ៍វប្បធម៌ដោយចងក្រងសហគមន៍ទេសចរណ៍ អភិវឌ្ឍទេសចរណ៍ស្នាក់នៅ និងជំរុញការលក់ផលិតផលក្នុងស្រុក ព្រមទាំងរៀបចំកម្មវិធីប្រពៃណីនិងកម្សាន្តផ្សេងៗ
- កែលម្អនិងរៀបចំមហាវិថី វិថី អនុវិថី និងផ្លូវសម្រាប់ដឹកជញ្ជូននិងសម្រាប់មនុស្សទាំងអស់គ្នាដោយរៀបចំឱ្យមានចំណែកផ្លូវសម្រាប់រថយន្ត គន្លងផ្លូវទោចក្រយាន ផ្លូវថ្មើរជើង ផ្លូវជនមានពិការភាព ចំណតរថយន្ត សញ្ញាបង្ហាញផ្លូវទេសចរណ៍ ប្រព័ន្ធការពារសុវត្ថិភាពតាមបទដ្ឋានបច្ចេកទេសនិងអភិវឌ្ឍបៃតង ដោយធានាបាននូវសោភណភាព វប្បធម៌ សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងគុណភាពបរិស្ថានល្អ
- ជំរុញឱ្យមានការរៀបចំកម្មវិធីប្រពៃណី និងកម្សាន្តផ្សេងៗ ដូចជាកម្មវិធីរាំរបាំបុរាណ ការប្រកួតអក្សរសាស្ត្រ សិល្បៈចម្រៀង ប្រណាំងទូក រត់ប្រណាំង ទិវាបរិស្ថានទីក្រុងស្អាត ដើម្បីលើកស្ទួយវិស័យទេសចរណ៍។

២)តំបន់ទេសចរណ៍ធម្មជាតិ

- ជំរុញរៀបចំនិងអភិវឌ្ឍទេសចរណ៍ធម្មជាតិ អេកូទេសចរណ៍ និងទេសចរណ៍កែច្នៃនៅតាមដងស្ទឹងសែន តំបន់ដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព តំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង តំបន់កសិកម្ម ភ្នំ ព្រៃឈើ និងបឹងទំនប់៩៥ និងរៀបចំទូកទេសចរណ៍សម្រាប់ដំណើរកម្សាន្ត គយគន់ទេសភាព ធម្មជាតិ ព្រះអាទិត្យលិច ព្រៃឈើ ទឹងជ្រោះ និងទឹកធ្លាក់
- កំណត់តំបន់កសិទេសចរណ៍ដែលមានសក្តានុពលនៅក្នុងតំបន់សហគមន៍កសិកម្មនិងសិក្សាលទ្ធភាពបង្កើតឱ្យមានកសិទេសចរណ៍
- រៀបចំតំបន់ទេសចរណ៍ធម្មជាតិដោយចងក្រងសហគមន៍ទេសចរណ៍ អភិវឌ្ឍទេសចរណ៍ស្នាក់នៅ និងជំរុញការលក់ផលិតផលក្នុងស្រុក
- លើកកម្ពស់ប្រសិទ្ធភាពនៃការការពារនិងការអភិរក្សធនធាននិងជីវៈចម្រុះក្នុងស្ទឹងសែន តំបន់ដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព តំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង តំបន់កសិកម្ម ភ្នំ ព្រៃឈើ និងបឹងទំនប់៩៥
- រៀបចំសួនច្បារ តំបន់លម្ហែកម្សាន្ត និងកន្លែងទេសចរណ៍ធម្មជាតិដែលមានអនាម័យបរិស្ថានល្អនិងរក្សានូវលក្ខណៈធម្មជាតិ ដើម្បីទាក់ទាញភ្ញៀវទេសចរមកកម្សាន្ត។

៣)ខ្សែទស្សនកិច្ចកម្សាន្ត ផលិតផល ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍

- រៀបចំនិងបង្កើតខ្សែទស្សនកិច្ចកម្សាន្តទេសចរណ៍ក្នុងខេត្តទៅតាមលំដាប់លំដោយ
- ជំរុញរៀបចំហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបម្រើខ្សែទស្សនកិច្ចកម្សាន្តទេសចរណ៍និងនិងពង្រឹងសេវាកម្មទេសចរណ៍
- កែលម្អនិងបង្កើតផលិតផលទេសចរណ៍ថ្មីៗ

- ធ្វើសមាហរណកម្មសេដ្ឋកិច្ចជនបទទៅក្នុងវិស័យទេសចរណ៍ ដើម្បីលើកកម្ពស់ទំនិញសហគមន៍តាមរយៈភូមិមួយផលិតផលមួយ និងបង្កើតសហគមន៍ផលិតកម្មបម្រើភ្ញៀវទេសចរនៅតាមតំបន់ទេសចរណ៍
- យកចិត្តទុកដាក់និងពង្រឹងសុវត្ថិភាពប្រព័ន្ធឬមធ្យោបាយសង្គ្រោះបន្ទាន់ ជាពិសេសត្រូវបណ្តុះបណ្តាលមន្ត្រីជំនាញសង្គ្រោះបន្ទាន់ឬសង្គ្រោះបឋម សន្តិសុខការពារតាមរមណីយដ្ឋាន ព្រមទាំងមានសម្ភារៈសង្គ្រោះគ្រប់គ្រាន់
- លើកកម្ពស់សេវាទេសចរណ៍និងបដិសណ្ឋារកិច្ចឱ្យឈានដល់កម្រិតបទដ្ឋានជាតិនិងអន្តរជាតិ ព្រមទាំងបុគ្គលិកនិងអ្នកគ្រប់គ្រងសេវាកម្មទេសចរណ៍ទទួលបានជំនាញវិជ្ជាជីវៈច្បាស់លាស់
- ត្រូវតែយកចិត្តទុកដាក់សុវត្ថិភាពចំណីអាហារដោយត្រូវជំរុញលើកកម្ពស់អនាម័យ ប្រព័ន្ធត្រួតពិនិត្យស្តង់ដា និងជំងឺឆ្លងផ្សេងៗតាមរយៈចំណីអាហារ
- រៀបចំសណ្តាប់ធ្នាប់ ប្រព័ន្ធចរាចរណ៍ ផ្លាកសញ្ញាបង្ហាញផ្លូវភ្ញៀវទេសចរ និងបំពាក់បរិក្ខារនៅតាមដងផ្លូវ កន្លែងកម្សាន្ត កន្លែងស្នាក់នៅ និងកន្លែងផ្សេងៗទៀត ដើម្បីធានាសន្តិសុខនិងសុវត្ថិភាពសម្រាប់ភ្ញៀវទេសចរ
- រៀបចំមជ្ឈមណ្ឌលផ្សព្វផ្សាយ មណ្ឌលព័ត៌មានទេសចរណ៍ គេហទំព័រតំបន់ទេសចរណ៍ដោយចាំបាច់ត្រូវតភ្ជាប់ជាមួយគេហទំព័ររបស់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល
- លើកទឹកចិត្តនិងបង្កលក្ខណៈងាយស្រួលដល់ផ្នែកឯកជនក្នុងការផ្តល់សេវាកម្មទេសចរណ៍ រួមមានការកម្សាន្ត រមណីយដ្ឋាន សណ្ឋាគារ ភោជនីយដ្ឋាន ធុរកិច្ចទេសចរណ៍ និងពិព័រណ៍ផលិតផលក្នុងស្រុក
- សហការជាមួយក្រុមហ៊ុនភាពយន្តនិងក្រុមហ៊ុនផ្សាយពាណិជ្ជកម្ម ដើម្បីរៀបចំព្រឹត្តិការណ៍ទេសចរណ៍នានានៅក្នុងខេត្ត
- ជំរុញរៀបចំនិងអភិវឌ្ឍផលិតផលទេសចរណ៍និងរៀបចំកែច្នៃផលិតផលឱ្យមានលក្ខណៈជាតិ។

### ៤.៤.២- ការអភិវឌ្ឍពាណិជ្ជកម្ម

ពាណិជ្ជកម្មមានសារៈសំខាន់ណាស់សម្រាប់គាំទ្រដល់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាជននិងគាំទ្រដល់ស្ថិរភាពដំណើរការ និងការរីកចម្រើននៃផ្នែកទេសចរណ៍ ឧស្សាហកម្ម និងកសិកម្មនៅក្នុងក្រុងព្រះវិហារ។ ដូចនេះយុទ្ធសាស្ត្រអភិវឌ្ឍពាណិជ្ជកម្មរួមមាន៖

- បែងចែកតំបន់ប្រើប្រាស់ដីពាណិជ្ជកម្មបច្ចុប្បន្ននិងអនាគតឱ្យបានច្បាស់លាស់និងត្រឹមត្រូវ ជាពិសេសមិននៅជាប់ផ្លូវជាតិឬផ្លូវមេសំខាន់ៗរបស់ក្រុង
- រក្សាបរិស្ថានរស់នៅល្អទាំងក្នុងតំបន់ពាណិជ្ជកម្មនិងតំបន់ជុំវិញ ជាពិសេសការគ្រប់គ្រងសំណល់រឹងនិងរាវ
- កំណត់ឱ្យបានច្បាស់លាស់គំរូផ្លាក ទីតាំងនិងទំហំស្តង់ដា ពណ៌និងភ្លើងបំភ្លឺ នៃការផ្សព្វផ្សាយពាណិជ្ជកម្ម
- កែលម្អនិងពង្រីកទីផ្សារលក់ដូរ ដើម្បីឱ្យប្រជាពលរដ្ឋនិងអាជីវករក្នុងផ្សារមានកន្លែងលក់ដូរធំទូលាយសមស្របនិងមានសណ្តាប់ធ្នាប់
- រៀបចំមជ្ឈមណ្ឌលផ្សព្វផ្សាយនិងមណ្ឌលព័ត៌មានអំពីស្តង់ដាបច្ចេកទេសផលិតផលិតផលក្នុងស្រុកដល់ប្រជាពលរដ្ឋ

- កែលម្អទីផ្សារដែលមានស្រាប់ទាំងឯកជននិងរដ្ឋឱ្យមានលក្ខណៈស្តង់ដា រួមមានចំណតយានយន្ត ច្រកចេញចូលនិងផ្លូវដើរក្នុងផ្សារ បណ្តាញទឹកស្អាត បណ្តាញអគ្គិសនី តំបន់បៃតង ប្រព័ន្ធលូបង្ហូរទឹកកខ្វក់ កន្លែងទុកដាក់សំរាម បរិស្ថានល្អ កន្លែងលើកដាក់ទំនិញ កន្លែងភ្ញៀវឡើងចុះរថយន្ត ភ្លើងបំភ្លឺ និងហេដ្ឋារចនាសម្ព័ន្ធឱ្យមានរបៀបរៀបរយនិងសណ្តាប់ធ្នាប់ល្អ។ រៀបចំថ្មីឬកែលម្អផ្សារលក់ដូរដែលមានស្រាប់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងជីវភាពរស់នៅរបស់ប្រជាជន
- លើកទឹកចិត្តឱ្យមានការវិនិយោគផ្សារទំនើប ហាងទំនិញ ផ្សាររាត្រី មជ្ឈមណ្ឌលពាណិជ្ជកម្ម ធនាគារ និងសហគ្រាសផ្សេងៗ ដើម្បីងាយស្រួលក្នុងការដោះដូរទំនិញ បង្កើតការងារ និងលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ច
- រៀបចំបង្កើតឃ្លាំងស្តុកទំនិញក្នុងក្រុងសម្រាប់ចែកចាយទៅតំបន់ជុំវិញ ព្រមទាំងសាងសង់ហេដ្ឋារចនាសម្ព័ន្ធឱ្យបានល្អ ដើម្បីជួយសម្រួលដល់ការដឹកជញ្ជូន
- រៀបចំទីកន្លែងសម្រាប់តាំងពិព័រណ៍ពាណិជ្ជកម្មនិងផ្សព្វផ្សាយផលិតផលគ្រប់ប្រភេទ ដើម្បីបង្កើនការផលិតនិងជំរុញសកម្មភាពសេដ្ឋកិច្ច។

### ៤.៤.៣- ការអភិវឌ្ឍឧស្សាហកម្ម

ការចងក្រុងជាសហគមន៍ទៅតាមប្រភេទនៃផលិតកម្ម ការពង្រឹង និងការពង្រីកឧស្សាហកម្មដោយការផ្ទេរបច្ចេកវិទ្យានិងការធ្វើឱ្យប្រសើរឡើងនូវម៉ាស៊ីននិងឧបករណ៍នៅខ្សោយ សមត្ថភាពបច្ចេកទេស ទីផ្សារ និងការគ្រប់គ្រងសហគ្រាសនៅមានកម្រិត និងទីតាំងរោងចក្រនិងឃ្លាំងមួយចំនួននៅលាយឡំនឹងតំបន់លំនៅឋាននិងតំបន់ពាណិជ្ជកម្មក្នុងទីប្រជុំជន។ ដូចនេះយុទ្ធសាស្ត្រអភិវឌ្ឍឧស្សាហកម្មរួមមាន៖

- រៀបចំបែងចែកតំបន់ឧស្សាហកម្មឱ្យបានសមស្របនិងមានទីតាំងនៅដាច់ចេញពីតំបន់លំនៅឋាន ជាពិសេសមិននៅជាប់ផ្លូវជាតិឬផ្លូវមេសំខាន់ៗរបស់ក្រុង
- រក្សាបរិស្ថានរស់នៅល្អទាំងក្នុងតំបន់ពាណិជ្ជកម្មនិងតំបន់ជុំវិញ ជាពិសេសការគ្រប់គ្រងសំណល់រឹងនិងរាវ
- រៀបចំឱ្យមានចំណតរថយន្តដឹកទំនិញនិងដឹកកម្មករ កន្លែងលើកដាក់ទំនិញនិងឡើងចុះរបស់កម្មករ ផ្លូវដឹកជញ្ជូន ច្រកចេញចូល និងទិសដៅចរាចរណ៍ នៅក្នុងតំបន់និងភ្ជាប់ទៅតំបន់ជុំវិញ
- លើកទឹកចិត្តដល់អ្នកវិនិយោគជាតិនិងអន្តរជាតិដែលមកធ្វើឧស្សាហកម្មបៃតងក្នុងក្រុង ដោយជ្រើសរើសយកប្រភេទឧស្សាហកម្មដែលមានទិសដៅនាំចេញ
- បង្កើតសួនឧស្សាហកម្មសម្រាប់សហគ្រាសធុនតូចនិងមធ្យម សំដៅជំរុញភ្ជាប់រវាងសហគ្រាសធំៗក្រៅប្រទេសនិងសហគ្រាសក្នុងស្រុក ជាពិសេសការចូលរួមក្នុងខ្សែច្រវាក់តម្លៃនិងខ្សែច្រវាក់ផលិតកម្មតំបន់ក្នុងបរិការណ៍នៃសមាហរណកម្មតំបន់
- ជំរុញអភិវឌ្ឍឧស្សាហកម្មធុនស្រាលដែលប្រើគ្រឿងម៉ាស៊ីនស្វ័យប្រវត្តិទំនើបសម្រាប់កែច្នៃ ផលិតផលកសិកម្មនិងសម្ភារៈប្រើប្រាស់ផ្សេងៗ ដើម្បីបំពេញតម្រូវការប្រើប្រាស់ប្រជាពលរដ្ឋក្នុងក្រុងនិងសម្រាប់ចែកចាយទាំងក្នុងនិងក្រៅប្រទេស

- លើកទឹកចិត្តដល់ការវិនិយោគលើវិស័យរោងចក្រកាត់ដេរ សហគ្រាស រោងចក្រតំឡើងយានយន្ត និងគ្រឿងអេឡិចត្រូនិក សិប្បកម្មដែលអាចបង្កើតការងារជូនប្រជាពលរដ្ឋ ដើម្បីលើកស្ទួយជីវភាពរស់នៅ
- ផ្លាស់ប្តូរទីតាំងរោងចក្រ សហគ្រាស សិប្បកម្ម និងស្ថានីយប្រេងឥន្ធនៈដែលកំពុងធ្វើអាជីវកម្មបច្ចុប្បន្ន និងបានប៉ះពាល់ដល់បរិស្ថាននិងសុខភាពរបស់ប្រជាជន ដោយសាងសង់ឬកែសម្រួលឡើងវិញស្របតាមស្តង់ដាបច្ចេកទេសនិងប្លង់គោលប្រើប្រាស់ដីនេះ
- តម្រង់ទិសការផ្គត់ផ្គង់អគ្គិសនីនិងទឹកស្អាតក្នុងតម្លៃសមរម្យទៅកាន់តំបន់ឧស្សាហកម្មនិងផលិតកម្មសំខាន់ៗ ដោយធានាឱ្យបានការផ្គត់ផ្គង់តាមតម្រូវការនិងមានស្ថិរភាព ដែលអនុញ្ញាតឱ្យរោងចក្រអាចគ្រោងផលិតកម្មរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព
- រៀបចំនិងអនុវត្តផែនការបញ្ចុះថ្លៃអគ្គិសនីនិងទឹកស្អាតសម្រាប់ឧស្សាហកម្មនិងផលិតកម្មសំខាន់ៗ រួមទាំងពង្រឹងទំនុកចិត្តនិងពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនីនិងទឹកស្អាត
- លើកកម្ពស់ការប្រកួតប្រជែងក្នុងការអភិវឌ្ឍសេដ្ឋកិច្ចតាមរយៈវិស័យឧស្សាហកម្មនិងលើកទឹកចិត្តដល់អង្គភាពមានស្នាដៃល្អ
- លើកកម្ពស់ប្រសិទ្ធភាពនៃការអភិរក្សទេសភាពវប្បធម៌និងធម្មជាតិជុំវិញ ដោយសិក្សានិងរៀបចំផែនការគ្រប់គ្រងការប្រើប្រាស់ទឹកក្រោមដីនិងការប្រើប្រាស់ដី។

### ៤.៤.៤-ការអភិវឌ្ឍកសិកម្មនិងការផ្សព្វផ្សាយផលិតផលក្នុងស្រុក

ការធ្វើកសិកម្មនិងនេសាទគឺជាកត្តាសេដ្ឋកិច្ចដ៏ចម្បងសម្រាប់ខេត្តព្រះវិហារនិងក្រុងព្រះវិហារនិងតែងតែរងការគំរាមកំហែងពីគ្រោះធម្មជាតិ។ ដូចនេះយុទ្ធសាស្រ្តអភិវឌ្ឍកសិកម្មនិងផ្សព្វផ្សាយផលិតផលក្នុងស្រុករួមមាន៖

- រក្សាទុកតំបន់កសិកម្មឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ កាត់បន្ថយឬទប់ស្កាត់ការបំប្លែងដីកសិកម្មទៅជាដីសាងសង់ដោយផ្អែកតាមប្លង់គោលប្រើប្រាស់ដីនេះ។ ករណីចាំបាច់សម្រាប់ការពង្រីកប្រភេទដីអាចសាងសង់បាន ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ពិនិត្យលទ្ធភាពពង្រីកនិងបង្កើតតំបន់កែច្នៃកសិផល ដូចជាកែច្នៃផលិតសង្ហារិម កែច្នៃផលិតម្ហូបអាហារ កែច្នៃចំណីអាហារ សម្រាប់គោលដៅប្រើប្រាស់ក្នុងប្រទេសនិងនាំចេញ ដោយប្រើប្រាស់យន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ព្រមទាំងផ្តល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុនណាដែលបោះទីតាំងនៅមូលដ្ឋាន
- ធ្វើសមាហរណកម្មសេដ្ឋកិច្ចជនបទទៅក្នុងវិស័យទេសចរណ៍ សំដៅលើកកម្ពស់ផលិតកម្មកសិកម្មតាមសហគមន៍ ដើម្បីបង្កើនការងារនិងប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ
- បង្កើតផ្សារ សិក្សាទីផ្សារ និងផ្សព្វផ្សាយផលិតផលកសិកម្មក្នុងស្រុកដែលមានគុណភាពល្អ
- រៀបចំមជ្ឈមណ្ឌលផ្សព្វផ្សាយនិងមណ្ឌលព័ត៌មាន ដើម្បីបណ្តុះបណ្តាលនិងចែករំលែកបទពិសោធអំពីស្តង់ដាបច្ចេកទេសកសិកម្មដល់ប្រជាជន
- សហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ ដើម្បីលុបបំបាត់ឱ្យបាននូវការធ្វើកសិកម្មដែលបំផ្លាញធនធានធម្មជាតិ ការប្រើប្រាស់ជីនិងថ្នាំគីមីមិនគោរពតាមស្តង់ដាបច្ចេកទេស

- ជំរុញធ្វើកសិកម្មសរីរាង្គដោយប្រើប្រាស់ជីធម្មជាតិ សម្រាប់គោលដៅប្រើប្រាស់ក្នុងប្រទេសនិងនាំចេញ ដោយបង្កើនគុណភាពផលិតផលនិងផ្សព្វផ្សាយផលិតផលរបស់កសិករនៅមូលដ្ឋាន
- អភិវឌ្ឍមូលធនមនុស្សដោយជំរុញការបណ្តុះបណ្តាលជំនាញដល់កសិករ ដោយអនុវត្តតាមស្តង់ដាកសិកម្មនិងចលនាផ្តែកឯកជនឱ្យចូលរួមការបណ្តុះបណ្តាលនៅតាមមូលដ្ឋាន
- ជំរុញឱ្យមានការបង្កើតទីតាំងកែច្នៃផលិតផលកសិកម្មឱ្យបានច្រើនប្រភេទ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារនិងការប្រើប្រាស់
- ជំរុញរៀបចំឱ្យមានកន្លែងចិញ្ចឹមត្រីតាមបែបធម្មជាតិស្របតាមតម្រូវការទីផ្សារ
- បង្កើតការភ្ជាប់ទំនាក់ទំនងដោយផ្ទាល់រវាងអ្នកលក់និងអ្នកទិញ
- បង្កបរិយាកាសល្អ លើកទឹកចិត្ត និងជំរុញវិនិយោគក្នុងស្រុកនិងក្រៅស្រុកលើកសិកម្មនិងវារិវប្បកម្ម ដោយផ្អែកលើធនធានដីមានជីជាតិ ដើម្បីគាំទ្រដល់កសិឧស្សាហកម្មនិងសេដ្ឋកិច្ច
- រៀបចំយន្តការសម្រួលដល់ការនាំចេញកសិផលកែច្នៃ ដោយដោះស្រាយបញ្ហាភស្តុភារកម្មនិងកែលម្អការសម្រួលពាណិជ្ជកម្មតាមព្រំដែន រវាងប្រទេសកម្ពុជា-ថៃ-ឡាវ
- ថែរក្សាទីតាំងសម្រាប់ការលក់ដូរនិងផ្សាំបណ្តុះរុក្ខជាតិ កូនឈើ ផ្កាឱ្យទៅជាតំបន់បៃតងនៅក្នុងក្រុង ដើម្បីប្រែក្លាយជាតំបន់ទេសចរណ៍ធម្មជាតិសម្រាប់ការលម្ហែកម្សាន្តរបស់ភ្ញៀវទេសចរ។

### ៤.៥-យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ច

ដើម្បីធានាបាននូវការរស់នៅរបស់ប្រជាជនក្នុងក្រុងព្រះវិហារប្រកបដោយផាសុកភាពនិងសុខដុមរមនាចាំបាច់ត្រូវយកចិត្តទុកដាក់ជាចម្បងលើលំនៅឋានសមស្រប ចំណូលនិងការងារឬមុខរបរចិញ្ចឹមជីវិត និងការជួយសង្គ្រោះបានទាន់ពេលវេលានៅពេលមានគ្រោះថ្នាក់ឬហានិភ័យជាយថាហេតុកើតឡើង។ ដូចនេះយុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ចរួមមាន៖

- យកចិត្តទុកដាក់ជួយដល់ប្រជាជនក្រីក្រនិងជនងាយរងគ្រោះ ជាពិសេសប្រជាជនដែលទទួលរងការគំរាមកំហែងពីគ្រោះធម្មជាតិ
- ធ្វើអត្តសញ្ញាណនិងកំណត់ទីតាំង ដើម្បីដោះស្រាយសំណង់មិនរៀបរយនៅលើដីសាធារណៈរបស់រដ្ឋនិងដីឯកជនរបស់រដ្ឋ ជាពិសេសនៅលើដីចំណីស្ទឹងសែន ដីចំណីបឹងទំនប់៩៥ ដីចំណីបឹងឫ អូរប្រឡាយ និងដីចំណីផ្លូវ ជាពិសេសសំណង់នៅក្នុងដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព តំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង និងតំបន់ព្រៃឈើ
- ជំរុញលើកទឹកចិត្តដល់អ្នកវិនិយោគក្នុងការសាងសង់លំនៅឋានមានតម្លៃសមរម្យសម្រាប់ប្រជាជនដែលមានប្រាក់ចំណូលទាប
- សិក្សាលទ្ធភាពនិងរៀបចំគម្រោងសម្បទានដីសង្គមកិច្ចសម្រាប់ប្រជាជនក្រីក្រក្នុងក្រុងនិងប្រជាជនរស់នៅក្នុងសំណង់មិនរៀបរយគ្រប់កន្លែង
- លើកទឹកចិត្តឱ្យមានការចូលរួមពីអង្គការ ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិលលើការងារមនុស្សធម៌សម្រាប់ប្រជាជនក្រីក្រ
- ជំរុញអភិវឌ្ឍសមត្ថភាពរបស់ប្រជាពលរដ្ឋនៅជនបទឱ្យមានជំនាញវិជ្ជាជីវៈដែលអាចប្រកបមុខរបរបាន ដើម្បីលើកកម្ពស់កម្រិតជីវភាព

- ពង្រឹងការបម្រើសេវាកម្មរដ្ឋបាលសាធារណៈ អភិបាលកិច្ចល្អ និងលើកទឹកចិត្តការប្រតិបត្តិតាមច្រកចេញចូលតែមួយ
- ពង្រឹងហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មដោះស្រាយហានិភ័យ សង្គ្រោះបន្ទាន់ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងគ្រោះមហន្តរាយនានា ដូចជាគ្រោះអគ្គិភ័យ ទឹកជំនន់ និងបាតុភូតធម្មជាតិផ្សេងៗ។

## ៤.៦-យុទ្ធសាស្ត្រការពារបរិស្ថាននិងគ្រប់គ្រងសំណល់

ផែនការយុទ្ធសាស្ត្រចម្បងៗក្នុងវិស័យបរិស្ថានមាន "**ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតង ២០១៣-២០៣៥**" "**ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣**" "**យុទ្ធសាស្ត្រនិងផែនការសកម្មភាពបរិស្ថានជាតិ ២០១៦-២០២៣**" និង "**ផែនការយុទ្ធសាស្ត្រវេជបូកជាតិ**"។

### ៤.៦.១-ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន

- តំបន់កណ្តាលក្រុងឬតំបន់អភិវឌ្ឍនគរូបនីយកម្ម
- តំបន់ដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព
- តំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង
- តំបន់កសិកម្ម
- តំបន់ព្រៃឈើ
- តំបន់ធនធានទឹក រួមមានស្ទឹង អូរ ប្រឡាយ បឹងបួ ផ្លូវទឹក។

### ៤.៦.២-វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ

- ការពារនិងថែរក្សាជីវៈចម្រុះក្នុងតំបន់ធនធានទឹកដែលជាកន្លែងមានតួនាទីសំខាន់សម្រាប់ត្រីពង-កូននិងរកចំណីធនធានវារីជាតិនៃគ្រប់ប្រភេទត្រី
- ការពារនិងថែរក្សាទីជម្រាល ភ្នំ ព្រៃឈើ ព្រៃលិចទឹក ដើម្បីធានាប្រព័ន្ធអេកូឡូស៊ីនិងការគ្រប់គ្រងបរិស្ថានប្រកបដោយចីរភាព
- កាត់បន្ថយការបំពុលខ្យល់ដោយសារម៉ាស៊ីនតាមរយៈការផ្គត់ផ្គង់អគ្គិសនីរដ្ឋឱ្យបានច្រើនបំផុត និងលើកកម្ពស់មធ្យោបាយដឹកជញ្ជូនដែលមិនបំពុលបរិស្ថាននិងមិនប៉ះពាល់សណ្តាប់ធ្នាប់
- ពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងការសាងសង់នៃគម្រោងអភិវឌ្ឍនិងគម្រោងវិនិយោគនានា
- រៀបចំឱ្យមានមូលនិធិសម្រាប់ថែទាំបរិស្ថាននិងជំរុញការវិនិយោគរបស់រដ្ឋនិងរបស់ឯកជន។

### ៤.៦.៣-ការគ្រប់គ្រងសំណល់រឹង

ក្រុងព្រះវិហារមានកន្លែងសម្រាប់ទុកដាក់សំណល់រឹងស្ថិតនៅភូមិភារកិច្ច ក្នុងសង្កាត់ប៉ាលហាល ដែលមានផ្ទៃដីប្រមាណ៦ហិកតា ប៉ុន្តែបច្ចុប្បន្ននៅសល់ផ្ទៃដីត្រឹមតែ១,៥ហិកតា និងមានចម្ងាយប្រមាណ៤គីឡូម៉ែត្រពីទីប្រជុំជនក្រុង។

- កំណត់ទីតាំងថ្មីសម្រាប់ទុកដាក់សំណល់រឹងស្ថិតនៅភូមិហ្សសែត ក្នុងសង្កាត់ប៉ាលហាល មានផ្ទៃដីប្រមាណ៣៦ហិកតា និងមានចម្ងាយប្រមាណ១០គីឡូម៉ែត្រពីទីប្រជុំជនក្រុង និងរៀបចំទីតាំងសម្រាប់ទុកដាក់សំណល់រឹងស្របតាមបទដ្ឋានបច្ចេកទេសនិងស្តង់ដាទីក្រុងស្អាត និងរៀបចំមធ្យោបាយប្រមូលសំណល់រឹង
- ចុះកំណត់និយាមកា បោះបង្គោលព្រំ និងលើកផ្លាកសម្គាល់ទីតាំងសម្រាប់ទុកដាក់សំណល់រឹងរបស់ក្រុង ដើម្បីការពារការទន្ទ្រានកាន់កាប់ផ្សេងៗ
- រៀបចំផ្លូវភ្ជាប់ទីតាំងដី ត្រួតពិនិត្យទឹកក្រោមដី និងការពារទឹកហូរចេញ នៃទីតាំងសម្រាប់ទុកដាក់សំណល់រឹង
- បង្កើតយន្តការនិងហេដ្ឋារចនាសម្ព័ន្ធក្នុងការគ្រប់គ្រងសំណល់រឹងក្នុងក្រុងនិងខេត្ត
- រៀបចំទំនប់ព័ទ្ធជុំវិញទីតាំងដីចាក់សំរាមនិងរៀបចំជាផ្នែកៗនៃកន្លែងសម្អាតកម្ទេចសំរាម កន្លែងស្តុកគម្របដី ការលុបសំរាម
- បង្កើនការផ្សព្វផ្សាយដល់ប្រជាជនពីការញែកសំរាមនិងផ្តល់លេខកូដធុងញែកសំរាមតាមពណ៌ ឬថង់សំរាមស្រាលៗដល់អ្នកប្រមូលសំរាម
- អភិវឌ្ឍបច្ចេកវិទ្យាទំនើបនិងរៀបចំប្រព័ន្ធឆ្លាតក្នុងការគ្រប់គ្រងសំណល់រឹង
- ជំរុញឱ្យមានការអនុវត្តច្បាប់ឱ្យបានតឹងរ៉ឹងស្របតាមគោលការណ៍ការកាត់បន្ថយការប្រើប្រាស់ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃប្រើប្រាស់ឡើងវិញ ព្រមទាំងការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិកផលិតផលប៉ះពាល់បរិស្ថាន និងរៀបចំឱ្យមានរោងចក្រកែច្នៃសំណល់រឹងឱ្យមានប្រសិទ្ធភាព
- អ្នកប្រមូលសំរាមអាចទទួលបានការបណ្តុះបណ្តាលបង្កើនចំណេះដឹងស្វែងយល់ពីសំណល់ ដើម្បីផលិតសម្ភារៈ ធ្វើឱ្យការងារកាន់តែល្អប្រសើរសម្រាប់អ្នករើសសំរាមជាមួយនឹងទីកន្លែងធ្វើការសមរម្យនៅក្នុងរោងដែលមានខ្យល់ចេញចូលល្អ ដើម្បីចៀសវាងបានពីតំបន់មុខសញ្ញាគ្រោះថ្នាក់ផ្សេងៗ
- ជំរុញការចូលរួមរបស់ប្រជាពលរដ្ឋនិងការវិនិយោគរបស់រដ្ឋនិងរបស់ឯកជនក្នុងការគ្រប់គ្រងសំណល់រឹង
- ជំរុញកំណត់តំបន់គ្មានសំរាមតាមទីតាំងសំខាន់ៗ ដើម្បីលើកកម្ពស់សោភណភាពក្រុងនិងសុខភាពសាធារណៈ។

### ៤.៦.៤-ការគ្រប់គ្រងសំណល់រាវនិងទឹកកខ្វក់

ក្រុងព្រះវិហារមានភូមិសាស្ត្រនិងសណ្ឋានដីជាតំបន់ខ្ពង់រាប ដែលមានភ្នំនៅភាគខាងលិចឈៀងខាងត្បូង មានស្ទឹងសែនព័ទ្ធនៅភាគខាងកើតនិងភាគខាងជើង នាំឱ្យរំហូរទឹកភ្លៀងមានទិសដៅច្បាស់លាស់គឺពីភាគខាងលិចទៅភាគខាងកើតនិងពីភាគខាងត្បូងទៅភាគខាងជើង និងហូរបានលឿនចាក់ចូលទៅស្ទឹងសែន។ ហេតុនេះក្រុងមិនមានបញ្ហាជំនន់ទឹកភ្លៀងនោះទេ។ ដោយឡែក ប្រព័ន្ធលូបង្ហូរទឹកកខ្វក់មានតិចតួចនៅជុំវិញផ្សារកំពង់ប្រណាក ក្នុងសង្កាត់កំពង់ប្រណាក និងតាមផ្លូវកោះកេរនិងផ្លូវម្លូព្រៃ។ ប្រព័ន្ធលូបង្ហូរនេះមិនបានឆ្លងកាត់ការប្រព្រឹត្តិកម្មតាមបែបធម្មជាតិឬស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់នោះទេ គឺបានបង្ហូរចូលដោយផ្ទាល់ទៅស្ទឹងសែន។ ម្យ៉ាងទៀត ការរីកចម្រើននគរូបនីយកម្មនៅផ្នែកកណ្តាលក្រុង ផ្នែកខាងលិចក្រុង និងផ្នែកខាងត្បូងក្រុង ជាពិសេសសំណង់នៅតាមបណ្តោយដងស្ទឹងសែន បានធ្វើឱ្យសំណល់រាវមានការកើនឡើងនិងបានបង្ហូរចូលដោយផ្ទាល់ទៅស្ទឹងសែន។

- កំណត់ទីតាំងសម្រាប់រៀបចំស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ ស្ថិតនៅភូមិកណ្តាល សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ មានផ្ទៃដីប្រមាណ១០ហិកតា
- រៀបចំប្រព័ន្ធលូទឹកភ្លៀងនិងលូទឹកកខ្វក់និងកំណត់ទីតាំងសម្រាប់រៀបចំស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ ស្ថិតនៅភូមិកំពង់ចំលង សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ដែលជាតំបន់នគរូបនីយកម្មថ្មីនៅភាគខាងជើងស្ទឹងសែន
- ចុះកំណត់និយាមកា បោះបង្គោលព្រំ និងលើកផ្លាកសម្គាល់ទីតាំងស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់របស់ក្រុង ដើម្បីការពារការទន្ទ្រានកាន់កាប់ផ្សេងៗ
- រៀបចំនិងពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀងនិងលូទឹកកខ្វក់ឱ្យដាច់ពីគ្នា ដោយតភ្ជាប់ទៅនឹងស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រនិងត្រូវចម្រោះទឹកឱ្យបានស្អាតស្របតាមបទដ្ឋានបច្ចេកទេសអនាម័យមុននឹងបង្ហូរចូលផ្លូវទឹកធម្មជាតិ
- ណែនាំគ្រប់ម្ចាស់សំណង់លំនៅឋាន ឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្មទេសចរណ៍ និងសំណង់សាធារណៈឱ្យអនុវត្តច្បាប់និងបទដ្ឋានបច្ចេកទេសបានល្អក្នុងការរៀបចំឱ្យមានអាងប្រព្រឹត្តិកម្មទឹកកខ្វក់និងអាងបង្គន់អនាម័យត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសមុននឹងបង្ហូរចូលប្រព័ន្ធលូសាធារណៈ
- មន្ត្រីមានសមត្ថកិច្ចជំនាញសហការជាមួយអាជ្ញាធរមូលដ្ឋានត្រូវត្រួតពិនិត្យជាប្រចាំរាល់ការដ្ឋានសំណង់ក្នុងការធ្វើអាងប្រព្រឹត្តិកម្មទឹកកខ្វក់និងអាងបង្គន់អនាម័យ
- គ្រប់គ្រងនិងថែរក្សាឱ្យបានធនធានប្រភពទឹកធម្មជាតិ ដូចជាស្ទឹង អូរ ប្រឡាយ បឹងបួ ផ្លូវទឹក សម្រាប់ជាប្រព័ន្ធបង្ហូរទឹកភ្លៀង អាងស្តុកទឹកជំនន់ និងការប្រព្រឹត្តិកម្មទឹកកខ្វក់តាមបែបធម្មជាតិ
- រៀបចំទំនប់ឬទ្វារទឹកតាមមុខផ្លូវទឹកដែលហូរចូលទៅស្ទឹងសែន ដើម្បីគ្រប់គ្រងនិងការពារទឹកជំនន់និងទឹកភ្លៀង
- រក្សាតុល្យភាពរវាងតំបន់ក្រាលថ្មបេតុងនិងតំបន់បៃតង ដោយលើកទឹកចិត្តប្រជាពលរដ្ឋឱ្យដាំដើមឈើដាំផ្កា រុក្ខជាតិផ្សេងៗ និងរៀបចំសួនច្បារជ្រាបទឹកនៅតាមដីឡូត៍ឯកជនឱ្យបានច្រើន
- សម្អាតបរិស្ថានតាមទីសាធារណៈ ជាពិសេសតាមមាត់ស្ទឹង បឹងបួ និងស្តារផ្លូវទឹកធម្មជាតិនានាព្រមទាំងទប់ស្កាត់ការចោលសំរាមលើផ្ទៃទឹកនិងតាមទីសាធារណៈ
- ទប់ស្កាត់ការលុបបឹងបួនិងផ្លូវទឹកធម្មជាតិក្នុងការយកដីទៅសាងសង់សំណង់និងអភិវឌ្ឍ
- បង្កើតបទប្បញ្ញតិជាក់លាក់ក្នុងការគ្រប់គ្រងសំណល់រឹងនិងរាវនិងទប់ស្កាត់ការបំពុលទឹកដែលបណ្តាលមកពីរោងចក្រ សហគ្រាស សិប្បកម្ម អាជីវកម្មជាដើម
- រៀបចំប្រព័ន្ធឆ្លាត ដើម្បីគ្រប់គ្រងសំណល់រាវ។

## ៤.៧-យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ

ខេត្តព្រះវិហារ ស្ថិតនៅតំបន់ខ្ពង់រាបនិងមានតំបន់ទំនាបតិចតួច ដែលហូរកាត់ដោយទន្លេ ស្ទឹង និងផ្លូវទឹកជាច្រើន ក្នុងនោះមានផ្នែកខ្លះនៅជាប់តំបន់ភ្នំនិងផ្នែកខ្លះទៀតនៅជាប់មាត់ទន្លេ ស្ទឹង ដែលជាហេតុធ្វើឱ្យខេត្តតែងតែទទួលរងគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងអាកាសធាតុត្រជាក់។ ទាំងនេះបានធ្វើឱ្យប៉ះពាល់ដល់ប្រជាជនជាពិសេសអ្នករស់នៅជាប់មាត់ស្ទឹង ខូចខាតដំណាំ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។ ដូចនេះយុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយរួមមាន៖

- កំណត់ទីតាំងសមស្របសម្រាប់ការបង្ការនិងសង្គ្រោះបឋម ក្នុងករណីមានគ្រោះមហន្តរាយធម្មជាតិ
- រៀបចំប្រព័ន្ធគ្រប់គ្រងការពារទឹកជំនន់ ដោយត្រូវការពារនិងអភិរក្សធម្មជាតិប្រណិតមានស្ទឹង អូរ ប្រឡាយ បឹងបួ ប្រកបដោយភាពឆ្លាត ចីរភាព និងបរិយាបន្ន
- ពង្រឹងយន្តការនិងមធ្យោបាយសម្រាប់បង្ការទប់ស្កាត់គ្រោះមហន្តរាយ
- សិក្សានិងរៀបចំផែនការគ្រប់គ្រងការប្រើប្រាស់ទឹកក្រោមដីនិងការប្រើប្រាស់ដី
- រៀបចំប្រព័ន្ធឆ្លាតក្នុងការជម្លៀសចេញពីគ្រោះមហន្តរាយ
- រៀបចំឱ្យមានឧបករណ៍ ប្រព័ន្ធការពារ និងប្រឆាំងអគ្គិភ័យ ព្រមទាំងរៀបចំក្បាលបូមពន្លត់អគ្គិភ័យនៅតាមដងផ្លូវសាធារណៈនិងតាមសំណង់អគារនានា
- តម្រូវឱ្យបំពាក់ឧបករណ៍ការពាររន្ទះនៅតាមសំណង់អគារកម្ពស់ខ្ពស់
- បន្តអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។

### ៤.៨-យុទ្ធសាស្ត្រពង្រឹងអភិបាលកិច្ចល្អ គ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុនៅមូលដ្ឋាន

ការពង្រឹងលើកកម្ពស់សមត្ថភាព ស្ថាប័ន និងមូលធនមនុស្សនៅរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុងក្នុងការសម្របសម្រួលអនុវត្តប្លង់គោលប្រើប្រាស់ដីនេះ និងការគ្រប់គ្រងហិរញ្ញវត្ថុនៅមូលដ្ឋានជាកត្តាសំខាន់ចាំបាច់ និងជាស្នូលនៃវិស័យទេសចរណ៍ សេដ្ឋកិច្ច អភិវឌ្ឍទីក្រុង និងបរិស្ថានដោយចាំបាច់ត្រូវ៖

- សម្របសម្រួលស្ថាប័នពាក់ព័ន្ធឱ្យចែករំលែកព័ត៌មានអំពីគម្រោងដែលត្រូវអនុវត្តនិងគម្រោងដែលត្រូវស្នើឡើងក្នុងក្រុង
- ពង្រឹងមូលធនមនុស្សទាំងនៅថ្នាក់ខេត្តនិងថ្នាក់ក្រុង ជាពិសេសសម្រាប់ការគ្រប់គ្រង ការអភិវឌ្ឍ និងការត្រួតពិនិត្យគម្រោងសាធារណៈ ការគ្រប់គ្រងដីធ្លី ការប្រមូលពន្ធ។ល។
- ពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការប្រើប្រាស់ដីសាធារណៈ ការផ្តល់លិខិតអនុញ្ញាតសាងសង់ ការផ្តល់លិខិតអនុញ្ញាតអភិវឌ្ឍដី ការចុះបញ្ជីដីធ្លី ការចុះបញ្ជីយានយន្ត ការបូមទឹកក្រោមដីរបស់ឯកជន និងការគ្រប់គ្រងបរិស្ថាន
- ពង្រឹងហិរញ្ញវត្ថុនៅមូលដ្ឋានតាមរយៈការប្រមូលចំណូលក្នុងមូលដ្ឋាន ការបែងចែកចំណូលរដ្ឋពីវិស័យទេសចរណ៍ និងប្រភពផ្សេងៗទៀតដល់រដ្ឋបាលមូលដ្ឋានសម្រាប់ប្រើប្រាស់ជាប្រយោជន៍សាធារណៈ ជាពិសេសសម្រាប់ការជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិងការលើកកម្ពស់សោភណភាពនិងកែលម្អបរិស្ថានក្នុងក្រុង។

## ៥-ផែនការសកម្មភាព

ផ្អែកតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជានិងប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារ រដ្ឋបាលក្រុងព្រះវិហារ រដ្ឋបាលខេត្តព្រះវិហារ និងក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធត្រូវអនុវត្តផែនការសកម្មភាពសំខាន់ៗដូចខាងក្រោម៖

## ៥.១-ការរៀបចំបទប្បញ្ញត្តិនគរូបនីយកម្ម

ដើម្បីសម្រេចនូវគោលបំណងនេះ វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវរៀបចំបទប្បញ្ញត្តិនគរូបនីយកម្មរួមមាន៖

- ផែនទីព្រំប្រទល់រដ្ឋបាលភូមិ សង្កាត់ និងហេដ្ឋារចនាសម្ព័ន្ធមានស្រាប់
- ផែនទីកំណត់តំបន់ប្រើប្រាស់ដីនាពេលបច្ចុប្បន្ន
- ផែនការប្រើប្រាស់ដីក្រុងព្រះវិហារ
- ប្លង់លម្អិតនគរូបនីយកម្មនិងបទប្បញ្ញត្តិបច្ចេកទេសសម្រាប់ការគ្រប់គ្រងការអភិវឌ្ឍនិងការសាងសង់
- ផែនទីកំណត់កម្ពស់អគារនិងសន្ទស្សន៍ប្រើប្រាស់ដីតាមតំបន់ប្រើប្រាស់ដីនីមួយៗ
- ផែនទីកំណត់ទីតាំងលម្ហសាធារណៈ ផ្ទៃបៃតង ផ្លូវថ្នល់ កំពង់ផែ ស្ទឹង អូរ ប្រឡាយ បឹងបួ ទំនប់ទឹក ជាដើម
- ផែនទីកំណត់តំបន់អភិវឌ្ឍជាអាទិភាព។

## ៥.២-ការផ្សព្វផ្សាយ

រដ្ឋបាលខេត្តព្រះវិហារ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះវិហារ រដ្ឋបាលក្រុងព្រះវិហារ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងព្រះវិហារ ត្រូវផ្សព្វផ្សាយប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារ ចក្ខុវិស័យឆ្នាំ២០៤០ ជូនដល់មន្ត្រីជំនាញ អ្នកវិនិយោគ និងប្រជាពលរដ្ឋតាមរយៈកិច្ចប្រជុំ សិក្ខាសាលា គេហទំព័រឬបណ្ដាញសង្គម។ល។

## ៥.៣-ការអនុវត្តគម្រោងតាមវិស័យ

គម្រោងតាមវិស័យសំខាន់ៗដែលត្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍក្រុងព្រះវិហារមានដូចខាងក្រោម៖

### ៥.៣.១- ការអភិវឌ្ឍក្រុង

- កែលម្អហេដ្ឋារចនាសម្ព័ន្ធតំបន់កណ្ដាលក្រុង ដូចជាផ្លូវ ភ្លើងបំភ្លឺផ្លូវ ស្ពាន និងសួនច្បារសាធារណៈ
- រៀបចំផែនការប្រើប្រាស់ដីនៅក្នុងសង្កាត់ទាំង២ និងប្លង់លម្អិតនគរូបនីយកម្ម
- បណ្ដុះបណ្ដាលនិងពង្រឹងសមត្ថភាពមូលធនមនុស្សនៅថ្នាក់ក្រោមជាតិលើការងាររៀបចំដែនដីនិងនគរូបនីយកម្ម
- ធ្វើទំនប់ឬទ្វារទឹកតាមមុខផ្លូវទឹកនិងតាមផ្លូវស្របតាមដងស្ទឹងសែនចំនួន៤ទីតាំង ដើម្បីការពារទឹកកខ្វក់កុំឱ្យហូរចូលផ្ទាល់ទៅស្ទឹងសែន
- អនុវត្តគោលការណ៍បំពាក់បរិក្ខារទីក្រុងឆ្លាត
- ប្រើប្រាស់ថាមពលកកើតឡើងវិញ រួមមានថាមពលពន្លឺព្រះអាទិត្យ ថាមពលមកពីទឹកស្ទឹង និងថាមពលមកពីសំណល់រឹង
- ធ្វើផែនការអភិវឌ្ឍនិងអភិរក្សតំបន់ដែនជម្រកសត្វព្រៃគូលែនព្រហ្មទេពនិងតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង

- ថែរក្សា ការពារ កែលម្អ និងអភិវឌ្ឍស្ទឹង ដីចំណីស្ទឹង និងផ្លូវស្របតាមដងស្ទឹង ឱ្យមានសោភណភាព អនាម័យល្អ និងបរិស្ថានល្អ សម្រាប់មនុស្សទាំងអស់គ្នា
- ផ្សព្វផ្សាយឯកសារគតិយុត្តពាក់ព័ន្ធការងាររៀបចំដែនដីនិងនគរូបនីយកម្ម ការងារគ្រប់គ្រងនិងអភិរក្ស តំបន់ដែនជម្រកសត្វព្រៃគូលែនព្រហ្មទេពនិងតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង ជាពិសេសអនុក្រឹត្យស្តីពីការគ្រប់គ្រងអាងទន្លេ
- ពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ៥.៣.២- ការអភិវឌ្ឍការដឹកជញ្ជូន

- សាងសង់ស្ពានថ្មីបន្ថែមដែលមានប្រវែងទទឹងសមស្របសម្រាប់ឆ្លងកាត់ស្ទឹងសែន
- សាងសង់ផ្លូវក្រវាត់ក្រុង ដើម្បីតភ្ជាប់ជាមួយផ្លូវក្រវាត់ក្រុងដែលមានស្រាប់
- កែលម្អបណ្តាញផ្លូវក្នុងក្រុងនិងសាងសង់បណ្តាញផ្លូវក្នុងក្រុង
- លើកកម្ពស់ស្ថាប័ននិងយុទ្ធនាការសម្រាប់ការពារសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- ស្តារនិងជួសជុលផ្លូវឆ្ពោះទៅកាន់តំបន់រមណីយដ្ឋានសំខាន់ៗនិងផ្លូវសម្រាប់ដឹកជញ្ជូនទំនិញ
- សាងសង់និងពង្រីកបន្ថែមផ្លូវសម្រាប់ដឹកកសិផល
- សាងសង់ផ្លូវសម្រាប់តំបន់ឧស្សាហកម្ម
- ពង្រឹងសមត្ថភាពស្ថាប័នសម្រាប់ថែទាំផ្លូវឱ្យមានប្រសិទ្ធភាព។

## ៥.៣.៣- ការអភិវឌ្ឍទេសចរណ៍

- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញផ្លូវទេសចរណ៍តភ្ជាប់ទៅរមណីយដ្ឋានទេសចរណ៍ក្នុងខេត្ត
- រៀបចំនិងអភិវឌ្ឍផ្សាររាត្រី ផ្សារផលិតផលកសិកម្មគ្មានជាតិគីមី
- លើកកម្ពស់គុណភាពទេសចរណ៍តាមរយៈភាពជាដៃគូរវាងរដ្ឋនិងឯកជន
- លើកកម្ពស់សហគមន៍ទេសចរណ៍
- អភិវឌ្ឍនិងលើកកម្ពស់ទេសចរណ៍តាមភូមិនិងទេសចរណ៍ធម្មជាតិ
- បណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍និងការផ្តល់លិខិតអនុញ្ញាតនានា
- សិក្សាលម្អិតលទ្ធភាពទទួលភ្ញៀវទេសចរនិងការគ្រប់គ្រងរមណីយដ្ឋាន
- ធ្វើតារាងតម្លៃសេវាកម្មកម្សាន្ត សេវាស្នាក់នៅ សេវាហូបចុក និងសេវាធ្វើដំណើរ
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីសេវាកម្សាន្ត សេវាស្នាក់នៅ សេវាហូបចុក និងសេវាធ្វើដំណើរ
- បោះពុម្ពផែនទីគោលដៅទេសចរណ៍
- បោះពុម្ពសៀវភៅផ្នត់ទេសចរណ៍ជាភាសាខ្មែរនិងភាសាបរទេសចាំបាច់
- លើកផ្លាកសញ្ញានិងផែនទីបង្ហាញទីតាំងតំបន់ទេសចរណ៍
- រៀបចំកំពង់ផែទូកទេសចរណ៍សម្រាប់ដឹកភ្ញៀវទេសចរទស្សនាតាមដងស្ទឹងសែន

- រៀបចំឱ្យមានទូកទេសចរណ៍ដំណើរកម្សាន្តតាមដងស្ទឹងសែន
- រៀបចំកម្មវិធីសន្ទនាមតិតាមវិទ្យុជាតិអំពីទេសចរណ៍
- រៀបចំចំណតរថយន្តទេសចរណ៍
- រៀបចំបង្គន់សាធារណៈ
- រៀបចំសួនទេសចរណ៍
- បង្កើតកម្មវិធីចុះសម្ភាសន៍ជាមួយអ្នកផ្តល់សេវានិងអ្នកទទួលសេវាទេសចរណ៍
- រៀបចំសម្បទាទេសចរណ៍ថ្មីៗបន្ថែមកម្រិតផ្កាយ រួមមានសណ្ឋាគារ ភោជនីយដ្ឋាន
- បង្កើតផលិតផលទេសចរណ៍ថ្មីៗបន្ថែម
- សាងសង់មជ្ឈមណ្ឌលនិងបញ្ជរផ្តល់ព័ត៌មានទេសចរណ៍
- រៀបចំសួនកុមារនិងកន្លែងហាត់ប្រាណ
- ពង្រឹងភ្នាក់ងារគ្រប់គ្រងនិងផ្តល់សេវាព័ត៌មានដល់ភ្ញៀវទេសចរ។

## ៥.៣.៤- ការអភិវឌ្ឍពាណិជ្ជកម្ម

- កែលម្អនិងរៀបចំផ្សារមានស្រាប់
- រៀបចំផែនការមេទាក់ទាញការវិនិយោគនិងគាំទ្រដល់ការអភិវឌ្ឍពាណិជ្ជកម្មនិងធុរកិច្ច
- កសាងផ្លូវសម្រាប់សម្រួលដល់ការដឹកទំនិញចេញចូល
- ផ្គត់ផ្គង់ប្រព័ន្ធអគ្គិសនីសម្រាប់ប្រើប្រាស់ក្នុងតំបន់ពាណិជ្ជកម្ម ដូចជាការបំភ្លឺនិងការលើកដាក់ទំនិញ
- កសាងផ្សារសម្រាប់ដោះដូរទំនិញនិងសម្រាប់ឃ្លាំងស្តុកនិងរក្សាទុកទំនិញ។

## ៥.៣.៥- ការអភិវឌ្ឍឧស្សាហកម្ម

- រៀបចំបទប្បញ្ញត្តិសម្រាប់ការសាងសង់ក្នុងតំបន់ឧស្សាហកម្ម ដើម្បីឆ្លើយតបតម្រូវការជាក់ស្តែង
- គ្រប់គ្រងការប្រមូលសំណល់រឹងនិងរាវដែលចេញពីតំបន់ឧស្សាហកម្ម
- រៀបចំតំបន់ដឹកជញ្ជូន ចំណតរថយន្ត កន្លែងលើកដាក់ទំនិញ ផ្លូវដឹកជញ្ជូនទំនិញ ច្រកចេញចូល និងទិសដៅចរាចរណ៍ នៃតំបន់ឧស្សាហកម្មនិងតំបន់ជុំវិញ
- ពង្រីកបន្ថែមផ្លូវធ្វើដំណើរ សួនច្បារតាមបណ្តោយផ្លូវ និងផ្លូវថ្មើរជើង សម្រាប់តំបន់ឧស្សាហកម្ម
- អភិវឌ្ឍមូលធនមនុស្សនិងបង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលឧស្សាហកម្ម
- ចលនាភូមិមួយផលិតផលមួយ រួមមានស្វាយចន្ទី ចេក ដំឡូងជាដើម
- អភិវឌ្ឍភូមិផលិតកម្មនិងតាំងពិព័រណ៍ផលិតផលឧស្សាហកម្ម
- រៀបចំផែនការអភិវឌ្ឍតំបន់ឧស្សាហកម្មភាគខាងកើតក្រុងដែលមិនប៉ះពាល់ដល់ស្ទឹងសែននិងតំបន់ជុំវិញ
- ផ្តល់លទ្ធភាពដល់ប្រជាជនមូលដ្ឋានអភិវឌ្ឍនិងកែច្នៃផលិតផលកសិកម្មមុននាំចេញ ដើម្បីទទួលបានតម្លៃបន្ថែម។

### ៥.៣.៦- ការអភិវឌ្ឍកសិកម្មនិងការផ្សព្វផ្សាយផលិតផលក្នុងស្រុក

- អភិវឌ្ឍមូលធនមនុស្សនិងបង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលក្នុងស្រុក
- ចលនាភូមិមួយផលិតផលមួយ
- អភិវឌ្ឍភូមិផលិតកម្មនិងតាំងពិព័រណ៍ផលិតផលក្នុងស្រុក
- ផ្សព្វផ្សាយកសិផលធម្មជាតិនិងគ្មានជាតិគីមី។

### ៥.៣.៧- ការគ្រប់គ្រងធនធានទឹកនិងការផ្គត់ផ្គង់ទឹកស្អាត

- ត្រួតពិនិត្យអ្នកប្រើប្រាស់ទឹកស្អាត
- បំពាក់បំពង់បង្ហូរទឹកថ្មីជំនួសបំពង់ទឹកចាស់ៗ
- សិក្សាយុទ្ធសាស្ត្រសមាហរណកម្មនៃការគ្រប់គ្រងធនធានទឹកពីស្ទឹងសែននិងទឹកពីបឹងទំនប់៩៥
- អភិវឌ្ឍប្រព័ន្ធថ្មីផ្គត់ផ្គង់ទឹកស្អាតដល់តំបន់ពង្រីកក្រុងថ្មី
- អភិវឌ្ឍធនធានទឹកស្អាតនៅចំណុចបឹងទំនប់៩៥
- អភិវឌ្ឍស្ថានីយចម្រោះទឹកស្អាតនិងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។

### ៥.៣.៨- ការផ្គត់ផ្គង់ថាមពលអគ្គិសនី ទូរគមនាគមន៍ បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍

- ពង្រីកបណ្តាញអគ្គិសនីដល់គ្រប់ភូមិ
- តម្លើងនិងជួសជុលបណ្តាញអគ្គិសនី ភ្លើងបំភ្លឺផ្លូវ ជាពិសេសមហាវិថី វិថី និងផ្លូវស្របតាមដងស្ទឹង
- ធ្វើផែនការប្រើប្រាស់ថាមពលអគ្គិសនីប្រកបដោយប្រសិទ្ធភាពខ្ពស់
- ធ្វើផែនការផ្គត់ផ្គង់ថាមពលអគ្គិសនីដល់តំបន់ពង្រីកក្រុងថ្មី
- ពិនិត្យឡើងវិញតម្លៃអគ្គិសនី
- ពិនិត្យនិងរៀបចំបទបញ្ញត្តិអំពីការផ្គត់ផ្គង់ថាមពលអគ្គិសនី ដើម្បីកាត់បន្ថយបន្ទុកលើបរិស្ថាន
- ស្រាវជ្រាវរកប្រភពថាមពលអគ្គិសនីប្រកបដោយចីរភាព
- ពង្រីកបណ្តាញផ្គត់ផ្គង់ទូរគមនាគមន៍ បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍។

### ៥.៣.៩- ការគ្រប់គ្រងសំណល់រឹង

- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងសំណល់រឹង
- ពង្រឹងប្រព័ន្ធប្រមូលសំណល់រឹង
- ពង្រឹងក្រុមការងារតាមដាននិងត្រួតពិនិត្យការប្រមូលសំរាម
- ពង្រឹងក្រុមកម្មករឬបុគ្គលិកសម្អាតក្រុង
- រៀបចំសេចក្តីជូនដំណឹងនិងលើកផ្ទាំងប៉ាណូកំណត់ពេលវេលាប្រមូលសំរាមតាមគោលដៅ
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់លើតម្លៃសេវាប្រមូលសំរាម
- អប់រំនិងផ្សព្វផ្សាយអំពីសំណល់គ្រោះថ្នាក់

- រៀបចំសេចក្តីណែនាំស្តីពីការទុកដាក់សំណល់គ្រោះថ្នាក់
- លើកផ្ទាំងប៉ាណូអប់រំនិងផ្សព្វផ្សាយតាមទីសាធារណៈនិងផ្សព្វផ្សាយតាមវិទ្យុនិងទូរទស្សន៍
- ធ្វើកិច្ចសន្យាគាំពារបរិស្ថានលើអាជីវកម្មពាក់ព័ន្ធនឹងសំណល់គ្រោះថ្នាក់
- ត្រួតពិនិត្យនិងតាមដានលើអាជីវកម្មពាក់ព័ន្ធនឹងការបញ្ចេញសំណល់គ្រោះថ្នាក់
- រៀបចំសេចក្តីជូនដំណឹងអំពីការញែកសំរាម
- ផ្សព្វផ្សាយនិងណែនាំអំពីការញែកសំរាមនិងអនុវត្តជាក់ស្តែងដោយញែកធុងសំរាម
- អនុវត្តវិធានការច្បាប់និងផាកពិន័យនៃការគ្រប់គ្រងសំណល់រឹង
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីផលិតខ្លឹមសារអប់រំអំពីបរិស្ថាន។

## ៥.៣.១០- ការគ្រប់គ្រងសំណល់រាវនិងទឹកកខ្វក់

- ណែនាំគ្រប់ម្ចាស់សំណង់ អគារសេវាកម្មសាធារណៈនិងឯកជន ឱ្យរៀបចំអាងបង្គន់អនាម័យនិងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ ឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស
- សាងសង់ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ចំនួន១កន្លែងនៅភូមិសំរោង ក្នុងសង្កាត់កំពង់ប្រណាកនិងចំនួន១កន្លែងទៀតនៅភូមិកំពង់ចំលង ក្នុងសង្កាត់កំពង់ប្រណាក ព្រមទាំងសាងសង់ប្រព័ន្ធលូបង្ហូរទឹកកខ្វក់
- រៀបចំនិងពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀងនិងលូទឹកកខ្វក់ឱ្យដាច់ពីគ្នាដោយតភ្ជាប់ទៅស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់
- ផ្សព្វផ្សាយអំពីគោលការណ៍អនាម័យនិងបរិស្ថាន។

## ៥.៣.១១- ការបង្ការទប់ស្កាត់គ្រោះមហន្តរាយ

- ពង្រឹងសមត្ថភាពស្ថាប័ននិងកសាងផែនទីតំបន់ហានិភ័យ
- បង្កើតប្រព័ន្ធព័ត៌មានគ្រប់គ្រងគ្រោះមហន្តរាយ
- សង់សំណង់ការពារច្រាំងស្ទឹង បឹងបួឱ្យបានរឹងមាំនិងមាននីវ៉ូខ្ពស់ជាងកម្ពស់ទឹកដែលធ្លាប់ឡើងខ្ពស់បំផុតដើម្បីការពារទឹកជំនន់
- រៀបចំផែនការបន្សាំនឹងការប្រែប្រួលអាកាសធាតុនិងគ្រប់គ្រងគ្រោះមហន្តរាយ ជាពិសេសគ្រោះទឹកជំនន់
- លើកទឹកចិត្តនិងទាក់ទាញការវិនិយោគរបស់ផ្នែកឯកជនក្នុងការកសាងនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបរិស្ថាននិងភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

## ៥.៤-ការអនុវត្តគម្រោងរយៈពេលខ្លី មធ្យម និងវែង

ផែនការសកម្មភាពនៃប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារត្រូវចែកចេញជាបីដំណាក់កាលគឺសម្រាប់ការអនុវត្តរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែងមានដូចខាងក្រោម៖

### ៥.៤.១- ការអនុវត្តគម្រោងរយៈពេលខ្លីឬគម្រោងអាទិភាព

- កែលម្អហេដ្ឋារចនាសម្ព័ន្ធតំបន់កណ្ដាលក្រុង ដូចជាផ្លូវ ភ្លើងបំភ្លឺផ្លូវ ស្ពាន និងសួនច្បារសាធារណៈ
- សាងសង់ផ្លូវក្រវាត់ក្រុង ដើម្បីតភ្ជាប់ជាមួយផ្លូវក្រវាត់ក្រុងដែលមានស្រាប់
- កែលម្អផ្លូវមេនិងផ្លូវចែកចាយក្នុងតំបន់កណ្ដាលក្រុង
- ការពារ កែលម្អ ស្ដារ និងកសាងខឿនទប់ការបាក់ច្រាំងទាំងសងខាងនៃស្ទឹងសែន
- ការពារនិងថែរក្សាដីចំណីស្ទឹងសែន
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងបណ្ដាញផ្លូវទេសចរណ៍តភ្ជាប់ទៅរមណីយដ្ឋានទេសចរណ៍ក្នុងខេត្ត
- ស្ដារនិងជួសជុលផ្លូវទៅកាន់រមណីយដ្ឋានសំខាន់ៗ
- លើកកម្ពស់គុណភាពទេសចរណ៍តាមរយៈភាពជាដៃគូរវាងរដ្ឋនិងឯកជន
- កែលម្អផ្សារកំពង់ប្រណាកឱ្យមានកន្លែងទុកដាក់សំរាម លូបង្ហូរទឹកកខ្វក់ ចំណតរថយន្ត កន្លែងលើកដាក់ទំនិញ និងកន្លែងភ្ញៀវឡើងចុះរថយន្ត
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសម្រាប់តំបន់ឧស្សាហកម្ម
- រៀបចំតំបន់ដឹកជញ្ជូន ចំណតរថយន្ត កន្លែងលើកដាក់ទំនិញ ផ្លូវដឹកជញ្ជូនទំនិញ ច្រកចេញចូល និងទិសដៅចរាចរណ៍ នៃតំបន់ឧស្សាហកម្មនិងតំបន់ជុំវិញ
- អភិវឌ្ឍមូលធនមនុស្សនិងបង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលក្នុងស្រុក
- លើកទឹកចិត្តការអភិវឌ្ឍឧស្សាហកម្មកែច្នៃកសិផល
- ស្ដារនិងជួសជុលផ្លូវទៅកាន់ទីតាំងថ្មីសម្រាប់ទុកដាក់សំណល់រឹង
- អនុវត្តគោលការណ៍ "កាត់បន្ថយការប្រើប្រាស់ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃប្រើប្រាស់ឡើងវិញ" សម្រាប់ការគ្រប់គ្រងសំណល់រឹង
- អភិវឌ្ឍប្រព័ន្ធបង្ហូរទឹកកខ្វក់នៅតំបន់កណ្ដាលក្រុង
- សាងសង់ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ចំនួន១កន្លែងនៅភូមិសំរោង ក្នុងសង្កាត់កំពង់ប្រណាក
- បង្កើតភាពជាដៃគូរវាងរដ្ឋនិងឯកជន លើការគ្រប់គ្រងសំណល់រឹងនិងរាវ
- លើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន
- អភិរក្សធនធានធម្មជាតិក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែនព្រហ្មទេពនិងតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង
- លើកកម្ពស់ការអភិវឌ្ឍអេកូទេសចរណ៍ធម្មជាតិក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព
- លើកកម្ពស់ការអភិវឌ្ឍអេកូទេសចរណ៍ធម្មជាតិ ប្រវត្តិសាស្ត្រ និងសាសនា ក្នុងតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង
- សិក្សាផែនការអភិវឌ្ឍការដឹកជញ្ជូននិងភស្តុភារកម្មគ្រប់ជ្រុងជ្រោយរវាងខេត្តព្រះវិហារ រាជធានីភ្នំពេញ ច្រកទ្វារព្រំដែន
- រៀបចំប្រព័ន្ធត្រួតពិនិត្យតាមព្រំដែនឱ្យមានលក្ខណៈអន្តរជាតិប្រកបដោយប្រសិទ្ធភាព
- រៀបចំនិងពង្រឹងការអនុវត្តច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

### ៥.៤.២- ការអនុវត្តគម្រោងរយៈពេលមធ្យម

- គម្រោងសំខាន់ៗតាមវិស័យក្រៅពីគម្រោងអាទិភាព។

### ៥.៤.៣- ការអនុវត្តគម្រោងរយៈពេលវែង

- ដោះស្រាយសំណង់មិនរៀបរយនៅលើដីសាធារណៈរបស់រដ្ឋនិងដីឯកជនរបស់រដ្ឋ ជាពិសេសនៅលើដីចំណីស្ទឹងសែន ដីចំណីបឹងទំនប់៩៥ ដីចំណីបឹងឫ ដីចំណីអូរប្រឡាយ និងដីចំណីផ្លូវ ជាពិសេសសំណង់នៅក្នុងដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព តំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង និងតំបន់ព្រៃឈើតាមសារាចរលេខ០៣ស.រ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ក្នុងខេត្ត ក្រុង និងទីប្រជុំជន
- សិក្សាលទ្ធភាពនិងរៀបចំគម្រោងសម្បទានដីសង្គមកិច្ចសម្រាប់ប្រជាជនក្រីក្រក្នុងក្រុងនិងប្រជាជនរស់នៅក្នុងសំណង់មិនរៀបរយគ្រប់កន្លែង
- គម្រោងពង្រីកក្រុងចាំបាច់ត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធសមស្របជាមុន ដូចជាបណ្តាញផ្លូវ ប្រព័ន្ធលូបង្ហូរទឹកកខ្វក់និងលូទឹកភ្លៀង ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ ការកំណត់តំបន់ប្រើប្រាស់ដី និងការអភិវឌ្ឍនាពេលអនាគត។

## ៦-ធនធានហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារ មានជាអាទិ៍៖

- ថវិកាជាតិ
- ថវិកាអភិវឌ្ឍន៍និងវិនិយោគដោយផ្នែកឯកជន
- ថវិកាវិនិយោគរវាងរដ្ឋនិងឯកជន
- ថវិកាហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ថវិកាពីការចូលរួមរបស់ប្រជាពលរដ្ឋ សហគមន៍ និងសប្បុរសជន។

## ៧-ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ

### ៧.១-យន្តការ

យន្តការថ្នាក់ជាតិសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារ ចក្ខុវិស័យឆ្នាំ២០៤០ មាន : ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួង ស្ថាប័នតាមវិស័យរបស់រដ្ឋ។

យន្តការថ្នាក់ក្រោមជាតិសម្រាប់អនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារ ចក្ខុវិស័យឆ្នាំ២០៤០ មាន : រដ្ឋបាលខេត្តព្រះវិហារ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះវិហារ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះវិហារ មន្ទីរ អង្គភាពពាក់ព័ន្ធជុំវិញខេត្តព្រះវិហារ រដ្ឋបាលក្រុងព្រះវិហារ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងព្រះវិហារ និងអាជ្ញាធរសង្កាត់និងភូមិ។

## ៧.២-គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារចក្ខុវិស័យឆ្នាំ ២០៤០ ត្រូវបានធ្វើឡើងដោយផ្អែកទៅលើគោលនយោបាយ ច្បាប់ និងក្របខ័ណ្ឌគតិយុត្ត មានជាអាទិ៍ គោលនយោបាយដីធ្លី "**សៀវភៅសដីធ្លី**" គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយជាតិស្តីពីលំនៅឋាន ច្បាប់ភូមិបាល ច្បាប់ស្តីពីសំណង់ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីអស្សាមិករណ៍ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យស្តីពីការគ្រប់គ្រងអាងទន្លេ អនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ព្រះរាជក្រឹត្យស្តីពីការបង្កើតដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព អនុក្រឹត្យស្តីពីការបង្កើតតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង អនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ និងសេចក្តីសម្រេចស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ៧.៣-ភារកិច្ច នីតិវិធី និងគោលការណ៍

រដ្ឋបាលខេត្តព្រះវិហារ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះវិហារ មន្ទីរ អង្គភាពពាក់ព័ន្ធជុំវិញខេត្តព្រះវិហារ រដ្ឋបាលក្រុងព្រះវិហារ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងព្រះវិហារ និងអាជ្ញាធរសង្កាត់និងភូមិមានតួនាទីនិងភារកិច្ចៈ

- ទទួលខុសត្រូវក្នុងការរៀបចំផែនការសកម្មភាពលម្អិតនៃគម្រោងអភិវឌ្ឍនានាសម្រាប់ការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារដោយមានការចូលរួមពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ផ្នែកឯកជន ដៃគូអភិវឌ្ឍ និងសហគមន៍មូលដ្ឋាន។ ផែនការសកម្មភាពលម្អិតខាងលើត្រូវកំណត់នូវគោលបំណង គោលដៅ សកម្មភាព ពេលវេលា ធនធានហិរញ្ញវត្ថុ ការទទួលខុសត្រូវ និងសូចនាករសំខាន់ៗសម្រាប់ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ ព្រមទាំងត្រូវមានសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍ៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល ប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារ ផែនការប្រើប្រាស់ដីថ្នាក់សង្កាត់ និងប្លង់លម្អិតនគរូបនីយកម្ម
- ត្រូវធ្វើបច្ចុប្បន្នកម្មប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារក្នុងរយៈពេល៥ឆ្នាំម្តងស្របតាមគោលការណ៍ និងនីតិវិធីជាធរមានឬតាមពេលវេលានិងតម្រូវការចាំបាច់ សំដៅបម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ
- ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំនៃការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះវិហារ ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ដើម្បីធ្វើការបូកសរុបនិងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល។

គោលការណ៍នៃការត្រួតពិនិត្យនិងការវាយតម្លៃត្រូវផ្អែកលើសូចនាករនៃការរៀបចំដែនដីនិងនគរូបនីយកម្ម និងសូចនាករតាមវិស័យ ដើម្បីបញ្ជាក់អំពីប្រសិទ្ធភាពនៃការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារក្នុងការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចប្រកបដោយចីរភាព។

## ៨-សេចក្តីសន្និដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ទទួលបាននូវសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ព្រមទាំងការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យតាមរយៈការអនុវត្តគោលនយោបាយ ឈ្នះ ឈ្នះនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។

ប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារត្រូវបានរៀបចំឡើងនិងសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការគឺជាឧបករណ៍គតិយុត្តគោលសម្រាប់ការអនុវត្តនិងការសម្របសម្រួលស្ថាប័នពាក់ព័ន្ធតាមវិស័យដ៏មានសារៈសំខាន់សម្រាប់ការអនុវត្តនិងការសម្របសម្រួលស្ថាប័ន ពាក់ព័ន្ធតាមវិស័យ ដើម្បីធានាសម្រេចបានចក្ខុវិស័យដល់ឆ្នាំ២០៤០ សំដៅរៀបចំនិងអភិវឌ្ឍក្រុងព្រះវិហារជា "**មជ្ឈមណ្ឌលពហុសេវាកម្មប្រពៃនៃតំបន់បេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រពិភពលោក និងតំបន់បេតិកភណ្ឌធម្មជាតិពិសិដ្ឋ និងជាមជ្ឈមណ្ឌលទេសចរណ៍ ធុរកិច្ច និងកសិឧស្សាហកម្មប្រកបដោយសុខដុមរមនា**" តាមរយៈការរៀបចំនិងការជំរុញ: ១)គ្រប់គ្រង ការពារ និងអភិរក្ស បេតិកភណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រ ធនធានធម្មជាតិ និងបរិស្ថាន ប្រកបដោយប្រសិទ្ធភាព ចីរភាព និងបរិយាបន្ន ២)ស្តារនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការអភិវឌ្ឍ ការប្រើប្រាស់ដី និងនគរូបនីយកម្ម ប្រកបដោយជីវភាពនិងសុខដុមរមនា ៣)អភិវឌ្ឍធុរកិច្ច សេវាកម្ម និងផលិតផលទេសចរណ៍សម្បូរបែប ប្រកបដោយគុណភាពនិងភាពទាក់ទាញ ដែលភ្ញៀវទេសចរមានអារម្មណ៍ជិតស្និតទៅនឹងប្រវត្តិសាស្ត្រ វប្បធម៌ខ្មែរ និងធម្មជាតិ ៤)អភិវឌ្ឍកសិកម្មនិងឧស្សាហកម្មប្រកបដោយគុណភាព និង ៥)លើកកម្ពស់អភិបាលកិច្ចល្អ សេដ្ឋកិច្ចនិងសង្គមឌីជីថល និងអភិវឌ្ឍមូលធនមនុស្ស កិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈល្អប្រសើរ ដើម្បីរួមចំណែកសម្រេចចក្ខុវិស័យកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ថ្ងៃ សុក្រ ១៣កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**ជា សុផារ៉ា**

## អនុសាសន៍

ដើម្បីឱ្យប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ រដ្ឋបាលខេត្តព្រះវិហារនិងរដ្ឋបាលក្រុងព្រះវិហារត្រូវយកចិត្តទុកដាក់៖

ទី១. អនុវត្តបទប្បញ្ញត្តិប្រើប្រាស់ដីតាមតំបន់នីមួយៗ និងត្រូវបន្តរៀបចំផែនការប្រើប្រាស់ដី ព្រមទាំងប្លង់លម្អិតនគរូបនីយកម្ម ចុះបញ្ជីដីធ្លីស្របតាមប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារឱ្យបានច្បាស់លាស់ និងរៀបចំបទប្បញ្ញត្តិនានាក្នុងការគ្រប់គ្រងនិងប្រើប្រាស់ដីនិងសំណង់ឱ្យមានប្រសិទ្ធភាព។

ទី២. រៀបចំផែនការសកម្មភាពនិងគម្រោងវិនិយោគតាមលំដាប់អាទិភាព ដើម្បីផ្សព្វផ្សាយ កៀរគរដៃគូអភិវឌ្ឍនិងអ្នកវិនិយោគ ស្របតាមច្បាប់វិនិយោគនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ទី៣. លើកកម្ពស់សមត្ថភាពមន្ត្រីនិងបណ្តុះបណ្តាលមូលធនមនុស្សថ្នាក់ក្រុងនិងថ្នាក់ខេត្ត ដើម្បីធានាការគ្រប់គ្រងនិងអភិបាលកិច្ចល្អ។

ទី៤. តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ព្រមទាំងត្រូវធ្វើបច្ចុប្បន្នកម្មប្លង់គោលប្រើប្រាស់ដីនេះ ដើម្បីស្នើសុំសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ទី៥. តាមដាន ត្រួតពិនិត្យ និងទប់ស្កាត់បទល្មើសក្នុងការសាងសង់ ការប្រើប្រាស់ដី និងការអភិវឌ្ឍដីធ្លីដែលមិនគោរពតាមប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ទី៦. រៀបចំកញ្ចប់ថវិកាថ្នាក់ខេត្តនិងថ្នាក់ក្រុងសម្រាប់អនុវត្តគម្រោងផែនការជួសជុល ថែទាំ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជន និងលម្ហសាធារណៈនិងផ្ទៃបៃតង។

ទី៧. ស្នើសុំសហការនិងគាំទ្រពីគ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីធានាការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារឱ្យមានប្រសិទ្ធភាព ចីរភាព តុល្យភាព និងសមាហរណកម្មល្អប្រសើរ។

៚

## សទ្ទានុក្រម

**ការត្រួតពិនិត្យការអភិវឌ្ឍ** សំដៅដល់ការត្រួតពិនិត្យការអនុវត្តស្របតាមប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងស្របតាមបទប្បញ្ញត្តិជាធរមាន។

**ជ្រោះ** សំដៅដល់ជ្រលងឬល្បាក់ទឹកធម្មជាតិដែលកើតឡើងដោយសារបាតុភូតធម្មជាតិនៃការហូរច្រោះដោយសារចរន្តទឹកពីតំបន់ភ្នំឬតំបន់ខ្ពង់រាប។

**តំបន់លម្ហសាធារណៈនិងផ្ទៃបៃតង** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់បម្រើដល់ការសម្រាក ការលម្ហែ ការកម្សាន្ត និងពិធីសាធារណៈនានា ដូចជាឧទ្យាន សួនច្បារ សួនសត្វ សួនកុមារ កន្លែងក្មេងលេង សួនយុវជន សួនមនុស្សចាស់។ល។ ដែលត្រូវបានរៀបចំនិងសាងសង់សម្រាប់បម្រើដល់សាធារណជន។

**តំបន់ស្នូលនៃការអភិវឌ្ឍ** សំដៅដល់តំបន់ដែលមានសក្តានុពលខ្ពស់ឬតំបន់ដែលមានការអភិវឌ្ឍខ្ពស់សម្រាប់គាំទ្រដល់តំបន់ដែលមានសក្តានុពលទាប។

**ទន្លេ** សំដៅដល់ផ្លូវទឹកធម្មជាតិដែលទទួលប្រភពទឹកមកពីស្ទឹង ព្រែក ជ្រោះ អូរ ទឹកក្រោមដី និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចាក់ទៅសមុទ្រ។

**ទីក្រុង** សំដៅដល់រាជធានី ក្រុង និងទីប្រជុំជន។ ទីក្រុងត្រូវបានធ្វើចំណាត់ថ្នាក់ជាទីក្រុងប្រភេទធំ ប្រភេទមធ្យម និងប្រភេទតូចស្របតាមលក្ខខណ្ឌនៃចំនួនប្រជាជន ដង់ស៊ីតេប្រជាជន សមាមាត្រអ្នកធ្វើការមិនមែនជាកសិករ មុខងារទីក្រុង និងរចនាសម្ព័ន្ធរូបវន្តទីក្រុង។ល។

**ទឹកកខ្វក់** សំដៅដល់ទឹកដែលបានប្រែប្រួលចរិតលក្ខណៈដើមរបស់វា ក្រោយពីការប្រើប្រាស់រួច មានដូចជាទឹកសំណល់ពីផ្ទះបាយ បន្ទប់ទឹក ការបោកគក់ឬការលាងសម្អាតនានា និងទឹកសំណល់ពីបង្គន់អនាម័យ រួមទាំងទឹកនោមនិងលាមកដែលបញ្ចេញពីលំនៅឋាន បុរីលំនៅឋាន ទីក្រុងរណប អគារអាជីវកម្ម អគារពាណិជ្ជកម្ម សេវាកម្ម និងតំបន់រមណីយដ្ឋានឬមជ្ឈមណ្ឌលកម្សាន្ត។

**ទឹកក្រោមដី** សំដៅដល់ទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មតូចធំនិងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត។

**នគរូបនីយកម្ម** សំដៅដល់សិល្បៈ វិទ្យាសាស្ត្រ និងបច្ចេកទេសនៃការធ្វើផែនការរូបវន្តទីក្រុង ការអភិវឌ្ឍ ការអភិរក្សការគ្រប់គ្រងការអភិវឌ្ឍ ការសាងសង់ និងការកែលម្អនៅក្នុងទីក្រុងនិងតំបន់ជុំវិញ ព្រមទាំងតំបន់ទទួលឥទ្ធិពលក្នុងគោលបំណងទទួលបាននូវចីរភាព តុល្យភាព សុខុមាលភាព សោភណភាព សមធម៌ និងសមាហរណកម្ម។

**បណ្តាញបៃតង** សំដៅដល់សួនសាធារណៈនិងដើមឈើដែលរៀបចំប្រទាក់ក្រឡាគ្នាតាមបង្អែមផ្លូវភ្ជាប់ទៅសួនទីក្រុង។

**បឹងបួ** សំដៅដល់ល្ហាលទឹកធំល្វឹងល្វើយកើតពីទីជម្រាលឬជម្រៅធម្មជាតិដែលអាចមានទឹកឬគ្មានទឹកទៅតាមរដូវកាលនិងមានប្រភពមកពីទន្លេ ស្ទឹង ព្រែក ឬពីតំបន់ផ្ទៃរងទឹកភ្លៀង។

**ប៉ូលអភិវឌ្ឍ** សំដៅដល់តំបន់ដែលមានសក្ដានុពលខ្ពស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។

**ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់** សំដៅដល់ប្រឡាយចំហ អាងស្តុក ស្ថានីយបូមលូឬទឹកភ្លៀង បណ្ដាញលូមេ បណ្ដាញលូមេរង ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ រួមមានតាមលក្ខណៈបច្ចេកវិទ្យាឬលក្ខណៈធម្មជាតិ។

**ប្រព័ន្ធលូ** សំដៅដល់បណ្ដាញប្រមូលនិងបង្ហូរទឹកកខ្វក់ រួមមានតំណភ្ជាប់ អណ្ដូងលូ និងបណ្ដាញលូ(បណ្ដាញលូរួម បណ្ដាញលូដាច់ដោយឡែក បណ្ដាញលូមេ បណ្ដាញលូមេរង បណ្ដាញលូខ្នែង និងបណ្ដាញលូខ្នែងរង)។

**ប្រភេទដីកម្រិតការសាងសង់** សំដៅដល់ប្រភេទដីដែលត្រូវគ្រប់គ្រងពិសេសចំពោះការសាងសង់។ ប្រភេទដីនេះត្រូវបានបែងចែកជាតំបន់កសិកម្ម តំបន់ព្រៃឈើ តំបន់ធនធានទឹក តំបន់ការពារ និងតំបន់ផ្សេងៗមួយចំនួនទៀតស្របតាមភូមិសាស្ត្រជាក់ស្ដែង។

**ប្រភេទដីអាចសាងសង់បាន** សំដៅដល់ប្រភេទដីដែលជំរុញឱ្យមានការអភិវឌ្ឍនិងការសាងសង់លើគ្រប់វិស័យ។ ប្រភេទដីនេះត្រូវបានបែងចែកជាតំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់ចម្រុះ តំបន់ដឹកជញ្ជូន តំបន់សេវាកម្មទេសចរណ៍ តំបន់រដ្ឋបាលនិងសេវាសាធារណៈ តំបន់លម្ហសាធារណៈនិងផ្ទៃបៃតង តំបន់វប្បធម៌និងសាសនា និងតំបន់ផ្សេងៗមួយចំនួនទៀតស្របតាមភូមិសាស្ត្រជាក់ស្ដែង។

**ប្លង់គោលប្រើប្រាស់ដីឬប្លង់គោល** សំដៅដល់ផែនការដែលកំណត់អំពីចក្ខុវិស័យនិងយុទ្ធសាស្ត្ររួបសម្រាប់ការអភិវឌ្ឍរូបវន្តនិងកំណត់ពីប្រភេទនៃការប្រើប្រាស់ដី(ប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់) ព្រមទាំងបង្ហាញអំពីទម្រង់ទីក្រុង បណ្ដាញហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងគមនាគមន៍សំខាន់ៗនៃទីក្រុង ព្រមទាំងការធ្វើសមាហរណកម្ម។ ប្លង់គោលប្រើប្រាស់ដីត្រូវភ្ជាប់មកជាមួយនូវផែនការសកម្មភាពសម្រាប់អភិវឌ្ឍនិងអភិរក្សទីក្រុងទៅតាមលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។ ប្លង់គោលប្រើប្រាស់ដីគឺជាប្លង់ដែលត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

**ប្លង់លម្អិតនគរូបនីយកម្ម** សំដៅដល់ប្លង់វិលេចទីតាំងនៃតំបន់ណាមួយក្នុងទីក្រុងឬជាគម្រោងអភិវឌ្ឍទីក្រុង ដើម្បីបង្ហាញអំពីយុទ្ធសាស្ត្ររូបបន្តលម្អិតនៃការរៀបចំផ្នែក ទីតាំង ឬតំបន់ប្រើប្រាស់ដីណាមួយឬច្រើនទីក្រុងដែលរួមមានការបង្ហាញអំពីការរៀបចំការរចនាទម្រង់ រូបរាង និងសោភណភាពនៃរចនាសម្ព័ន្ធរូបវន្តសម្រាប់ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់តាមរយៈគំនូរឬរូបសំណាក។ ប្លង់លម្អិតនគរូបនីយកម្មត្រូវគោរពតាមផែនការប្រើប្រាស់ដី។

**ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍** សំដៅដល់អនុបាតរវាងផ្ទៃក្រឡាបាតសំណង់ជាន់ផ្ទាល់ដីនិងផ្ទៃក្រឡាដីឡូត៍គិតជាភាគរយ។

**ផែនការប្រើប្រាស់ដី** សំដៅដល់ផែនការលម្អិតចេញពីប្លង់គោលប្រើប្រាស់ដីដែលកំណត់អំពីប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី និងកំណត់អំពីបទបញ្ញានៃការប្រើប្រាស់ដីជាក់ស្ដែង ការសាងសង់ ការអភិវឌ្ឍដី និងការអភិរក្សក្នុងតំបន់នីមួយៗ ព្រមទាំងកំណត់អំពីបណ្ដាញគមនាគមន៍និងការធ្វើសមាហរណកម្ម។ ផែនការប្រើប្រាស់ដីគឺជាផែនការដែលត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

**ផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់** សំដៅដល់ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ទាំងមូល ទាំងដីរដ្ឋ ទាំងដីឯកជន ដោយប៉ាន់ប្រមាណពីសក្ដានុពលដីនិងធនធានទឹក លទ្ធភាពផ្សេងៗក្នុងការប្រើប្រាស់ដី ព្រមទាំងលក្ខខណ្ឌសេដ្ឋកិច្ចនិងសង្គមកិច្ច ដើម្បីធ្វើការជ្រើសរើសនូវជម្រើសសមស្របក្នុងការប្រើប្រាស់ដី។

**ផែនការរៀបចំដែនដីថ្នាក់ជាតិ តាមតំបន់ និងថ្នាក់ខេត្ត** សំដៅដល់ផែនការដែលកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្រតម្រង់ទិសការប្រើប្រាស់ដីនិងការអភិវឌ្ឍផ្នែករូបវន្តដោយផ្អែកលើសក្ដានុពលនៃភូមិសាស្ត្រនិងតំបន់នីមួយៗក្នុងក្របខ័ណ្ឌថ្នាក់ជាតិ តាមតំបន់ និងថ្នាក់ខេត្ត។

**ព្រែក** សំដៅដល់ផ្លូវទឹកធម្មជាតិឬសិប្បនិម្មិតដែលនាំទឹកចេញឬចូលពីទន្លេឬស្ទឹង និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ។

**សន្ទស្សន៍ប្រើប្រាស់ដី** សំដៅដល់អនុបាតរវាងផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការនិងផ្ទៃក្រឡាដីឡូត៍ដែលសំណង់នោះតាំងនៅ។

**សមុទ្រ** សំដៅដល់ប្រភពធនធានទឹកប្រៃនិងជាកន្លែងទទួលរំហូរទឹកមកពីទន្លេ ស្ទឹង ព្រែក ជ្រោះ អូរ ទឹកក្រោមដី និងតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ។

**សំណល់រាវ** សំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុបំពុលបរិស្ថានដែលបញ្ចេញពីសកម្មភាពឬដំណើរការផ្ទាល់នៃផលិតកម្ម អាជីវកម្ម ឬសេវាកម្ម។

**ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់រួម** សំដៅដល់រោងចក្រសម្អាតទឹកកខ្វក់រួមរបស់ទីប្រជុំជន រាជធានី ខេត្ត ក្រុង ស្រុក ឬខណ្ឌ។

**ស្ទឹង** សំដៅដល់ផ្លូវទឹកធម្មជាតិដែលទទួលប្រភពទឹកមកពីជ្រោះ អូរ ទឹកក្រោមដី និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចាក់ទៅបឹង ទន្លេ និងសមុទ្រ។

**អ័ក្សនៃការអភិវឌ្ឍ** សំដៅដល់បណ្ដាញផ្លូវគមនាគមន៍ឬច្រករបៀងតភ្ជាប់ពីតំបន់អភិវឌ្ឍន៍មួយទៅតំបន់អភិវឌ្ឍន៍មួយទៀតដែលអាចឱ្យតំបន់ជាប់ជិតខាងតាមអ័ក្សទាញយកប្រយោជន៍ពីការអភិវឌ្ឍតាមអ័ក្សនេះបាន។

**អាងទន្លេ** សំដៅដល់តំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ទីជម្រាលនៃប្រព័ន្ធទឹកហូរដោយរាប់បញ្ចូលទាំងទឹកលើដីនិងទឹកក្រោមដី។

**អាងទឹក** សំដៅដល់ទីតម្កល់ទឹកដែលកើតឡើងដោយធម្មជាតិឬសិប្បនិម្មិតសម្រាប់ប្រើទៅតាមតម្រូវការ។

**អាងបង្គន់អនាម័យ** សំដៅដល់អាងទទួលទឹកកខ្វក់ពីបង្គន់អនាម័យនិងបន្ទប់ទឹក ដើម្បីស្តុកនិងបំបែកសំណល់សរីរាង្គក្នុងទឹកកខ្វក់មុនការហូរចេញទៅក្នុងប្រព័ន្ធលូសាធារណៈ។

**អូរ** សំដៅដល់ផ្លូវទឹកធម្មជាតិដែលទទួលប្រភពទឹកមកពីជ្រោះនិងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចូលព្រែក ស្ទឹង ទន្លេ ឬបឹង។

**ឯកសារឧបសម្ព័ន្ធ**

- ផែនទីរូបភាពពីលើអាកាសក្រុងព្រះវិហារ ឆ្នាំ២០២០
- ផែនទីព្រំប្រទល់រដ្ឋបាលក្រុងព្រះវិហារ ឆ្នាំ២០២០
- ផែនទីបែងចែកតំបន់ប្រើប្រាស់ដីក្រុងព្រះវិហារ ឆ្នាំ២០២០
- ផែនទីហេដ្ឋារចនាសម្ព័ន្ធក្រុងព្រះវិហារ ឆ្នាំ២០៤០
- ផែនទីបណ្តាញផ្លូវថ្នល់ក្រុងព្រះវិហារ ឆ្នាំ២០៤០
- ផែនទីតំបន់ការពារឬអភិរក្សក្រុងព្រះវិហារ ឆ្នាំ២០៤០
- ផែនទីតំបន់ធនធានទឹកក្រុងព្រះវិហារ ឆ្នាំ២០៤០
- ផែនទីតំបន់ការពារបរិស្ថានក្រុងព្រះវិហារ ឆ្នាំ២០៤០
- ផែនទីតំបន់លម្ហសាធារណៈនិងផ្ទៃបៃតងក្រុងព្រះវិហារ ឆ្នាំ២០៤០
- ផែនទីប្លង់គោលប្រើប្រាស់ដីក្រុងព្រះវិហារ ចក្ខុវិស័យឆ្នាំ២០៤០
- តារាងសង្ខេបអំពីបទប្បញ្ញត្តិនៃការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់ប្រើប្រាស់ដីនីមួយៗ៕